«សៀវភៅ *ដំណឹងល្អនៃអំណរដ៏អស្ចារ្យ* នាំជូននូវការរកឃើញដ៏ស្រស់ថ្លានូវសិរីល្អនៃពិធីបុណ្យណូអែល ដែលយើងអាចឈោងចាប់បាន។ ក្នុងការរស់នៅដ៏មមាញឹក យើងម្នាក់ៗអាចមានភាពធូរស្រាលក្នុងចិត្ត ពេលដែលយើងអង្គុយចុះ ដើម្បីចំណាយពេល១០នាទី ជារៀងរាល់ថ្ងៃ ក្នុងរដូវកាលនៃការរង់ចាំ មុនថ្ងៃណូអែល ហើយគិតអំពីព្រះយេស៊ូវ—ដែលជាព្រះអង្គសង្គ្រោះរបស់យើង ព្រមទាំងសម្រាក អរសប្បាយនិងមានកម្លាំងជាថ្មី!»

**Ray Ortlund,** Pastor to Pastors, Immanuel Church, Nashville, Tennessee

«តើធ្វើដូចម្ដេចឲ្យយើងអាចដកបទពិសោធជាមួយនឹងរដូវកាលនៃការរង់ចាំមុនថ្ងៃបុណ្យណូអែលមកដល់បាន តាមរបៀបដែលមានប្រយោជន៍ដល់វិញ្ញាណយើងបន្ទាប់ពីថ្ងៃទី២៥ ខែធ្នូ? គឺដោយមើលទៅ និងអរសប្បាយជាមួយនឹងសិរីល្អរបស់ព្រះ ក្នុងព្រះគ្រីស្ទដែលបានយកកំណើតជាមនុស្ស ជាព្រះអង្គសង្គ្រោះ ព្រះអម្ចាស់ បងប្រុស និងមិត្តសម្លាញ់របស់យើង។ សៀវភៅ *ដំណឹងល្អនៃក្ដីអំណរដ៏អស្ចារ្យ* ដែលលោកគ្រូ ចន ផាបភ័រ បាននិពន្ធឡើងនាំលោកអ្នកឲ្យស្វែងយល់អំពីដំណឹងល្អនៃថ្ងៃណូអែល ដោយអញ្ជើញអ្នកឲ្យចូលរួមជាមួយគាត់ ដោយការភ្ញាក់ផ្អើល ការស្វែងខ្លាច និងក្ដីអំណរ ដែលប្រសើរលើសភាពរីករាយក្នុងថ្ងៃឈប់សម្រាកទៅទៀត។ សៀវភៅនេះរៀបរាប់អំពីក្ដីអំណរដ៏ស្ថិតស្ថេរ ហើយលោកគ្រូ ផាបភ័រ នឹងចង្អុលបង្ហាញឲ្យលោកអ្នកងាកទៅរកក្ដីអំណរនោះ និងងាកទៅរកព្រះអង្គ—ព្រះយេស៊ូវគ្រីស្ទ។»

**J. A. Medders,** author, **Humble Calvinism;** Pastor, Risen Church, Houston, Texas

«សៀវភៅសម្រាប់អានប្រចាំថ្ងៃ ក្នុងរដូវកាលនៃការរង់ចាំ មុនថ្ងៃណូអែល ដែល លោកគ្រូ ចន ផាបភ័រ បាននិពន្ធ ប្រហែលជាមានទំព័រតិច តែលោកអ្នកនឹងរក ឃើញក្នុងអត្ថបទនីមួយៗ នូវភាពស៊ីជម្រៅ និងភាពសម្បូរបែបនៃគំនិត ដែល លោកគ្រូ ផាបភ័រ មានដូចដែលមនុស្សជាច្រើនបានទទួលស្គាល់ហើយ។ ដោយ ការកោតខ្លាចព្រះដោយអំណរ នោះគាត់ដឹកដៃយើងឲ្យចូលទៅក្នុងអត្ថន័យនៃ ការយាងមកប្រសូតរបស់ព្រះយេស៊ូវ។ ខណៈពេលដែលយើងឈប់បង្អង់ នៅ ក្នុងការអានអំពីកំណើតនៃព្រះរាជបុត្រានៃព្រះ ដែលបានយាងចុះមករកយើង ដោយការប្រសូតនៅបេថ្លេហិម យើងនឹងឲ្យតម្លៃកាន់តែខ្លាំងទៅលើក្តីស្រឡាញ់ ដ៏ហូរហៀរ ដែលព្រះអង្គបានបង្ហាញចេញមក ក្នុងការសុគតនៅឯភ្នំកាល់វ៉ារី។ បើលោកអ្នកចង់ឲ្យការចំណាយពេល ក្នុងរដូវកាលនៃបុណ្យណូអែល កាន់តែ មានតម្លៃខាងឯវិញ្ញាណ នោះសូមស្វែងយល់ការបង្រៀនក្នុងសៀវភៅនេះចុះ!»

**Conrad Mbewe,** Pastor, Kabwata Baptist Church, Lusaka, Zambia

«សៀវភៅនេះជាកំណប់ទ្រព្យដ៏មានតម្លៃ នៃសេចក្តីពិត ស្តីអំពីព្រះយេស៊ូវ! ក្នុងសៀវភៅសម្រាប់អានប្រចាំថ្ងៃដ៏ខ្លីនេះ លោកគ្រូ ចន ផាបភ័រ បាននាំយើង ឲ្យសម្លឹងមើលទៅពិធីបុណ្យណូអែលម្តងហើយម្តងទៀតតាមដែលយើងគួរ មើលឃើញ ជាដំណឹងល្អនៃអំណរដ៏អស្ចារ្យ សម្រាប់លោកអ្នក ហើយនិងខ្ញុំ។ សៀវភៅនេះគឺជាការអញ្ជើញ ឲ្យស្គាល់ព្រះរាជបុត្រានៃព្រះ ដែលព្រះវរបិតាបាន ចាត់ឲ្យយាងចុះមកប្រសូត ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។»

**Abigail Dodds,** author, (A)*Typical Woman: Free, Whole, and Called in Christ*

# ដំណឹងល្អនៃអំណរអស្ចារ្យ

*Good News of Great Joy*

**Other Books by John Piper**

*Battling Unbelief*
*Bloodlines*
*Brothers, We Are Not Professionals*
*Coronavirus and Christ*
*The Dangerous Duty of Delight*
*Desiring God*
*Does God Desire All to Be Saved?*
*Don't Waste Your Life*
*Expository Exultation*
*Fifty Reasons Why Jesus Came to Die*
*Finally Alive*
*Five Points*
*Future Grace*
*God Is the Gospel*
*God's Passion for His Glory*
*A Godward Heart*
*A Godward Life*
*A Hunger for God*
*Lessons from a Hospital Bed*
*Let the Nations Be Glad!*
*A Peculiar Glory*
*The Pleasures of God*
*Providence*
*Reading the Bible Supernaturally*
*Seeing and Savoring Jesus Christ*
*Spectacular Sins*
*A Sweet and Bitter Providence*
*Taste and See*
*Think*
*This Momentary Marriage*
*What Jesus Demands from the World*
*When I Don't Desire God*
*Why I Love the Apostle Paul*

# ដំណឹងល្អនៃ
# អំណរអស្ចារ្យ

## Good News of Great Joy

*សៀវភៅសម្រាប់អានប្រចាំថ្ងៃ រយៈពេល២៥ថ្ងៃ សម្រាប់*
*រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល*

John Piper

ផ្លូវពិត
plovpit.com

*Good News of Great Joy: 25 Devotional Readings for Advent*

Copyright © 2021 by Desiring God Foundation

Khmer Edition Published by ACTION Cambodia

English Edition Published by Crossway 1300 Crescent Street Wheaton, Illinois 60187

Crossway is a publishing ministry of Good News Publishers.

បកប្រែដោយ៖ លោក ឯក សត្យា

ជំនួយការបកប្រែ៖ លោក វ៉ែល ណាថាន

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ឈាង បូរ៉ា, លោក ខែម បូឡុង, លោក ពឹង ពេជ្រចិន្តា, លោក ប៊ុន ធីម៉ូថេ, និងលោក ខ្វៃ រ៉ាយអិន

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ, ថតទុកក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រ, ឬចែកចាយបន្តរួមបញ្ចូលទាំង ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក, បច្ចេកទេសថតចម្លង, ការថតទុកជាឯកសារសំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើមដែលនៅប្រទេសអាមេរិកឡើយ។

Cover design: Jordan Singer

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ែល ណាថាន និងលោក ទេព រ៉ូ

បោះពុម្ពលើកទី១ ចំនួន២.000ក្បាល ២០២១ នៃគ.ស.

បោះពុម្ពនៅប្រទេសចិន

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។



**លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេងដោយគ្រាន់តែចូលទៅកាន់គេហទំព័រ៖**

goodnewsofgreatjoykhmer.com/audio

# មាតិកា


អារម្ភកថា ១១

សេចក្តីផ្តើម៖ តើព្រះយេស៊ូវសព្វព្រះទ័យចង់បានអ្វី ក្នុងរដូវកាលបុណ្យណូអែលឆ្នាំនេះ? ២១

ថ្ងៃទី១ ចូររៀបចំផ្លូវថ្វាយព្រះ (លូកា ១:១៦-១៧) ៣១

ថ្ងៃទី២ ព្រះដ៏ខ្ពស់បំផុតរបស់នាង ម៉ារា (លូកា ១:៤៦-៥៥) ៣៧

ថ្ងៃទី៣ ការយាងចុះរបស់ព្រះ ដែលគេបានរង់ចាំជាយូរ (លូកា ១:៦៨-៧១) ៤៣

ថ្ងៃទី៤ ដើម្បីរាស្ត្រដ៏តូចទាបរបស់ព្រះអង្គ (លូកា ២:១-៥) ៤៩

ថ្ងៃទី៥ គ្មានផ្លូវវាងចេញពីផ្លូវទៅកាល់វ៉ារី (លូកា ២:៦-៧) ៥៥

ថ្ងៃទី៦ សន្តិភាពដល់អ្នកដែលជាទីគាប់ព្រះទ័យដល់ព្រះ (លូកា ២:១២-១៤) ៦១

ថ្ងៃទី៧ ព្រះមេស្ស៊ី ដែលពួកហោរាបានមករក (ម៉ាថាយ ២:១-២) ៦៧

ថ្ងៃទី៨ បាតុភូតផ្កាយ នៅបេថ្លេហិម (ម៉ាថាយ ២:២) ៧៣

ថ្ងៃទី៩ ការប្រឆាំងពីរយ៉ាងដែលព្រះយេស៊ូវជួប (ម៉ាថាយ ២:៣) ៨១

ថ្ងៃទី១០ ដង្វាយជាមាស កំញាន និងជ័រល្វីងទេស (ម៉ាថាយ ២:១០-១១) *៨៧*

ថ្ងៃទី១១ មូលហេតុដែលព្រះយេស៊ូវបានយាងចុះមក (ហេព្រើរ ២:១៤-១៥) *៩៣*

ថ្ងៃទី១២ ការជំនួសស្រមោល (ហេព្រើរ ៨:១-២) *១០១*

ថ្ងៃទី១៣ ការពិតចុងក្រោយបានបើកសម្តែងហើយ (ហេព្រើរ ៨:១-២,៥) *១០៧*

ថ្ងៃទី១៤ បង្ហាញការពិតឲ្យរាស្ត្រទ្រង់បានស្គាល់(ហេព្រើរ៨:៦) *១១៣*

ថ្ងៃទី១៥ ជីវិតនិងការស្លាប់នៅថ្ងៃណូអែល(យ៉ូហាន១០:១០) *១១៩*

ថ្ងៃទី១៦ ការអន់ថយ ដ៏ជោគជ័យបំផុតរបស់ព្រះ (ភីលីព ២:៩-១១) *១២៥*

ថ្ងៃទ១៧ សេចក្តីសង្គ្រោះដ៏អស្ចារ្យបំផុត ដែលយើងអាចយល់បាន (យេរេមា ៣១:៣១) *១៣១*

ថ្ងៃទី១៨ បុណ្យណូអែលគឺជាគំរូសម្រាប់បេសកកម្ម (យ៉ូហាន ១៧:១៨) *១៣៧*

ថ្ងៃទី១៩ បុណ្យណូអែល គឺដើម្បីឲ្យយើងមានសេរីភាព (ហេព្រើរ ២:១៤-១៥) *១៤៣*

ថ្ងៃទ២០ ការរួមចិត្តគ្នានៃថ្ងៃណូអែល (១យ៉ូហាន ៣:៨) *១៤៩*

ថ្ងៃទី២១ កំណើតនៃព្រះដែលមានព្រះវត្តមានតាំងពីអស់កល្ប
ជានិច្ច (យ៉ូហាន ១៨:៣៧) ១៥៥

ថ្ងៃទី២២ ដើម្បីឲ្យលោកអ្នកជឿព្រះអង្គ (យ៉ូហាន
២០:៣០-៣១) ១៦១

ថ្ងៃទី២៣ អំណោយរបស់ព្រះដែលមិនអាចពិពណ៌នាបាន (រ៉ូម
៥:១០-១១) ១៦៧

ថ្ងៃទី២៤ គោលបំណងទាំងពីរនៃបុណ្យណូអែល (១យ៉ូហាន
៣:៧-៨) ១៧៣

ថ្ងៃទី២៥ អំណោយទាំងបីនៃថ្ងៃណូអែល (១យ៉ូហាន ២:១-២;
៣:៧-៨) ១៧៩

ការសន្និដ្ឋាន៖ កណ្ឌគម្ពីរស្ដីអំពីបុណ្យណូអែលដែល
ខ្ញុំចូលចិត្តជាងគេ ១៨៩

សេចក្ដីបន្ថែម៖ ស្រមោលនៃសេចក្ដីសញ្ញាចាស់ និង
ការយាងមកនៃព្រះគ្រីស្ទ ១៩៩

លេខខគម្ពីរយោង ២០៥

# អារម្ភកថា

រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល គឺសម្រាប់ឲ្យយើងគោរពស្រឡាញ់ព្រះយេស៊ូវ ដោយក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ។ យ៉ាងហោចណាស់ នោះជាទស្សនៈរបស់យើង នៅក្នុងអង្គការ Desiring God។

រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល គឺជារដូវកាលប្រចាំឆ្នាំនៃការរង់ចាំដោយឥតធ្មត់ និងការរំពឹងចង់បានដោយសង្ឃឹម ហើយនិងការពិនិត្យមើលចិត្តគំនិតខ្លួនឯង ព្រមទាំងជារដូវកាលដែលត្រូវបានកំណត់យកក្នុងប្រតិទិន ដោយពួកជំនុំក្រុមគ្រួសារគ្រីស្ទាន និងអ្នកដើរតាមព្រះយេស៊ូវជាច្រើននាក់។ ព្រះគម្ពីរមិនបានតម្រូវឲ្យយើងប្រកាន់យករដូវកាលនៃការរង់ចាំមុនថ្ងៃណូអែលនោះឡើយ។បានជាយើងអាចប្រកាន់យក ឬមិនប្រកាន់យកក៏បាន ដោយការប្រកាន់យកនេះជាប្រពៃណីដែលបានកើតមាន ក្នុងប្រវត្តិសាស្ត្រពួកជំនុំតាំង

ពីយូរមកហើយ ដោយគេបានកំណត់យករដូវកាលនេះ ជាពេលត្រៀមខ្លួន សម្រាប់ថ្ងៃណូអែល។ មនុស្សជាច្រើនបានយល់ឃើញថា ការប្រកាន់យករដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល មានការប្រឹងប្រែង មានអំណររីករាយ និងមានប្រយោជន៍ខាងវិញ្ញាណ។

ពាក្យរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល ប្រែមកពីភាសាអង់គ្លេស *advent* មានប្រភពមកពីពាក្យ *adventus* ក្នុងភាសាឡាតាំង ដែលមានន័យថា «ការយាងមក»។ ពីដើមឡើយ រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល ដែលគេប្រារព្ធធ្វើនៅខែធ្នូ រៀងរាល់ឆ្នាំ គឺទាក់ទងនឹងការយាងមកលើកទី១របស់ព្រះយេស៊ូវ ប្រមាណជា២ពាន់ឆ្នាំមុន។ ប៉ុន្តែ គេក៏បានរាប់បញ្ចូលការយាងមកជាលើកទី២របស់ព្រះយេស៊ូវផងដែរ គឺដូចដែលបទចម្រៀង «អំណរដល់លោក» ជាបទដ៏ពេញនិយមសម្រាប់បុណ្យណូអែល បានបកស្រាយយ៉ាងច្បាស់ថា៖

*មិនឲ្យអំពើបាប និងទុក្ខព្រួយចម្រើន*
*នឹងគ្មានគុម្ពបន្លារីករាលដាលច្រើននៅលើដី*
*ព្រះអង្គយាងមក ដើម្បីឲ្យព្រះពរព្រះអង្គហូរចុះមក*
*ដរាបណា នៅមានអំពើបាប សេចក្ដីស្លាប់ និងភាពប្រេះបែក។*[១]

១ លោក Isaac Watts, "Joy to the World," ឆ្នាំ១៧១៩។

រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល ចាប់ផ្ដើម នៅថ្ងៃអាទិត្យទី៤ មុនថ្ងៃណូអែល ហើយបញ្ចប់មុនថ្ងៃណូអែលមួយថ្ងៃ។ បានសេចក្ដីថា អាស្រ័យទៅលើថ្ងៃអាទិត្យទី៤មកដល់ចំថ្ងៃណា  រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល អាចចាប់ផ្ដើមឆាប់បំផុត នៅថ្ងៃទី២៧ ខែវិច្ឆិកា ហើយចាប់ផ្ដើមយឺតបំផុត នៅថ្ងៃទី៣ខែធ្នូ។ រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល នៅឆ្នាំនីមួយៗ មានរយៈពេលខុសគ្នា គឺមានរយៈពេលចាប់ពី ២២ទៅ២៨ថ្ងៃ ចំណែកឯរដូវកាលនៃការត្រៀមខ្លួនសម្រាប់ពិធីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ (ឬ “Lent”) មានរយៈពេល៤០ថ្ងៃ (ដោយបូកបន្ថែមថ្ងៃអាទិត្យ៦ថ្ងៃទៀត)។

គ្រីស្ទាននៅទូទាំងពិភពលោក ប្រារព្ធរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល តាមរបៀបខុសៗគ្នា ហើយមានការតុបតែងផ្សេងៗគ្នាផងដែរ។ ខ្លះដុតទៀនបំភ្លឺ។ ខ្លះច្រៀងបទចម្រៀង។ ខ្លះញ៉ាំស្ករគ្រាប់។ ខ្លះឲ្យកាដូ។ ខ្លះចងព្យួរកម្រងផ្កាជាដើម។ មនុស្សជាច្រើនបានធ្វើនូវសកម្មភាពទាំងអស់នេះ។ ប៉ុន្មានសតវត្សរ៍នេះ គ្រីស្ទបរិស័ទបានរកឃើញវិធីល្អៗជាច្រើន ដើម្បីអបអរការយាងមកចាប់កំណើតរបស់ព្រះយេស៊ូវ ឲ្យមានរយៈពេលវែងជាង២៤ម៉ោង នៃថ្ងៃទី២៥ ខែធ្នូ ដែលជារយៈពេល

ដ៏ខ្លី។ ការយាងមកប្រសូតរបស់ព្រះរាជបុត្រានៃព្រះ «ដើម្បី យើង និងដើម្បីសង្គ្រោះយើងឲ្យរួចពីបាប» ដូចដែលមានចែង ក្នុងគោលជំនឿពួកសាវ័កដ៏ចាស់បុរាណ គឺមានសារៈសំខាន់ ខ្លាំងណាស់ បានជាការប្រារព្ធធ្វើតែមួយថ្ងៃ គឺមិនគ្រប់គ្រាន់ ឡើយ។ ជាការពិតណាស់ នេះជាពិធីដែលយើងនឹងប្រារព្ធ ធ្វើអស់កល្បជានិច្ច។

យើងខ្ញុំសូមអធិស្ឋាន សូមឲ្យកូនសៀវភៅសម្រាប់ប្រកប ជាមួយព្រះអម្ចាស់ជាប្រចាំថ្ងៃនេះ ជួយឲ្យលោកអ្នកយកព្រះ យេស៊ូវជាចំណុចកណ្ដាល និងកំណប់ទ្រព្យដ៏ប្រសើរបំផុត ក្នុង រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែលឆ្នាំនេះ។ ទៀន និងស្គរ គ្រាប់មានប្រយោជន៍ នៅក្នុងការប្រារព្ធ ប៉ុន្តែ យើងត្រូវប្រាកដ ថា យើងពិតជាបានគោរពស្រឡាញ់ព្រះយេស៊ូវ លើសអ្វីៗ ទាំងអស់ ក្នុងខែធ្នូដែលសម្បូរទៅដោយភាពប្រញាប់ប្រញាល់ និងអ៊ូអរ។

ដូចនេះ ខ្លឹមសារនៃអត្ថបទសម្រាប់រដូវកាលនៃការរង់ចាំមុន ថ្ងៃណូអែលឆ្នាំនេះ ប្រហែលជាផ្ដោតទៅលើប្រធានបទ «ចូរ យើងចូលមក ចូរយើងគោរពស្រឡាញ់ព្រះអង្គ»។[២] អត្ថបទ

២ លោក John Francis Wade, "O Come, All Ye Faithful," ឆ្នាំ១៧៥១។

សម្រាប់ជញ្ជឹងគិតព្រះបន្ទូលក្នុងសៀវភៅនេះ សុទ្ធតែនិយាយ អំពីការគោរពស្រឡាញ់ព្រះគ្រីស្ទ ដែលជាព្រះអម្ចាស់។ ត្រង់ ចំណុចខ្លះ អ្នកនឹងបានឃើញការពិពណ៌នា ដូចក្នុងបទ ចម្រៀងទំនុកសកល «ឱ! អេម៉ាញូអែលអើយ សូមព្រះអង្គ យាងមក» និងក្នុងបទ «ន៍ ពពួកទេវតា ច្រៀងបទ»។[៣] ហើយ យើងក៏នឹងបានអានអត្ថបទខ្លីៗ អំពីពួកហោរាទាំងបី។ ប៉ុន្តែ តួ អង្គសំខាន់នៅចំណុចកណ្តាលនៃសៀវភៅនេះ គឺព្រះយេស៊ូវជា បុត្រតូចដែលបានប្រសូតនៅភូមិបេថ្លេហិម ជាព្រះដែលយក កំណើតជាមនុស្ស ដែលបានរុំនឹងសំពត់ ផ្ទំក្នុងស្នូក។ ព្រះអង្គ ត្រូវយាងទៅកាល់វ៉ារី ដោយព្រះវរបិតាបានចាត់ឲ្យយាងមក សុគត ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីសង្គ្រោះរាស្ត្រ ព្រះអង្គឲ្យរួចពីបាប។

ទំព័រសេចក្តីផ្តើមនៃសៀវភៅនេះ ត្រូវបានរៀបចំមកសម្រាប់ អាន មុនរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល ចាប់ផ្តើម (ឬ ក្នុងអំឡុងរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល)។ លោកអ្នក អាចអានសេចក្តីបញ្ចប់ ដែលជាការជ្រើសរើសខគម្ពីរជាបន្ថែម សម្រាប់អាននៅថ្ងៃណូអែល (ឬនៅពេលណាក៏បានមុនថ្ងៃ

៣ លោក John Mason Neale, បកប្រែ “O Come, O Come, Emmanuel,” ឆ្នាំ១៨៦១; លោក Charles Wesley, “Hark! The Herald Angels Sing,” ឆ្នាំ១៧៣៩។

ណូអែល ជាពិសេសបើសិនជាលោកអ្នកចង់ដឹង អំពីកណ្ឌគម្ពីរសម្រាប់ថ្ងៃណូអែល ដែលលោកគ្រូគង្វាល ចន ផាបភ័រ [John Piper] ចូលចិត្ត)។ សេចក្តីបន្ថែម អំពីស្រមោលនៅគ្រាសញ្ញាចាស់ និងការយាងមករបស់ព្រះគ្រីស្ទ ដែលស៊ីសង្វាក់នឹងអត្ថបទសម្រាប់ជញ្ជឹងគិត នៅថ្ងៃទី១២ (ហើយអ្នកនឹងរកឃើញការពន្យល់ក្នុងរង្វង់ក្រចកក្នុងអត្ថបទនោះ)។

សូមព្រះទ្រង់សព្វព្រះទ័យ នឹងជួយចិត្តរបស់លោកអ្នក ឲ្យគោរពស្រឡាញ់ព្រះយេស៊ូវ កាន់តែស៊ីជម្រៅ និងជិតស្និទ្ធ ក្នុងរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែលឆ្នាំនេះ។

លោក David Mathis

*អ្នកកែសម្រួលច្បង*

*Desiring God*

# សេចក្តីផ្តើម

ឱព្រះវរបិតាអើយ ឯពួកអ្នកដែលទ្រង់ប្រទានមកទូលបង្គំ នោះទូលបង្គំចង់ឲ្យគេនៅជាមួយនឹងទូលបង្គំ ក្នុងកន្លែងដែលទូលបង្គំនៅដែរ ដើម្បីឲ្យបានឃើញសិរីល្អ ដែលទ្រង់បានប្រទានមកទូលបង្គំ ដ្បិតទ្រង់បានស្រឡាញ់ទូលបង្គំ តាំងតែពីមុនកំណើតលោកីយ៍រៀងមក ។

យ៉ូហាន ១៧:២៤

សេចក្ដីផ្ដើម

# តើព្រះយេស៊ូវសព្វព្រះទ័យចង់បានអ្វី ក្នុងរដូវកាលបុណ្យណូអែលឆ្នាំនេះ?

តើព្រះយេស៊ូវសព្វព្រះទ័យចង់បានអ្វី ក្នុងរដូវកាលបុណ្យណូអែលឆ្នាំនេះ? យើងអាចរកឃើញចម្លើយសម្រាប់សំណួរនេះ ក្នុងសេចក្ដីអធិស្ឋានរបស់ព្រះអង្គ។ តើព្រះអង្គបានទូលសូមអ្វីខ្លះពីព្រះវរបិតា? សេចក្ដីអធិស្ឋានវែងបំផុតរបស់ព្រះអង្គ គឺមានចែងក្នុងកណ្ឌគម្ពីរយ៉ូហានជំពូក១៧។ ព្រះអង្គបានបង្ហាញជម្រៅដ៏ជ្រៅបំផុតនៃបំណងព្រះទ័យព្រះអង្គ ក្នុងខ២៤។

ក្នុងចំណោមមនុស្សមានបាបទាំងអស់ ដែលមិនសមនឹងទទួលសេចក្ដីសង្គ្រោះ ក្នុងពិភពលោកនេះ មានអ្នកដែលព្រះទ្រង់បាន «ប្រទាន» មកព្រះយេស៊ូវ។ ពួកគេជាមនុស្សដែលព្រះទ្រង់បាននាំមករកព្រះរាជបុត្រា (យ៉ូហាន ៦:៤៤, ៦៥)។

ពួកគេ*ជាគ្រីស្ទបរិស័ទ* គឺអ្នកដែល*បានទទួលជឿ*ព្រះយេស៊ូវជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ដែលបានសុគតនៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ និងជាកំណប់ទ្រព្យនៃជីវិតពួកគេ (យ៉ូហាន ១:១២; ៣:១៧; ៦:៣៥; ១០:១១, ១៧-១៨; ២០:២៨)។ ព្រះយេស៊ូវមានបន្ទូលថា ព្រះអង្គសព្វព្រះទ័យឲ្យពួកគេនៅជាមួយព្រះអង្គ។

ជួនកាល យើងឮគេនិយាយថា ព្រះទ្រង់បានបង្កើតមនុស្សមក ដោយសារព្រះអង្គឯកោ។ ហេតុនេះហើយពួកគេក៏បាននិយាយថា «ព្រះបានបង្កើតយើងមក ដើម្បីឲ្យយើងបាននៅ*ជាមួយព្រះអង្គ*»។ តើព្រះយេស៊ូវបានយល់ស្របនឹងមតិនេះទេ? ជាការពិតណាស់ ព្រះអង្គ*ពិតជា*បានមានបន្ទូលថា ព្រះអង្គសព្វព្រះទ័យឲ្យយើងនៅជាមួយព្រះអង្គ! ប៉ុន្តែ តើហេតុអ្វី? សូមអានខគម្ពីរនេះឲ្យចប់។ ហេតុអ្វីព្រះអង្គសព្វព្រះទ័យឲ្យយើងនៅជាមួយព្រះអង្គ?

គឺ...ដើម្បីឲ្យបានឃើញសិរីល្អ ដែលទ្រង់ [ព្រះវរបិតា] បានប្រទានមកទូលបង្គំ ដ្បិតទ្រង់បានស្រឡាញ់ទូលបង្គំ តាំងតែពីមុនកំណើតលោកីយ៍រៀងមក។ បើព្រះបន្ទូលព្រះអង្គខាងលើនេះ ពិតជាបានបង្ហាញភាពឯកោរបស់ព្រះអង្គមែន នោះមាន

ន័យថា ព្រះអង្គកំពុងបង្ហាញនូវភាពឯកោ តាមរបៀបដ៏ចម្លែកហើយ។ ព្រះអង្គមានបន្ទូលថា «ទូលបង្គំចង់ឲ្យគេនៅជាមួយនឹងទូលបង្គំ ដើម្បីឲ្យបានឃើញសិរីល្អរបស់ទូលបង្គំ»។ តាមពិត ព្រះបន្ទូលព្រះអង្គ មិនបានបង្ហាញថា ព្រះអង្គមានភាពឯកោនោះទេ តែបានបង្ហាញថា ព្រះអង្គយកព្រះទ័យទុកដាក់ចំពោះការស្រេកឃ្លាន*របស់យើង* គឺមិនមែនចំពោះភាពឯកោ*របស់ព្រះអង្គ*ឡើយ។

ព្រះយេស៊ូវមិនឯកោ ព្រោះព្រះអង្គ ព្រះវរបិតា និងព្រះវិញ្ញាណ មានការពេញព្រះទ័យយ៉ាងខ្លាំង នៅក្នុងការប្រកបស្និទ្ធស្នាល នៃព្រះត្រៃឯក។ គឺយើងទេតើ ដែលស្រេកឃ្លានរកអ្វីមួយ  គឺមិនមែនព្រះអង្គទេដែលស្រេកឃ្លាននោះ។ ហើយអ្វីដែលព្រះយេស៊ូវសព្វព្រះទ័យចង់បាន សម្រាប់ថ្ងៃណូអែល នោះគឺដើម្បីឲ្យយើងបានពិសោធន៍នឹងមូលហេតុដែលទ្រង់បានបង្កើតយើងមក គឺដើម្បីឲ្យយើងបានឃើញ និងអរសប្បាយនឹងសិរីល្អព្រះអង្គ។

សូមព្រះអង្គធ្វើឲ្យការនេះជ្រួតជ្រាប ក្នុងវិញ្ញាណយើង! ព្រះយេស៊ូវបានបង្កើតយើងមក (យ៉ូហាន ១:៣)  ដើម្បីឲ្យយើងមើលឃើញសិរីល្អព្រះអង្គ។

មុនពេលព្រះយេស៊ូវជិតដល់ពេលយាងទៅឈើឆ្កាង ព្រះអង្គបានបង្ហាញជម្រៅនៃព្រះទ័យដ៏ជ្រៅបំផុត ដោយទូលសូមដល់ព្រះវរបិតាថា៖ «ឱព្រះវរបិតាអើយ...ទូលបង្គំ*ចង់ឲ្យ*គេនៅជាមួយនឹងទូលបង្គំ...ដើម្បីឲ្យបាន*ឃើញសិរីល្អ*ដែលទ្រង់បានប្រទានមកទូលបង្គំ»។

ប៉ុន្តែ នេះគ្រាន់តែបានបង្ហាញព្រះទ័យទ្រង់តែពាក់កណ្ដាលក្នុងខគម្ពីរនៃការអធិស្ឋានដ៏ខ្ពស់បំផុតរបស់ព្រះអង្គ។ មុននេះខ្ញុំទើបតែបាននិយាយថា ព្រះទ្រង់ពិតជាបានបង្កើតយើងមកដើម្បីឲ្យយើងមើលឃើញ *និងអរសប្បាយ*នឹងសិរីល្អព្រះអង្គ។ តើនោះជាអ្វីដែលព្រះអង្គសព្វព្រះទ័យចង់បាន គឺឲ្យយើងមិនគ្រាន់តែមើលឃើញសិរីល្អរបស់ព្រះអង្គ តែបានអរសប្បាយ រីករាយ ពេញចិត្ត ឲ្យតម្លៃ និងស្រឡាញ់សិរីល្អរបស់ព្រះអង្គមែនទេ? សូមពិចារណា អំពីខ២៦ ដែលជាខចុងក្រោយនៃជំពូកនេះ ដែលបានចែងថា៖

ទូលបង្គំបានឲ្យគេស្គាល់ព្រះនាមទ្រង់ ក៏នឹងសម្ដែងឲ្យគេស្គាល់តទៅទៀត *ដើម្បីឲ្យសេចក្ដីស្រឡាញ់ ដែលទ្រង់ស្រឡាញ់ដល់ទូលបង្គំ បាននៅក្នុងគេ* ហើយឲ្យទូលបង្គំនៅក្នុងគេដែរ។

នោះជាចុងបញ្ចប់នៃការអធិស្ឋានរបស់ព្រះអង្គ។ តើព្រះយេស៊ូវមានគោលដៅ*ចុងក្រោយអ្វី* សម្រាប់យើង? គឺមិនគ្រាន់តែឲ្យយើងបានឃើញសិរីល្អព្រះអង្គប៉ុណ្ណោះទេ តែក៏ដើម្បីឲ្យយើងស្រឡាញ់ព្រះអង្គ ដោយក្តីស្រឡាញ់ដែលព្រះវរបិតាមានចំពោះទ្រង់ គឺដូចដែលទ្រង់បានទូលសូមថា «ទូលបង្គំបានឲ្យគេស្គាល់ព្រះនាមទ្រង់ ក៏នឹងសម្ដែងឲ្យគេស្គាល់តទៅទៀត ដើម្បីឲ្យសេចក្តីស្រឡាញ់ ដែលទ្រង់ស្រឡាញ់ដល់ទូលបង្គំ បាននៅក្នុងគេ»។

បំណងព្រះទ័យ និងគោលដៅរបស់ព្រះយេស៊ូវ គឺដើម្បីឲ្យយើងមើលឃើញសិរីល្អទ្រង់ ហើយបន្ទាប់មក យើងអាចស្រឡាញ់អ្វីដែលយើងបានឃើញ ដោយក្តីស្រឡាញ់ដែលព្រះវរបិតាមាន ចំពោះព្រះរាជបុត្រាទ្រង់។ ហើយព្រះបន្ទូលព្រះអង្គត្រង់ចំណុចនេះ មិនមានន័យថា យើងគ្រាន់តែ*យកតម្រាប់*តាមសេចក្តីស្រឡាញ់ ដែលព្រះវរបិតាមានចំពោះព្រះរាជបុត្រានោះទេ។ តែមានន័យថា សេចក្តីស្រឡាញ់របស់ព្រះវរបិតាក្លាយជាសេចក្តីស្រឡាញ់ដែលយើងមានចំពោះព្រះរាជបុត្រា ពោលគឺយើងស្រឡាញ់ព្រះរាជបុត្រា ដោយក្តីស្រឡាញ់ដែលព្រះវរបិតាមានចំពោះព្រះរាជបុត្រា។ ហើយ

អ្វីដែលព្រះវិញ្ញាណបានដាក់ក្នុងជីវិតយើងនោះ គឺសេចក្ដីស្រឡាញ់ ចំពោះព្រះរាជបុត្រា ដោយអំណាចនៃព្រះវរបិតា តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។

អ្វីដែលព្រះយេស៊ូវសព្វព្រះទ័យចង់បានខ្លាំងបំផុត សម្រាប់បុណ្យណូអែលនោះគឺ ឲ្យពួកជ្រើសតាំងរបស់ទ្រង់ជួបជុំគ្នា ហើយបន្ទាប់មកទទួលបានអ្វីដែល*ពួកគេ*ស្រេកឃ្លានបំផុត គឺ*ឃើញ*សិរីល្អព្រះអង្គ ហើយបន្ទាប់មក*អរសប្បាយ*នឹងសិរីល្អព្រះអង្គ ដោយការអរសប្បាយដែលព្រះវរបិតាមានចំពោះព្រះរាជបុត្រា។

អ្វីដែលខ្ញុំចង់បានបំផុត សម្រាប់ណូអែលឆ្នាំនេះ គឺចង់ចូលរួមជាមួយលោកអ្នក (និងមនុស្សជាច្រើនទៀត) នៅក្នុងការមើលឃើញព្រះគ្រីស្ទ ក្នុងភាពពេញលេញរបស់ព្រះអង្គ ហើយយើងទាំងអស់គ្នា ស្រឡាញ់អ្វីដែលយើងឃើញ ដោយក្តីស្រឡាញ់ដែលលើសសមត្ថភាពរបស់ចិត្តយើងជាមនុស្ស ដែលមិនមានភាពពេញលេញ។ នេះជាគោលដៅរបស់យើង ក្នុងសៀវភៅនេះ ក្នុងរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល។ យើងខ្ញុំចង់ឃើញ និងអរសប្បាយនឹងព្រះយេស៊ូវទាំងអស់គ្នា ដោយយើងបានប្រារព្ធរដូវកាលនៃការរង់ចាំមុន

ថ្ងៃណូអែល (ការយាងមកប្រសូត) ដំបូង ហើយរំពឹងចង់បានការយាងមកលើកទី២របស់ព្រះអង្គ។

ក្នុងរដូវកាលនៃបុណ្យណូអែលឆ្នាំនេះ ព្រះយេស៊ូវសព្វព្រះទ័យនឹងអធិស្ឋានឲ្យយើងថា «ឱព្រះវរបិតាអើយ! ទូលបង្គំចង់ឲ្យពួកគេបានស្គាល់សិរីល្អរបស់ទូលបង្គំ ដើម្បីឲ្យពួកគេអរសប្បាយក្នុងទូលបង្គំ ដូចដែលព្រះអង្គអរសប្បាយនឹងទូលបង្គំ»។ *ចូរយើងមើលឃើញ*ព្រះគ្រីស្ទ ដូចដែលព្រះវរបិតាបានទតឃើញព្រះអង្គ ហើយ*អរសប្បាយ*នឹងព្រះគ្រីស្ទ ដោយដួងព្រះទ័យរបស់ព្រះ។ នោះជាលក្ខណៈនៃនគរស្ថានសួគ៌។ នោះជាអំណោយ ដែលព្រះគ្រីស្ទបានយាងមកបង់ថ្លៃទិញ សម្រាប់មនុស្សមានបាប ដោយលះបង់ព្រះជន្មព្រះអង្គជំនួសយើង។

# ថ្ងៃទី១

*វានឹងបង្វិលកូនចៅសាសន៍អ៊ីស្រាអែលជាច្រើន ឲ្យត្រឡប់
វិលមកឯព្រះអម្ចាស់ជាព្រះនៃគេវិញ វានឹងនាំមុខទ្រង់ ដោយ
នូវវិញ្ញាណ ហើយនិងអំណាចរបស់លោក អេលីយ៉ា ដើម្បី
នឹងបំបែរចិត្តពួកឪពុកមកឯកូន និងពួកចចេសមកឯប្រាជ្ញា
របស់មនុស្សសុចរិតវិញ ប្រយោជន៍នឹងរៀបចំមនុស្ស១
ពួកទុកជាស្រេច សម្រាប់ជារាស្ត្ររបស់ព្រះអម្ចាស់។*

លូកា ១:១៦-១៧

ថ្ងៃទី១

# ចូររៀបចំផ្លូវថ្វាយព្រះ

ការអ្វីដែលលោក យ៉ូហាន-បាទីស្ទ បានធ្វើសម្រាប់ប្រជាជនអ៊ីស្រាអែល នោះរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល ក៏បានធ្វើការនោះសម្រាប់យើងផងដែរ។ ចូរយើងកុំខកខានមិនបានត្រៀមខ្លួន សម្រាប់ពិធីបុណ្យណូអែលនោះឡើយ។ ការត្រៀមខ្លួន*ខាងឯវិញ្ញាណ*សម្រាប់ពិធីបុណ្យណូអែល ពិតជាសំខាន់ណាស់។ ពិធីបុណ្យណូអែលនឹងនាំមកនូវក្តីអំណរ និងមានឥទ្ធិពលកាន់តែខ្លាំងមកលើជីវិតលោកអ្នក បើសិនជាលោកអ្នកបានរៀបចំខ្លួនជាស្រេច!

ដូចនេះ អ្នកអាចមានការ*រៀបចំខ្លួន*ដូចតទៅ...

ទី១ ចូរយើងជញ្ជឹងគិត អំពីសេចក្តីពិតដែលថា យើងត្រូវការ*ព្រះអង្គសង្គ្រោះ*មួយអង្គ។ ពិធីបុណ្យណូអែលនឹងក្លាយជាពេលដ៏មានអំណរ បន្ទាប់ពីយើងបានទទួលស្គាល់ថា យើង

ជាមនុស្សមានបាប សមនឹងវិនាសអស់កល្ប និងត្រូវការព្រះអង្គសង្គ្រោះ។ «ដ្បិតនៅថ្ងៃនេះ មាន*ព្រះអង្គសង្គ្រោះ*១អង្គប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់» (លូកា ២:១១)។ បានសេចក្ដីថា បើសិនជាយើងអត់យល់ពីសារៈសំខាន់នៃព្រះអង្គសង្គ្រោះ នោះយើងអត់យល់ពីសារៈសំខាន់នៃថ្ងៃបុណ្យណូអែលឡើយ។ សូមឲ្យការជញ្ជឹងគិត ក្នុងរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែលឆ្នាំនេះ ជួយដាស់តឿនលោកអ្នកឲ្យនឹកចាំ អំពីសណ្ឋានដ៏ជូរល្វីងរបស់លោកអ្នក ដែលត្រូវការព្រះអង្គសង្គ្រោះ។

ទី២ ចូរយើងពិនិត្យមើលខ្លួនយើង។ អត្ថន័យដែលរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល មានសម្រាប់ពិធីបុណ្យណូអែល គឺមិនខុសពីអត្ថន័យ ដែលរដូវនៃការរៀបចំខ្លួនមុនថ្ងៃពិធីបុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ មានសម្រាប់ពិធីបុណ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញនោះឡើយ។ គឺដូចមានសេចក្ដីចែងទុកមកថា «ឱព្រះអង្គអើយ សូមពិនិត្យមើល ឲ្យបានស្គាល់ចិត្តទូលបង្គំផង សូមល្បងលឲ្យបានជ្រាបអស់ទាំងគំនិតនៃទូលបង្គំចុះ សូមទតមើលបើមានអំពើអាក្រក់ណានៅក្នុងទូលបង្គំ ហើយនាំទូលបង្គំតាមផ្លូវដ៏នៅអស់កល្ប

ជានិច្ច» (ទំនុកតម្កើង ១៣៩:២៣-២៤)។ ចូរយើង*រៀបចំចិត្ត*
របស់យើងម្នាក់ៗថ្វាយព្រះអង្គ...ជម្រុះចោលទម្លាប់អាក្រក់។

ទី៣ ចូរបង្កើតឲ្យមានការរំពឹងចង់បាន ការគិតទុកជាមុន និងភាពរំភើបរីករាយ ដែលផ្តោតទៅលើព្រះ នៅក្នុងគ្រួសាររបស់លោកអ្នក ជាពិសេសសម្រាប់ក្មេងៗ។ បើលោកអ្នកមានចិត្តរំភើបរីករាយ ចំពោះព្រះគ្រីស្ទ នោះពួកគេក៏នឹងរីករាយដូចលោកអ្នកផងដែរ។ បើលោកអ្នកអាចបង្កើតឲ្យមានភាពរំភើបរីករាយ តែចំពោះសម្ភារៈ តើធ្វើដូចម្តេចឲ្យក្មេងៗមានចិត្តស្រេកឃ្លានរកព្រះ? ចូរខិតខំស្រមៃរកវិធីធ្វើឲ្យក្មេងៗអាចមើលឃើញភាពអស្ចារ្យ នៃការយាងមកប្រសូតរបស់ព្រះដ៏ជាស្តេច។

ទី៤ ចូរចំណាយពេលឲ្យច្រើនជាមួយព្រះគម្ពីរ ហើយទន្ទេញខគម្ពីរដែលប៉ះពាល់ចិត្តខ្លាំង! «ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលសួរថា ឯពាក្យរបស់អញ តើមិនមែនដូចជាភ្លើង ហើយដូចជាញញួរ ដែលបំបែកថ្មខ្ទេចខ្ទីទេឬអី?» (យេរេមា ២៣:២៩)។ ចូរយើងជួបជុំគ្នា នៅជុំវិញភ្លើងនៃព្រះបន្ទូលព្រះ ក្នុងរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែលឆ្នាំនេះ។ ភ្លើងនោះផ្តល់ឲ្យនូវភាពកក់ក្តៅ និងបញ្ចេញផ្កាភ្លើងដែលមានពណ៌នៃព្រះគុណ ហើយផ្តល់ឲ្យនូវការប្រោសឲ្យជាដល់មនុស្ស

រាប់ពាន់នាក់ ដែលកំពុងឈឺចាប់ ព្រមទាំងធ្វើជាពន្លឺសម្រាប់
យប់ងងឹតផងដែរ។

# ថ្ងៃទី២

រួចម៉ារានិយាយឡើងថា ព្រលឹងខ្ញុំលើកតម្កើងព្រះអម្ចាស់
វិញ្ញាណខ្ញុំក៏រីករាយនឹងព្រះដ៏ជាព្រះអង្គសង្គ្រោះនៃខ្ញុំ
ដ្បិតទ្រង់បានទតមើលសណ្ឋានទាបថោករបស់ខ្ញុំ ជាបាវបម្រើទ្រង់។
មើលចុះ ពីនេះទៅមុខ គ្រប់ទាំងដំណមនុស្សនឹងរាប់ខ្ញុំថា ជាអ្នកមានពរ។
ពីព្រោះព្រះដ៏មានព្រះចេស្ដា ទ្រង់បានប្រោសសេចក្ដីយ៉ាងល្អវិសេសដល់ខ្ញុំ ព្រះនាមទ្រង់បរិសុទ្ធ
ទ្រង់មានសេចក្ដីមេត្តាករុណាដល់គ្រប់ទាំងដំណមនុស្ស
ដែលគេកោតខ្លាចទ្រង់តរៀងទៅ។
ទ្រង់បានសម្ដែងឫទ្ធិ ដោយព្រះហស្តទ្រង់ ព្រមទាំងកំចាត់កំចាយ
មនុស្សអំនួត ដោយសារគំនិតដែលនៅក្នុងចិត្តខ្លួនគេ។
ទាំងទំលាក់ស្ដេចពីបល្ល័ង្កចេញ ហើយលើកមនុស្សរាបសាឡើងវិញ។
ឯមនុស្សឃ្លាន ទ្រង់បានចំអែតដោយរបស់ល្អ តែពួកអ្នកមាន ទ្រង់បានបណ្ដេញឲ្យទៅទទេវិញ។
ទ្រង់បានជួយអ៊ីស្រាអែល ជាអ្នកបម្រើទ្រង់ ឲ្យបាននឹកចាំពីសេចក្ដីមេត្តាករុណាទ្រង់។
ដូចជាទ្រង់មានព្រះបន្ទូលនឹងពួកឰយុកោយើង គឺនឹងលោកអ័ប្រាហាំ
ហើយនឹងពូជលោកជារៀងរាបដរាបតមក។

លូកា ១:៤៦-៥៥

ថ្ងៃទី២

# ព្រះដ៏ខ្ពស់បំផុតរបស់នាង ម៉ារា

នាង ម៉ារា បានដឹងថា ព្រះទ្រង់ជិតដល់ពេលកែប្រែប្រវត្តិសាស្ត្រនៃមនុស្សជាតិហើយ ពោលគឺនាងដឹងថា រយៈពេលបីទសវត្សរ៍ដ៏សំខាន់បំផុតនៃប្រវត្តិសាស្ត្រ ជិតដល់ពេលចាប់ផ្តើមហើយ។ នេះជាចំណុច ដែលគួរឲ្យកត់សម្គាល់បំផុតរបស់ព្រះ ដែលនាងបានមើលឃើញច្បាស់។

ហើយពេលនោះ ព្រះទ្រង់នៅទីណា? ព្រះទ្រង់កំពុងផ្តោតព្រះទ័យមកលើស្ត្រីសាមញ្ញពីរនាក់ ដែលជាមនុស្សបន្ទាបខ្លួន ដែលម្នាក់មានវ័យចាស់ និងជាស្រីអារ (ឈ្មោះនាងអេលីសាបិត) និងម្នាក់ទៀតជាស្ត្រីវ័យក្មេង និងព្រហ្មចារី (ឈ្មោះនាង ម៉ារា)។ ហើយនាង ម៉ារា មានការប៉ះពាល់ចិត្តយ៉ាងខ្លាំង ដោយការបើកសម្តែងនេះមកពីព្រះ ដែលស្រឡាញ់មនុស្សតូចទាប បានជានាងបន្លឺសំឡេងច្រៀងបទចម្រៀង

មួយបទ ដែលគេបានដាក់ចំណងជើងឲ្យថា «ទំនុកតម្កើងរបស់នាង ម៉ារា»។

នាង ម៉ារា និងនាង អេលីសាបិត ជាវីរនារីដ៏អស្ចារ្យ នៅក្នុងកណ្ឌគម្ពីរដំណឹងល្អ ដែលលោក លូកា បាននិពន្ធ។ គាត់ស្រឡាញ់ជំនឿរបស់ស្ត្រីទាំងពីរខ្លាំងណាស់។ នាង អេលីសាបិត និងនាង ម៉ារា សុទ្ធតែមានភាពតូចទាប និងការបន្ទាបខ្លួនដោយអំណរ ខណៈពេលដែលពួកគេចុះចូលចំពោះព្រះដ៏ខ្ពស់បំផុតរបស់ពួកគេ។ ការនេះហាក់ដូចជាបានធ្វើឲ្យគាត់ស្ញើចសរសើរ ហើយក៏ជាអ្វីដែលគាត់ចង់ឲ្យលោក ថេវភីល ស្ញើចសរសើរផងដែរ។

នាង អេលីសាបិត បាននិយាយថា «ដូចម្ដេចហ្ន៎ បានជាដល់ទៅព្រះមាតាព្រះអម្ចាស់នៃខ្ញុំក៏មកសួរដូច្នេះដែរ?» (លូកា ១:៤៣) ហើយទន្ទឹមនឹងនោះ នាង ម៉ារា ក៏បាននិយាយផងដែរថា (លូកា ១:៤៨) «ទ្រង់បានទតមើលសណ្ឋានទាបថោករបស់ខ្ញុំ ជាបាវបម្រើទ្រង់»។

មនុស្សដែលមានវិញ្ញាណ ដែលពិតជាអាចសរសើរតម្កើងព្រះអម្ចាស់យ៉ាងពិតប្រាកដ គឺជាមនុស្សដូចនាង អេលីសាបិត និងនាង ម៉ារា ដែលបានទទួលស្គាល់ភាពតូចទាបរបស់ខ្លួន

ហើយមានចិត្តស្ងើចជាពន់ពេក ចំពោះការបន្ទាបព្រះកាយរបស់ព្រះដ៏ខ្ពស់បំផុត។

# ថ្ងៃទី៣

*សូមឲ្យព្រះអម្ចាស់ ជាព្រះនៃសាសន៍អ៊ីស្រាអែល បានប្រកប ដោយព្រះគុណ ពីព្រោះទ្រង់បានទតមើល ហើយប្រោសលោះ រាស្ត្រទ្រង់ ព្រមទាំងបង្កើតព្រះដ៏មានឥទ្ធិឫទ្ធិ នៅក្នុងពូជហ្លួង ដាវីឌ ជាអ្នកបម្រើ ទ្រង់ សម្រាប់នឹងជួយសង្គ្រោះយើងផង ដូចជាទ្រង់មានព្រះបន្ទូល ដោយមាត់ពួកហោរាបរិសុទ្ធរបស់ ទ្រង់តាំងពីបុរាណមក គឺជាសេចក្តីសង្គ្រោះ ឲ្យរួចពីខ្មាំងសត្រូវ យើង ហើយពីកណ្តាប់ដៃនៃអស់អ្នកណាដែលស្អប់យើង។*

លូកា ១:៦៨-៧១

ថ្ងៃទី៣

# ការយាងចុះរបស់ព្រះ ដែលគេបានរង់ចាំជាយូរ

តាមរយៈពាក្យសម្ដីរបស់លោក សាការី ដែលជាប្ដីរបស់នាង អេលីសាបិត ក្នុងកណ្ឌគម្ពីរ លូកា ១:៦៨-៧១ យើងសង្កេតឃើញមានរឿងដែលគួរឲ្យកត់សម្គាល់ពីរយ៉ាង។

ទី១ កាលពី៩ខែមុន លោក សាការី មិនជឿថា ភរិយាគាត់នឹងមានកូននោះទេ។ តែក្រោយមក គាត់បានពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងមានការជឿជាក់យ៉ាងខ្លាំងចំពោះព្រះរាជកិច្ចនៃការប្រោសលោះរបស់ព្រះ នៅក្នុងការយាងមកនៃព្រះមេស្ស៊ី បានជាគាត់ប្រើពាក្យសម្រាប់និយាយអំពីអតីតកាលថា “ទ្រង់បានទតមើល ហើយប្រោសលោះរាស្ត្រទ្រង់”។ សម្រាប់គំនិតរបស់មនុស្សដែលមានជំនឿ ការអ្វីដែលព្រះទ្រង់សន្យាថានឹងធ្វើ គឺដូចជាការអ្វីដែលទ្រង់បានធ្វើហើយ។ លោក សាការី

បានរៀនទុកចិត្តព្រះបន្ទូលរបស់ព្រះ ហេតុនេះហើយ គាត់ក៏បានមានការធានាដ៏គួរឲ្យកត់សម្គាល់ថា ព្រះ «ទ្រង់បានទតមើល ហើយប្រោសលោះរាស្ត្រទ្រង់» (លូកា ១:៦៨)។

ទី២ ការយាងមករបស់ព្រះយេស៊ូវ ដែលជាព្រះមេស្ស៊ី ជាការដែលព្រះទ្រង់យាងចុះមក ក្នុងពិភពលោកយើង និយាយរួមគឺ *ព្រះនៃសាសន៍អ៊ីស្រាអែល*បានយាងចុះមក និងប្រោសលោះមនុស្ស។ អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ដែលជនជាតិយូដាបានរងទុក្ខ ដោយការជឿថា ព្រះអម្ចាស់បានយាងចេញពីពួកគេ ដោយវិញ្ញាណនៃការថ្លែងទំនាយលែងមានទៀត ហើយនគរអ៊ីស្រាអែលបានធ្លាក់ចូលទៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង។ ហើយអស់អ្នកកោតខ្លាចព្រះ នៅអ៊ីស្រាអែល កំពុងតែរង់ចាំការយាងចុះមករបស់ព្រះ។

កណ្ឌគម្ពីរលូកាបានចែងថា មានបុរសវ័យចាស់ម្នាក់ទៀតឈ្មោះស៊ីម្មាន ជាអ្នកជឿច្បាស់ កំពុង «រង់ចាំសេចក្តីដោះទុក្ខរបស់សាសន៍អ៊ីស្រាអែល» (លូកា ២:២៥)។ ទន្ទឹមនឹងនោះ អ្នកស្រីអាណេដែលជាអ្នកអធិស្ឋានខ្ជាប់ខ្ជួន ក៏ «កំពុងរង់ចាំសេចក្តីប្រោសលោះនៅទីក្រុងយេរូសាឡឹម» (លូកា ២:៣៨)។

សម័យនោះ ជាគ្រានៃការរំពឹងរង់ចាំដ៏អស្ចារ្យ។ ពេលនោះ ការយាងចុះរបស់ព្រះមករកមនុស្ស ដែលគេបានរង់ចាំអស់ពេលជាយូរ ជិតដល់ពេលកើតឡើងហើយ ដោយទ្រង់ជិតដល់ពេលយាងចុះមក តាមរបៀបដែលគ្មាននរណាម្នាក់នឹកស្មានដល់។

# ថ្ងៃទី៤

*នៅគ្រានោះស្ដេច សេសារ-អូគូស្ទ បានចេញព្រះរាជឱង្ការ១ ច្បាប់ ឲ្យមនុស្សទាំងអស់ដែលនៅផែនដីបានចុះបញ្ជី បញ្ជីមុនដំបូងនោះ បានធ្វើនៅវេលាដែលលោក គីរេនាស ធ្វើជាចៅហ្វាយនៅស្រុកស៊ីរី មនុស្សទាំងអស់ក៏ទៅឯស្រុកកំណើតរៀងខ្លួន ដើម្បីចុះបញ្ជី ឯយ៉ូសែប គាត់ក៏ចេញពីណាសារ៉ែត ស្រុកកាលីឡេ ឡើងទៅឯស្រុកយូដា ដល់ក្រុងរបស់ហ្លួងដាវីឌ ដែលឈ្មោះថា បេថ្លេហិម ពីព្រោះគាត់ជាព្រះវង្ស ហើយជាព្រះញាតិនឹងហ្លួងដាវីឌដែរ ដើម្បីនឹងចុះបញ្ជីជាមួយនឹងម៉ារា ដែលបានបម្រុងទុកឲ្យធ្វើជាប្រពន្ធគាត់ ដែលនាងមានគភ៌នោះ។*

លូកា ២:១-៥

ថ្ងៃទី៤

# ដើម្បីរាស្ត្រដ៏តូចទាបរបស់ព្រះអង្គ

តើអ្នកធ្លាប់គិត អំពីភាពអស្ចារ្យនៃការដែលព្រះទ្រង់បានរៀបផែនការជាមុន ឲ្យព្រះមេស្ស៊ីយាងចុះមកចាប់កំណើតនៅភូមិបេថ្លេហិមដែរឬទេ (តាមបទទំនាយ ក្នុងកណ្ឌគម្ពីរ មីកា ៥:១)? តើអ្នកនឹកស្ញើចក្នុងចិត្តដែរឬទេ ពេលដែលបានដឹងថា ព្រះទ្រង់មានផែនការទុកជាមុន ដោយនៅពេលកំណត់មកដល់ ទ្រង់បានរៀបចំឲ្យមាតារបស់ព្រះមេស្ស៊ី និងឪពុកស្របច្បាប់របស់ទ្រង់ រស់នៅក្នុងភូមិណាសារ៉ែត តែមិនមែននៅភូមិបេថ្លេហិម ហើយដើម្បីសម្រេចតាមព្រះបន្ទូលទ្រង់ ទ្រង់ក៏បាននាំជនសាមញ្ញ ដ៏តូចទាបពីរនាក់នេះ ទៅភូមិបេថ្លេហិម នៅថ្ងៃណូអែលដំបូងបំផុត ដោយទ្រង់បណ្ដាលចិត្តស្ដេច សេសារ-អូគូស្ទ ឲ្យចេញព្រះរាជក្រឹត្យបង្គាប់ប្រជាជនក្នុងចក្រភពរ៉ូម៉ាំងទាំងមូល ឲ្យទៅចុះឈ្មោះក្នុងស្រុកកំណើតរៀងៗ

ខ្លួន? បានសេចក្តីថា ព្រះទ្រង់បានប្រើព្រះរាជក្រឹត្យសម្រាប់ចក្រភពទាំងមូល ដើម្បីបណ្តាលឲ្យមនុស្សពីរនាក់ផ្លាស់ទីចម្ងាយ១១២ គីឡូម៉ែត្រ!

តើអ្នកធ្លាប់មានអារម្មណ៍ថា ខ្លួនតូចទាប និងមិនសំខាន់ក្នុងពិភពលោកមួយ ដែលមានប្រជាជន៧ពាន់លាននាក់ ដែលក្នុងនោះ ព័ត៌មានទាំងអស់សុទ្ធតែនិយាយអំពីរឿងធំៗក្នុងផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម និងអំពីជនមានឈ្មោះល្បី មានតួនាទីសំខាន់ មានអំណាច និងឥទ្ធិពលជាអន្តរជាតិជាដើម? ខ្ញុំក៏ធ្លាប់មានអារម្មណ៍ដូចនេះដែរ។ បើអ្នកធ្លាប់មានអារម្មណ៍ដូចនេះ នោះចូរកុំបណ្តោយឲ្យអារម្មណ៍នេះធ្វើឲ្យអ្នកបាក់ទឹកចិត្ត ឬមិនសប្បាយចិត្តនោះឡើយ។ ដ្បិតព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា គ្រប់ទាំងអំណាចនយោបាយ នៃប្រទេសមហាអំណាច និងឧស្សាហកម្មខ្នាតយក្សទាំងអស់សុទ្ធតែត្រូវបានព្រះទ្រង់គ្រប់គ្រង ដោយមិនដឹងខ្លួន មិនមែនដើម្បីខ្លួនពួកគេនោះទេ តែដើម្បីមនុស្សដ៏តូចទាបរបស់ព្រះ ដែលមាននាង ម៉ារា និងលោក យ៉ូសែប ដ៏តូចទាបជាដើម ដែលត្រូវធ្វើដំណើរពីភូមិណាសារ៉ែត ទៅភូមិបេថ្លេហិម។ ព្រះអង្គបានប្រើចក្រភពមួយ ដើម្បីសម្រេចព្រះបន្ទូលសន្យារបស់

ទ្រង់ ហើយប្រទានពររាស្ត្រទ្រង់។

ពេលណាលោកអ្នកជួបទុក្ខលំបាកក្នុងពិភពដ៏តូចនៃបទពិសោធន៍របស់លោកអ្នក នោះចូរកុំគិតថា ព្រះហស្តរបស់ព្រះបានរួញខ្លីនោះឡើយ។ ព្រះអង្គមិនបានស្វែងរកភាពចម្រុងចម្រើន ឬកេរ្តិ៍ឈ្មោះរបស់យើងនោះទេ តែព្រះអង្គស្វែងរកភាពបរិសុទ្ធរបស់យើង អស់ពីព្រះទ័យទ្រង់។ នេះក៏ជាមូលហេតុដែលព្រះអង្គគ្រប់គ្រងពិភពលោកទាំងមូល។ គឺដូចដែលកណ្ឌគម្ពីរ សុភាសិត ២១:១ បានចែងថា “ព្រះទ័យនៃស្តេចនោះនៅក្នុងព្រះហស្តព្រះយេហូវ៉ា ដូចជាផ្លូវនៃទឹកហូរទាំងឡាយ ទ្រង់ឲ្យបែរហូរទៅខាងណាក៏តាមតែព្រះហឫទ័យ”។ ហើយព្រះអង្គតែងតែបង្វែរលំហូរនៃផ្លូវទឹកនោះ ដើម្បីសម្រេចបំណងព្រះទ័យដ៏អស់កល្ប ដើម្បីជួយសង្គ្រោះ និងញែកជាបរិសុទ្ធ ក្នុងចំណោមរាស្ត្រព្រះអង្គ។

ព្រះអង្គជាព្រះដ៏ធំ សម្រាប់មនុស្សដ៏តូចទាប ហើយយើងមានហេតុផលដ៏ធំប្រសើរ ដើម្បីនឹងអរសប្បាយ ដោយដឹងថា ពួកស្តេច ប្រធានាធិបតី នាយករដ្ឋមន្ត្រី អធិការបតី និងមេកុលសម្ព័ន្ធទាំងអស់ ក្នុងពិភពលោកនេះ អនុវត្តតាមព្រះរាជក្រឹត្យនៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ដោយមិនដឹង

ខ្លួន ដើម្បីឲ្យយើង ដែលជាកូនទ្រង់ អាចផ្លាស់ប្រែ ឲ្យមានលក្ខណៈដូចព្រះរាជបុត្រាព្រះអង្គ ព្រះនាមព្រះយេស៊ូវគ្រីស្ទ ហើយចូលទៅក្នុងសិរីល្អដ៏អស់កល្បរបស់ព្រះអង្គ។

# ថ្ងៃទី៥

*កាលកំពុងតែនៅទីនោះ វេលាដែលនាងត្រូវប្រសូតក៏មកដល់ ហើយនាងប្រសូតបានបុត្រាជាចម្បងមក រួចរុំនឹងសំពត់ផ្ដេកក្នុងស្នូក ពីព្រោះក្នុងផ្ទះសំណាក់គ្មានកន្លែងណានៅទេ។*

លូកា ២:៦-៧

ថ្ងៃទី៥

# គ្មានផ្លូវវាងចេញពីផ្លូវទៅកាល់វ៉ារី

អ្នកប្រហែលជាគិតថា បើព្រះទ្រង់គ្រប់គ្រងពិភពលោក តាមរយៈការធ្វើជំរឿនទូទាំងចក្រភពរ៉ូម៉ាំង ដើម្បីនាំនាង ម៉ារា និងលោក យ៉ូសែប ទៅភូមិបេថ្លេហិម នោះទ្រង់ប្រាកដជាអាចរៀបចំឲ្យមានបន្ទប់មួយនៅសល់ ក្នុងផ្ទះសំណាក់នោះហើយ។

ជាការពិតណាស់ ព្រះអង្គអាចរៀបចំឲ្យមានបន្ទប់មួយសម្រាប់ពួកគេ! ព្រះអង្គពិតជាអាច! ហើយព្រះយេស៊ូវក៏*អាច*ចាប់កំណើតក្នុងគ្រួសារអ្នកមានស្តុកស្តម្ភផងដែរ។ ព្រះអង្គ*អាច*ធ្វើឲ្យថ្មក្លាយជានំប៉័ង ពេលព្រះអង្គគង់នៅវាលរហោស្ថាន។ ព្រះអង្គក៏*អាច*បង្គាប់ឲ្យពួកទេវតារាប់ពាន់នាក់មកជួយព្រះអង្គ នៅសួនច្បារគែតសេម៉ានី។ ព្រះអង្គក៏*អាច*យាងចុះពីឈើឆ្កាង ហើយជួយសង្គ្រោះអង្គទ្រង់ផ្ទាល់ផង

ដែរ។ តែដែលសំខាន់នោះ យើងមិនត្រូវសួរថា ព្រះអង្គ*អាច*ធ្វើអ្វីខ្លះនោះទេ តែត្រូវសួរថា តើព្រះអង្គ*សព្វព្រះទ័យ*នឹងធ្វើអ្វី?

ព្រះទ្រង់មានព្រះទ័យចង់ឲ្យព្រះគ្រីស្ទធ្លាក់ខ្លួនក្រ ដើម្បីយើងរាល់គ្នា ទោះព្រះអង្គជាអ្នកមានក៏ដោយ។ នៅភូមិបេថ្លេហិមផ្ទះសំណាក់ទាំងអស់សុទ្ធតែដាក់ផ្លាកថា «អស់បន្ទប់» គឺ*ដើម្បីយើងរាល់គ្នា*។ «ទ្រង់បានត្រឡប់ជាក្រ ដោយ*ព្រោះអ្នករាល់គ្នា*» (២កូរិនថូស ៨:៩)។

ព្រះទ្រង់គ្រប់គ្រងលើអ្វីៗទាំងអស់ សូម្បីតែបន្ទប់សណ្ឋាគារ និងក្រុមហ៊ុនបដិសណ្ឋារកិច្ច ដើម្បីកូនព្រះអង្គ។ ផ្លូវទៅកាន់កាល់វ៉ារីបានចាប់ផ្តើមដោយផ្លាកសញ្ញា «អស់បន្ទប់» នៅភូមិបេថ្លេហិម ហើយបញ្ចប់ដោយការស្តោះទឹកមាត់ និងការជេរប្រមាថនៃឈើឆ្កាង នៅទីក្រុងយេរូសាឡឹម។

ហើយយើងមិនត្រូវភ្លេចថា ព្រះយេស៊ូវបានមានបន្ទូលថា «បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ» (លូកា ៩:២៣)។

យើងរួមដំណើរជាមួយព្រះអង្គ តាមផ្លូវទៅកាល់វ៉ារី ហើយឮព្រះអង្គមានបន្ទូលថា «ចូរនឹកចាំពីពាក្យដែលខ្ញុំបានប្រាប់រួច

ហើយថា បាវមិនមែនធំជាងចៅហ្វាយទេ បើគេបានបៀតបៀនដល់ខ្ញុំ នោះគេនឹងបៀតបៀនដល់អ្នករាល់គ្នា ហើយបើគេបានកាន់តាមពាក្យខ្ញុំ នោះគេនឹងកាន់តាមពាក្យរបស់អ្នករាល់គ្នាដែរ» (យ៉ូហាន ១៥:២០)។

កាលកំពុងតែទៅតាមផ្លូវ នោះមានម្នាក់ទូលទ្រង់ថា «ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ ទោះបើទ្រង់យាងទៅក្នុងទីណាក៏ដោយ»។ ព្រះយេស៊ូវមានព្រះបន្ទូលតបថា «កញ្ជ្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មានសំបុកដែរ តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ» (លូកា ៩:៥៧-៥៨)។

ជាការពិតណាស់ ព្រះទ្រង់អាចរៀបចំឲ្យព្រះយេស៊ូវមានបន្ទប់សម្រាប់ប្រសូត។ តែការធ្វើដូចនេះគឺជាការបត់ទៅតាមផ្លូវវាង ចេញពីផ្លូវទៅកាល់វ៉ារីហើយ។

# ថ្ងៃទី៦

*ហើយនេះជាទីសម្គាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹង ឃើញព្រះឱរស១រុំនឹងសំពត់ផ្ដេកនៅក្នុងស្នូក នោះស្រាប់តែ មានពួកពលបរិវារកកកុញពីស្ថានសួគ៌ មកនៅជាមួយនឹង ទេវតានោះ ក៏ពោលសរសើរដល់ព្រះថា សួស្ដីដល់ព្រះនៅ ស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដី នៅ កណ្ដាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់។*

លូកា ២:១២-១៤

ថ្ងៃទី៦

# សន្តិភាពដល់អ្នកដែលជាទីគាប់ព្រះទ័យដល់ព្រះ

តើសន្តិភាព ឬសេចក្តីសុខសាន្តសម្រាប់នរណា? ការសរសើរតម្កើងរបស់ពួកទេវតា មានបង្កប់ចំណុចដ៏គ្រៀមក្រំ។ សន្តិភាពនៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់។ ឬសន្តិភាពក្នុងចំណោមមនុស្ស ដែលព្រះអង្គសព្វព្រះទ័យ។ តែបើគ្មានជំនឿទេ នោះមិនអាចធ្វើឲ្យព្រះទ្រង់សព្វព្រះទ័យបានឡើយ (ហេព្រើរ ១១:៦)។ ដូចនេះ ពិធីបុណ្យណូអែលមិនបាននាំមកនូវសេចក្តីសុខសាន្តដល់មនុស្សទាំងអស់ឡើយ។

ព្រះយេស៊ូវមានបន្ទូលថា «ទោសនេះ គឺថា ពន្លឺបានមកក្នុងលោកីយ៍ តែមនុស្សលោកចូលចិត្តនឹងសេចក្តីងងឹតជាជាងពន្លឺ ពីព្រោះអំពើដែលគេធ្វើទាំងប៉ុន្មាន សុទ្ធតែអាក្រក់»

(យ៉ូហាន ៣:១៩)។ ពេលដែលលោក ស៊ីម្មាន ដែលជាចាស់ទុំ បានឃើញព្រះឱរសយេស៊ូវ គាត់បានមានប្រសាសន៍ថា «មើល បុត្រនេះបានតាំងឡើង សម្រាប់ធ្វើឲ្យពួកសាសន៍អ៊ីស្រាអែលជាច្រើនដួល ហើយងើបឡើងវិញ ក៏សម្រាប់ជាទីសម្គាល់ ដែលគេនឹងស្រដីទទឹងផង ឯនាងវិញ នឹងមានដាវចាក់ទំលុះព្រលឹងនាងដែរ ដើម្បីឲ្យគំនិតក្នុងចិត្តរបស់មនុស្សជាច្រើនបានសម្តែងចេញមក» (លូកា ២:៣៤-៣៥)។ ឱ! តើមានមនុស្សប៉ុន្មាននាក់ ដែលក្រឡេកមើលទៅក្រៅ នៅថ្ងៃណូអែល ដ៏ក្រៀមក្រំ និងត្រជាក់ មិនឃើញមានអ្វី ក្រៅពីទីសម្គាល់នៃការដែលត្រូវគេស្រដីទទឹង ឬប្រឆាំង?

«ទ្រង់បានយាងមកគង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនបានទទួលទ្រង់សោះ ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែល*ជឿ*ដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ» (យ៉ូហាន ១:១១-១២)។ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកសិស្សទ្រង់ថា «ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកីយ៍ឲ្យទេ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ» (យ៉ូហាន

១៤:២៧)។

មនុស្សដែលអរសប្បាយនឹងសន្តិភាពរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត គឺជាអ្នកដែលទូលដល់ព្រះ ឲ្យជ្រាបពីសេចក្តីសំណូម និងពាក្យទូលអង្វរ (ភីលីព ៤:៦-៧)។

ជំនឿលើព្រះបន្ទូលសន្យារបស់ព្រះ គឺជាគន្លឹះសម្រាប់បើកហឹបនៃកំណប់ទ្រព្យ ដែលជាសន្តិភាពរបស់ព្រះ។ ហេតុនេះហើយ សាវ័ក ប៉ុល បានអធិស្ឋានថា «សូមព្រះនៃសេចក្តីសង្ឃឹមប្រទានឲ្យអ្នករាល់គ្នាបានគ្រប់អស់ទាំងសេចក្តីអំណរ និងសេចក្តីសុខសាន្តដ៏ពោរពេញ *ដោយសារជំនឿ*» (រ៉ូម ១៥:១៣)។ ពេលណាយើង*ទុកចិត្ត*ព្រះបន្ទូលសន្យា ហើយមានក្តីអំណរ សន្តិភាព និងក្តីស្រឡាញ់ នោះព្រះនាមទ្រង់ក៏បានតម្កើងឡើង។

សូមថ្វាយសិរីល្អដល់ព្រះ ដែលគង់នៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី ក្នុងកណ្តាលចំណោមមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់! គឺដល់មនុស្សម្នាក់ៗ មកពីគ្រប់ទាំងពូជមនុស្ស ហើយគ្រប់ទាំងភាសា គ្រប់ទាំងកុលសម្ព័ន្ធ គ្រប់ទាំងសាសន៍ដែលជឿព្រះអង្គ។

# ថ្ងៃទី៧

*កាលព្រះយេស៊ូវទ្រង់ប្រសូតមក នៅភូមិបេថ្លេហិម ស្រុក យូដា ក្នុងរាជ្យស្ដេច ហេរ៉ូឌ នោះមានពួកហោរ ពីទិស ខាងកើត មកដល់ក្រុងយេរូសាឡឹម សួរថា តើព្រះអង្គ ដែលប្រសូតមក ធ្វើជាស្ដេចសាសន៍យូដា ទ្រង់គង់ នៅឯណា ពីព្រោះយើងបានឃើញផ្កាយរបស់ទ្រង់ ពី ទិសខាងកើតមក ហើយយើងមកថ្វាយបង្គំទ្រង់។*

ម៉ាថាយ ២:១-២

ថ្ងៃទី៧

# ព្រះមេស្ស៊ី ដែលពួកហោរាបានមករក

កណ្ឌាគម្ពីរម៉ាថាយមិនបានថែងអំពីការដែលពួកអ្នកគង្វាលចូលគាល់ព្រះយេស៊ូវ ក្នុងក្រោលសត្វនោះទេ គឺខុសពីកណ្ឌាគម្ពីរលូកា។ សាវ័ក ម៉ាថាយ ដែលជាអ្នកនិពន្ធកណ្ឌាគម្ពីរនេះ បាននិយាយផ្តោតទៅលើជនបរទេសតែម្តង ដែលជាសាសន៍ដទៃ មិនមែនជាជនជាតិយូដា ដែលធ្វើដំណើរមកពីទិសខាងកើត មកថ្វាយបង្គំព្រះយេស៊ូវ។

ដូចនេះ សាវ័ក ម៉ាថាយ និយាយអំពីព្រះយេស៊ូវ នៅដើមដំបូង និងចុងបញ្ចប់នៃកណ្ឌាគម្ពីរដំណឹងល្អរបស់គាត់ ដើម្បីនិយាយសង្កត់ធ្ងន់ថា ព្រះអង្គជាព្រះមេស្ស៊ី សម្រាប់គ្រប់ជាតិសាសន៍ គឺមិនគ្រាន់តែសម្រាប់ជនជាតិយូដាប៉ុណ្ណោះឡើយ។

ត្រង់ចំណុចនេះ អ្នកមកថ្វាយបង្គំព្រះអង្គមុនគេ គឺជាពួកហោរា ឬពួកតារាសាស្ត្រ ឬក៏ពួកអ្នកប្រាជ្ញ មិនមែនមកពីទឹកដីអ៊ីស្រាអែល តែមកពីទិសខាងកើត គឺប្រហែលចក្រភពបាប៊ីឡូន។ ពួកគេជាសាសន៍ដទៃ ដែលគេរាប់ថា មិនស្អាតតាមក្រឹត្យវិន័យសញ្ញាចាស់។

ហើយនៅចុងបញ្ចប់នៃកណ្ឌគម្ពីរម៉ាថាយ ព្រះយេស៊ូវបានមានបន្ទូលជាលើកចុងក្រោយថា «គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង ដូច្នេះចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍» (ម៉ាថាយ ២៨:១៨-១៩)។

ការនេះមិនគ្រាន់តែបានបើកផ្លូវ ឲ្យពួកសាសន៍ដទៃបានអរសប្បាយ ក្នុងព្រះមេស្ស៊ីប៉ុណ្ណោះទេ តែថែមទាំងបានធ្វើជាភស្តុតាងបញ្ជាក់បន្ថែមទៀតថា ព្រះអង្គជាព្រះមេស្ស៊ី ព្រោះមានបទទំនាយ ដែលបានបើកសម្តែងម្តងហើយម្តងទៀតថា តាមពិត ជាតិសាសន៍ និងស្តេចទាំងឡាយ នឹងចូលមករកព្រះអង្គ ដែលជាអ្នកគ្រប់គ្រងពិភពលោក។ ឧទាហរណ៍ កណ្ឌគម្ពីរ អេសាយ ៦០:៣ បានចែងថា៖

*អស់ទាំងសាសន៍នឹងមូលគ្នាមកឯពន្លឺរបស់ឯង ហើយស្តេច ទាំងប៉ុន្មាននឹងមកឯរស្មីដែលភ្លឺចេញពីឯង ក្នុងកាលដែលឯង រះឡើង។*

ដូចនេះ កណ្ឌគម្ពីរម៉ាថាយបានបង្ហាញភស្តុតាងបន្ថែម ទៀត ដើម្បីបញ្ជាក់អំពីភាពជាព្រះមេស្ស៊ីរបស់ព្រះអង្គ *ហើយ* បង្ហាញថា ព្រះអង្គជាព្រះមេស្ស៊ី ជាក្សត្រ និងអ្នកសម្រេចបទ ទំនាយ សម្រាប់ជាតិសាសន៍ទាំងអស់ គឺមិនគ្រាន់តែសាសន៍ អ៊ីស្រាអែលប៉ុណ្ណោះទេ។

# ថ្ងៃទី៨

*គង់នៅឯណា? ពីព្រោះយើងបានឃើញផ្កាយរបស់ទ្រង់*
*ពីទិសខាងកើតមក ហើយយើងមកថ្វាយបង្គំទ្រង់។*

ម៉ាថាយ ២:២

ថ្ងៃទី៨

# បាតុភូតផ្កាយនៅបេថ្លេហិម

ព្រះគម្ពីរបានចែងអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យជាច្រើន ដែលបានកើតឡើង ធ្វើឲ្យយើងមានការងឿងឆ្ងល់ ម្តងហើយម្តងទៀត។ តើ «ផ្កាយ» នេះបាននាំពួកហោរាពីទិសខាងកើត មកកាន់ទីក្រុងយេរូសាឡឹម ដោយរបៀបណា?

ព្រះគម្ពីរមិនបានចែងថា ផ្កាយនោះដឹកនាំ ឬនាំមុខពួកគេតាមផ្លូវទៅទីក្រុងយេរូសាឡឹមនោះទេ។ តែគ្រាន់តែបានចែងថា ពួកគេបានឃើញផ្កាយមួយនោះ ពីទិសខាងកើតមក (ម៉ាថាយ ២:២) ហើយពួកគេក៏បានមកទីក្រុងយេរូសាឡឹម។ តើផ្កាយនោះបាននាំមុខពួកគេ ក្នុងការធ្វើដំណើរចម្ងាយប្រហែល៧គីឡូម៉ែត្រ ពីទីក្រុងយេរូសាឡឹម ទៅភូមិបេថ្លេហិម ដូចដែលមានចែងក្នុងកណ្ឌគម្ពីរ ម៉ាថាយ ២:៩ ដោយរបៀបណា?

ហើយតើផ្កាយមួយដួង «នៅចំពីលើកន្លែងដែលបុត្រតូចគង់នៅ» ដោយរបៀបណា?

យើងមិនដឹងថា ត្រូវឆ្លើយដូចម្ដេចទេ។ មានមនុស្សជាច្រើនបានប្រឹងប្រែងពន្យល់អំពីបាតុភូតនេះ ដោយថា វាបានកើតឡើង ដោយសារការប្រសព្វគ្នានៃភព ឬថា វាជាផ្កាយដុះកន្ទុយ ឬក៏បន្ទុះផ្កាយ ឬមួយជាទីសម្គាល់នៃការអស្ចារ្យ។ យើងគ្រាន់តែមិនដឹងថា វាជាអ្វី។ ហើយខ្ញុំសូមលើកទឹកចិត្តអ្នក កុំឲ្យមានការងប់ងុល ឬផ្ដោតចិត្ត ទៅលើទ្រឹស្ដីអំពីបាតុភូតនេះ ដែលទីបំផុត គ្រាន់តែជាការស្មាន ហើយមិនសូវមានប្រយោជន៍ខាងឯវិញ្ញាណ។

មនុស្សជាច្រើនចូលចិត្តចំណាយពេលគិត ឬងប់ងុលនឹងរឿងទាំងនេះ ពោលគឺគិតអំពីរបៀបដែលផ្កាយនោះផ្លាស់ទី និងរបៀបដែលសមុទ្រក្រហមញែកជាពីរ ហើយនិងរបៀបដែលនំម៉ាណាធ្លាក់ចុះពីលើមេឃ ព្រមទាំងរបៀបដែលលោកយ៉ូណាស អាចរួចជីវិត នៅក្នុងពោះត្រីធំ ក៏ដូចជាគិត អំពីរបៀបដែលដួងច័ន្ទប្រែជាមានពណ៌ឈាម។ ទោះគេគិតថា ខ្ញុំនិយាយម៉ែជាទូទៅក៏ដោយ ក៏ខ្ញុំសូមដាស់តឿនអ្នកថា ជាទូទៅអ្នកទាំងនោះមានផ្នត់គំនិត ដែលចូលចិត្តចំណាយពេលគិត

អំពីរឿងបន្ទាប់បន្សំ ច្រើនជាងគិតអំពីរឿងដែលសំខាន់ជាង។

លោកអ្នកមិនឃើញពួកគេបង្ហាញចេញនូវក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ចំពោះចំណុចស្នូលដ៏សំខាន់បំផុតនៃដំណឹងល្អ ដែលមានដូចជា សេចក្តីបរិសុទ្ធរបស់ព្រះ ភាពគួរឲ្យស្អប់ខ្ពើមនៃអំពើបាប ភាពអស់សង្ឃឹមរបស់មនុស្ស និងការសុគតរបស់ព្រះគ្រីស្ទ ការរាប់ជាសុចរិត ដោយសារជំនឿតែម្យ៉ាង ការញែកជាបរិសុទ្ធដោយព្រះវិញ្ញាណ សិរីល្អនៃការយាងមកវិញរបស់ព្រះគ្រីស្ទ និងការជំនុំជម្រះនៅគ្រាចុងក្រោយ។ ជានិច្ចជាកាល ពួកគេហាក់ដូចជា បង្វែរផ្លូវលោកអ្នក ដោយប្រើអត្ថបទ ឬសៀវភៅថ្មីៗ ដែលធ្វើឲ្យពួកគេមានចិត្តរំភើបរីករាយ និងនិយាយអំពីរឿងបន្ទាប់បន្សំ ក្នុងព្រះគម្ពីរ។ ពួកគេមិនសូវអរសប្បាយនឹងការពិតដែលជាចំណុចស្នូលដ៏ប្រសើរ និងសំខាន់ជាងនោះឡើយ។

ប៉ុន្តែ យើងអាចដឹងច្បាស់ថា ផ្កាយនោះកំពុងតែធ្វើការអ្វីដែលវាមិនអាចធ្វើដោយខ្លួនឯងបាន គឺការនាំផ្លូវពួកហោរាឆ្ពោះទៅរកព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យពួកគេថ្វាយបង្គំព្រះអង្គ។

នៅក្នុងការគិតតាមបែបព្រះគម្ពីរ នោះមានតែព្រះទេដែល អាចនៅពីក្រោយ ការកំណត់គោលបំណង សម្រាប់ផ្កាយទាំងឡាយ។

ដូចនេះ តាមមេរៀននេះ យើងអាចដឹងច្បាស់ថា កាលនោះព្រះទ្រង់កំពុងតែនាំផ្លូវជនបរទេសទាំងនោះ ទៅរកព្រះគ្រីស្ទ ដើម្បីថ្វាយបង្គំព្រះអង្គ។ ហើយព្រះអង្គកំពុងតែនាំផ្លូវពួកគេ ដោយបញ្ចេញនូវឥទ្ធិពល និងអំណាច មកលើពិភពលោក ព្រមទាំងចក្រវាលទាំងមូល ដើម្បីឲ្យការនេះអាចសម្រេចទៅបាន។

កណ្ឌគម្ពីរលូកាបានបង្ហាញថា ព្រះទ្រង់កំពុងបញ្ចេញឥទ្ធិពលមកលើចក្រភពរ៉ូម៉ាំងទាំងមូល ដើម្បីឲ្យការធ្វើជំរឿនប្រជាជនកើតឡើង ចំពេលដែលស្ត្រីព្រហ្មចារីដ៏តូចទាប ត្រូវធ្វើដំណើរទៅភូមិបេថ្លេហិម ដើម្បីសម្រេចបទទំនាយ តាមរយៈការប្រសូតបុត្ររបស់នាង។ កណ្ឌគម្ពីរម៉ាថាយវិញ បានបង្ហាញថា ព្រះអង្គកំពុងប្រើឥទ្ធិពលមកលើផ្កាយ នៅលើមេឃ ដើម្បីនាំជនបរទេសមួយក្រុមតូច ទៅភូមិបេថ្លេហិម ដើម្បីឲ្យពួកគេអាចថ្វាយបង្គំព្រះរាជបុត្រានៃព្រះ។

នេះជាការរៀបចំរបស់ព្រះ។ ព្រះអង្គបានធ្វើការនេះកាលពី

មុន។ ព្រះអង្គនៅតែធ្វើការអស្ចារ្យដូចនេះ ក្នុងពេលបច្ចុប្បន្ន។ គោលបំណងរបស់ព្រះអង្គ គឺដើម្បីឲ្យប្រជាជាតិទាំងអស់ បានថ្វាយបង្គំព្រះរាជបុត្រាព្រះអង្គ (ម៉ាថាយ ២៤:១៤)។

នេះជាបំណងព្រះទ័យព្រះ សម្រាប់មនុស្សម្នាក់ៗ ក្នុងការិយាល័យ ក្នុងថ្នាក់រៀន ក្នុងតំបន់ដែលអ្នករស់នៅ និងក្នុងផ្ទះអ្នក។ គឺដូចដែលកណ្ឌគម្ពីរ យ៉ូហាន ៤:២៣ បានចែងថា «ព្រះវរបិតា ទ្រង់រកពួកអ្នកយ៉ាងនោះ ឲ្យបានថ្វាយបង្គំទ្រង់»។

នៅដើមដំបូងនៃកណ្ឌគម្ពីរម៉ាថាយ យើងនៅតែឃើញគំរូនៃ «ការមកមើល»។ តែនៅចុងបញ្ចប់ យើងឃើញគំរូនៃ «ការទៅប្រាប់»។ បានសេចក្ដីថា ពួកហោរាមកមើលព្រះអង្គ ហើយយើងវិញ ត្រូវទៅប្រាប់គេ។

ប៉ុន្តែ អ្វីដែលមិនខុសប្លែកនោះ គឺគោលបំណង និងអំណាចចេស្ដារបស់ព្រះ នៅក្នុងការប្រមូលប្រជាជាតិទាំងឡាយ ឲ្យមកថ្វាយបង្គំព្រះអង្គ។ ការលើកតម្កើងព្រះគ្រីស្ទ ក្នុងការថ្វាយបង្គំដ៏ឆេះឆួលនៃជាតិសាសន៍ទាំងអស់ គឺជាមូលហេតុដែលព្រះអង្គបានបង្កើតពិភពលោកឲ្យមានឡើង។

# ថ្ងៃទី៩

*កាលស្ដេច ហេរ៉ូឌ បានឮ នោះទ្រង់មានសេចក្ដីវិតក្កព្រួយ ព្រមទាំងពួកអ្នកនៅក្រុងយេរូសាឡឹមទាំងអស់គ្នាផង។*

ម៉ាថាយ ២:៣

ថ្ងៃទី៩

# ការប្រឆាំងពីរយ៉ាងដែលព្រះយេស៊ូវជួប

ព្រះយេស៊ូវកំពុងតែធ្វើឲ្យមនុស្សដែលមិនចង់ថ្វាយបង្គំព្រះអង្គ មានការព្រួយបារម្ភ ហើយព្រះអង្គបណ្តាលឲ្យមានការប្រឆាំង មកលើអ្នកដែលថ្វាយបង្គំព្រះអង្គ។ គេជឿថា ចំណុចនេះមិនមែនជាចំណុចសំខាន់ជាងគេ ក្នុងកណ្ឌគម្ពីរម៉ាថាយនោះទេ ប៉ុន្តែ ជាបញ្ហាដែលមិនអាចជៀសរួច ខណៈពេលដែលសាច់រឿងបន្តទៅមុខទៀត។

ក្នុងរឿងនេះ មានមនុស្សពីរប្រភេទ ដែលមិនចង់ថ្វាយបង្គំព្រះយេស៊ូវ។

មនុស្សប្រភេទទី១ ជាមនុស្សដែលគ្រាន់តែមិនបានបង្ហាញប្រតិកម្មអ្វីសោះ ចំពោះព្រះយេស៊ូវ។ ព្រះអង្គ មិនមានចំណុច

ដែលពួកគេយកចិត្តទុកដាក់ ក្នុងជីវិតរបស់ពួកគេឡើយ។ នៅដើមដំបូងនៃព្រះជន្មព្រះយេស៊ូវ នៅលើផែនដី ពួកសង្គ្រាជ និងពួកអាចារ្យ គឺជាតំណាងឲ្យក្រុមមួយនេះ។ កណ្ឌគម្ពីរ ម៉ាថាយ ២:៤ បានចែងថា “កាលបានប្រជុំពួកសង្គ្រាជ និងពួកអាចារ្យនៃបណ្ដាជនមកសាកសួរពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវប្រសូតនៅឯណា”។ ដូចនេះ ពួកគេក៏បានទូលស្ដេច ហេរ៉ូឌ ហើយក៏បានវិលត្រឡប់ទៅរកការរស់នៅជាធម្មតាទៀត។ ភាពស្ងាត់ស្ងៀម និងភាពអសកម្មរបស់ពួកអ្នកដឹកនាំទាំងនោះ គឺពិតជាលើសលុបណាស់ បើយើងគិតដល់ ទំហំនៃការអ្វីដែលកំពុងតែកើតឡើង។

ហើយយើងក៏ត្រូវកត់សម្គាល់កណ្ឌគម្ពីរ ម៉ាថាយ ២:៣ ដែលបានចែងថា “កាលស្ដេច ហេរ៉ូឌ បានឮ នោះទ្រង់មានសេចក្ដីវិតក្កព្រួយ ព្រមទាំងពួកអ្នកនៅក្រុងយេរូសាឡឹមទាំងអស់គ្នាផង”។ ត្រង់ចំណុចនេះ អាចនិយាយបានម្យ៉ាងទៀតថា កាលនោះ មានពាក្យចចាមអារ៉ាមថា ព្រះមេស្ស៊ីបានចាប់កំណើតហើយ។ ការដែលពួកសង្គ្រាជគ្មានប្រតិកម្មអ្វីសោះ គឺជាចំណុចដែលគួរឲ្យភ្ញាក់ផ្អើលណាស់។ ហេតុអ្វីពួកគេមិនទៅរកព្រះអង្គ ជាមួយពួកហោរាទាំងបី? ពួកគេមិនចាប់អារម្មណ៍

ទេ។ ពួកគេមិនមានចិត្តឆេះឆួល នៅក្នុងការទៅរកព្រះរាជបុត្រា នៃព្រះ ហើយថ្វាយបង្គំព្រះអង្គនោះទ្បើយ។

មនុស្សប្រភេទទី២ ដែលមិនចង់ថ្វាយបង្គំព្រះយេស៊ូវ ជាប្រភេទមនុស្សដែលមានអារម្មណ៍ថា ព្រះអង្គកំពុងមានការគំរាមកំហែងយ៉ាងខ្លាំងមកលើពួកគេ។ ក្នុងរឿងនេះ ស្តេចហេរ៉ូឌ ស្ថិតក្នុងចំណោមមនុស្សប្រភេទនេះឯង។ ស្តេចអង្គនេះពិតជាមានការភ័យខ្លាច គឺខ្លាចយ៉ាងខ្លាំងបានជាទ្រង់រៀបចំគម្រោង និងការភូតកុហក ហើយក៏បានធ្វើការសម្លាប់រង្គាលទារកជាច្រើន ដើម្បីកំចាត់ព្រះយេស៊ូវ។

ដូចនេះ ការប្រឆាំងទាំងពីរប្រភេទនេះ ដែលនឹងកើតមានចំពោះព្រះគ្រីស្ទ និងអ្នកថ្វាយបង្គំរបស់ទ្រង់ គឺការមិនខ្វល់អំពីទ្រង់ និងទាស់ប្រឆាំងនឹងទ្រង់។ ខ្ញុំពិតជាសង្ឃឹមថា អ្នកមិនស្ថិតក្នុងក្រុមណាមួយទេ។

ហើយបើអ្នកជាគ្រីស្ទបរិស័ទ សូមឲ្យថ្ងៃបុណ្យណូអែលបានធ្វើជាពេលដែលអ្នកជញ្ជឹងគិត អំពីអត្ថន័យ ឬការលះបង់ដែលយើងត្រូវមាន ដើម្បីថ្វាយបង្គំ និងដើរតាមព្រះមេស្ស៊ី។

# ថ្ងៃទី១០

*គេមានសេចក្ដីអំណរជាខ្លាំងក្រៃ ដោយឃើញផ្កាយ
នោះ ហើយក៏ចូលទៅក្នុងផ្ទះ ឃើញបុត្រតូច នៅជា
មួយនឹងម៉ារា ជាមាតា រួចក៏ក្រាបថ្វាយបង្គំ ព្រមទាំង
បើកយកទ្រព្យដ៏វិសេសរបស់ខ្លួន ថ្វាយដង្វាយជា
មាស ជាកំញាន ជាជ័រល្វីងទេស ដល់បុត្រនោះ។*

ម៉ាថាយ ២:១០-១១

ថ្ងៃទី១០

# ដង្វាយជាមាស កំញាន និងជ័រល្វីងទេស

ដៃរបស់មនុស្សធ្វើការបម្រើព្រះ មិនមែនដោយសារព្រះអង្គត្រូវការអ្វីមួយនោះទេ (កិច្ចការ ១៧:២៥)។ ពួកហោរាបានថ្វាយដង្វាយដល់ព្រះអង្គ មិនមែនដើម្បីផ្ដល់ជំនួយ ឬបំពេញតម្រូវការរបស់ព្រះអង្គឡើយ។ ក្សត្រនឹងបាត់បង់ព្រះកិត្តិនាម បើសិនជាភ្ញៀវបរទេសដែលមកទស្សនកិច្ច នាំយកកញ្ចប់ជំនួយមកថ្វាយទ្រង់។

អំណោយទាំងនេះក៏មិនមែនដើម្បីសូកប៉ាន់ដែរ។ កណ្ឌគម្ពីរ ចោទិយកថា ១០:១៧ បានចែងថា ព្រះទ្រង់មិនដែលទទួលសំណូកទេ។ តើការថ្វាយដង្វាយនោះមានន័យដូចម្ដេច? តើការថ្វាយដង្វាយនោះ បានបង្ហាញនូវការថ្វាយបង្គំដល់ព្រះអង្គយ៉ាងណាខ្លះ?

អំណោយដែលបានជូនដល់អ្នកមាន ឬមនុស្សដែលមានគ្រប់គ្រាន់ គឺបានឆ្លុះបញ្ចាំង និងធ្វើឲ្យបំណងចិត្តរបស់លោកអ្នកកាន់តែខ្លាំងឡើង គឺបំណងចិត្តដែលចង់បង្ហាញថា ពួកគេមានភាពអស្ចារ្យយ៉ាងណាចំពោះលោកអ្នក។ គេអាចបកស្រាយថា ការថ្វាយដង្វាយដល់ព្រះគ្រីស្ទ គឺប្រៀបដូចជាការអធិស្ឋានតម ដែលជាការតមអត់អ្វីមួយ ដើម្បីបង្ហាញថា ព្រះគ្រីស្ទមានតម្លៃលើសអ្វីៗដែលអ្នកអាចលះបង់។

ពេលដែលអ្នកថ្វាយដង្វាយដល់ព្រះគ្រីស្ទ យ៉ាងដូចនេះ គឺដូចជាការទូលព្រះអង្គថា “ក្តីអំណរដែលទូលបង្គំបានដេញតាម គឺមិនមែនជាការសង្ឃឹមថា នឹងក្លាយជាអ្នកមាន ដោយការដោះដូរឲ្យបានអ្វីមួយពីព្រះអង្គ ឬដោយការចរចា អំពីប្រាក់កំរៃអ្វីមួយនោះទេ[សូមកត់សម្គាល់កណ្ឌគម្ពីរ ម៉ាថាយ ២:១០ ដែលបានចែងថា “គេមានសេចក្តីអំណរជាខ្លាំងក្រៃ ដោយឃើញផ្កាយនោះ”។ ទូលបង្គំបានមករកព្រះអង្គ មិនមែនដើម្បីឲ្យបាន*អ្វីមួយពី*ព្រះអង្គ តែ*ដើម្បីព្រះអង្គ*។ ហើយបំណងចិត្តទូលបង្គំកាន់តែមានភាពខ្លាំងក្លា និងបានបង្ហាញចេញមកដោយការលះបង់*អ្វីៗ* ដោយសង្ឃឹមថា នឹងមានអំណរចំពោះព្រះអង្គកាន់តែខ្លាំងឡើង។ ពេលណាទូលបង្គំថ្វាយដល់ព្រះ

អង្គ នូវអ្វីដែលព្រះអង្គមិនត្រូវការ និងអ្វីដែលទូលបង្គំអាចអរសប្បាយ នោះមានន័យថា ទូលបង្គំកំពុងតែទូលថ្វាយ ដោយចិត្តកាន់តែឆេះឆួល និងពិតត្រង់ថា «របស់ទាំងនេះមិនមែនជាកំណប់ទ្រព្យទូលបង្គំឡើយ គឺព្រះអង្គទេ ដែលជាកំណប់ទ្រព្យរបស់ទូលបង្គំ»។

ខ្ញុំគិតថា នេះហើយជាអត្ថន័យនៃការថ្វាយបង្គំព្រះ ដោយអំណោយជាមាស កំញាន និងជ័រល្វីងទេស។ ឬជង្វាយអ្វីក៏ដោយដែលយើងចង់ថ្វាយដល់ព្រះ។

សូមព្រះទ្រង់ដាស់ចិត្តយើង ឲ្យប្រាថ្នាចង់ស្វែងរកព្រះគ្រីស្ទ។ សូមយើងនិយាយចេញពីចិត្តថា «ឱព្រះអម្ចាស់យេស៊ូវ ព្រះអង្គជាព្រះមេស្ស៊ី ជាស្តេចនៃសាសន៍អ៊ីស្រាអែល។ ប្រជាជាតិទាំងអស់នឹងមកក្រាបនៅចំពោះព្រះអង្គ។ ព្រះទ្រង់បានប្រើពិភពលោក ដើម្បីឲ្យគេថ្វាយបង្គំព្រះអង្គ។ ដូចនេះទោះទូលបង្គំនឹងជួបការប្រឆាំងអ្វីក៏ដោយ ទូលបង្គំសូមប្រកាសដោយអំណរថា សិទ្ធិអំណាច និងភាពថ្លៃថ្នូរជាកម្មសិទ្ធិរបស់ព្រះអង្គ ហើយសូមថ្វាយជង្វាយ ដើម្បីថ្លែងថា មានតែព្រះអង្គទេ ដែលអាចធ្វើឲ្យចិត្តទូលបង្គំស្កប់ស្កល់»។

# ថ្ងៃទី១១

*ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ ដើម្បីឲ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្ដីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ហើយឲ្យបានប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវបម្រើគ្រប់១ជីវិត ដោយខ្លាចស្លាប់ ឲ្យបានរួចចេញវិញ។*

ហេព្រើរ ២:១៤-១៥

ថ្ងៃទី១១

# មូលហេតុដែលព្រះយេស៊ូវ បានយាងចុះមក

ខ្ញុំយល់ឃើញថា កណ្ឌគម្ពីរ ហេព្រើរ ២:១៤-១៥ ជាកណ្ឌគម្ពីរ សម្រាប់រដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល ដែលខ្ញុំចូលចិត្តជាងគេ ព្រោះខ្ញុំមិនដឹងថា មានកណ្ឌគម្ពីរណាទៀត ដែលបានបង្ហាញច្បាស់ជាងខគម្ពីរនេះ អំពីទំនាក់ទំនងរវាងការចាប់ផ្ដើម និងចុងបញ្ចប់នៃព្រះជន្មរបស់ព្រះយេស៊ូវនៅលើផែនដី ពោលគឺទំនាក់ទំនងរវាងការប្រសូត និងការសុគតនៅលើឈើឆ្កាងរបស់ព្រះគ្រីស្ទ។ ខគម្ពីរទាំងពីរនេះបានបកស្រាយយ៉ាងច្បាស់ អំពីមូលហេតុដែលព្រះយេស៊ូវបានយាងចុះមកផែនដី និយាយឲ្យចំ គឺយាងមកសុគត។ វាជាការប្រសើរណាស់ ដែលយើងប្រើ

កណ្ឌគម្ពីរនេះ ជាមួយមិត្តភក្តិ ឬសមាជិកគ្រួសារដែលមិនទាន់ជឿព្រះ ដើម្បីនាំពួកគេស្វែងយល់ម្តងមួយជំហានៗ អំពីទស្សនៈ បែបគ្រីស្ទបរិស័ទ ដែលអ្នកមានចំពោះពិធីបុណ្យណូអែល។ អ្នកអាចអនុវត្តន៍យ៉ាងដូចនេះ ម្តងមួយឃ្លាៗ ដូចតទៅ៖

ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា...

ពាក្យ “កូនចៅ” ដែលគេបានដកស្រង់ពីខមុន (ហេព្រើរ ២:១៣) សំដៅទៅលើកូនចៅខាងឯវិញ្ញាណរបស់ព្រះគ្រីស្ទ ដែលជាព្រះមេស្ស៊ី (មើលអេសាយ ៨:១៨; ៥៣:១០)។ កូនចៅក៏ជា “កូនរបស់ព្រះ” (យ៉ូហាន ១:១២)។ អាចនិយាយម៉្យាងទៀតថា ពេលដែលព្រះទ្រង់ចាត់ព្រះគ្រីស្ទឲ្យយាងចុះមក ទ្រង់បានគិតដល់សេចក្តីសង្គ្រោះរបស់ “កូនៗទ្រង់” ជាពិសេស។

ជាការពិតណាស់ “ព្រះទ្រង់ស្រឡាញ់*មនុស្សលោកដល់ម្ល៉េះ* បានជាទ្រង់ប្រទានព្រះយេស៊ូវ]” (យ៉ូហាន ៣:១៦)។ តែវាក៏ជាការពិតផងដែរ ដែលថា ព្រះទ្រង់បានប្រមូល “អស់ទាំងកូននៃព្រះ ដែលបានខ្ចាត់ខ្ចាយ” នៅក្រៅប្រទេស *ជាពិសេស*

(យ៉ូហាន ១១:៥២)។ ការរៀបចំរបស់ព្រះ គឺដើម្បី*ប្រទាន*ព្រះគ្រីស្ទ ដល់លោកីយ៍ និងដើម្បី*សម្រេច*នូវសេចក្តីសង្គ្រោះសម្រាប់កូនទ្រង់ (សូមមើល ១ធីម៉ូថេ ៤:១០)។ អ្នកអាចពិសោធន៍នឹងការទទួលចិញ្ចឹមជាកូន ដោយទទួលជឿព្រះគ្រីស្ទ (យ៉ូហាន ១:១២)។

...នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ...

ត្រង់ចំណុចនេះ បានសេចក្តីថា ព្រះគ្រីស្ទមានព្រះវត្តមាន តាំងពីមុនព្រះអង្គចាប់កំណើតជាមនុស្ស។ ព្រះអង្គជាវិញ្ញាណ។ ព្រះអង្គជាព្រះបន្ទូលដ៏អស់កល្ប។ ព្រះអង្គគង់នៅជាមួយព្រះ ហើយព្រះអង្គជាព្រះ (យ៉ូហាន ១:១ និងកូឡុស ២:៩)។ ប៉ុន្តែ ព្រះអង្គបានយកកំណើតជាសាច់ និងឈាម ហើយបានគ្របដណ្តប់ពីលើភាពជាព្រះរបស់ទ្រង់ ដោយភាពជាមនុស្សរបស់ព្រះអង្គ។ ព្រះអង្គបានក្លាយជាមនុស្សទាំងស្រុង ហើយនៅមានលក្ខណៈជាព្រះទាំងស្រុង។ នេះជារឿងអាថ៌កំបាំងដ៏អស្ចារ្យ ក្នុងន័យជាច្រើន។ ប៉ុន្តែ រឿងនេះស្ថិតនៅក្នុងចំណុចស្នូលនៃជំនឿរបស់យើង និងជាអ្វីដែលព្រះគម្ពីរបានបង្រៀន។

...ដោយទ្រង់សុគត...

ក្នុងការសុគត ព្រះគ្រីស្ទបានកាច់បំបាក់ចង្កូមរបស់អារក្ស។ តើដោយរបៀបណា? គឺដោយគ្របបាំងបាបរបស់យើង។ ការនេះគឺមានន័យថា សាតាំងមិនមានមូលដ្ឋានផ្អែកក្រឹត្យវិន័យដើម្បីចោទប្រកាន់យើង នៅចំពោះព្រះនោះឡើយ។ “តើអ្នកណានឹងចោទប្តឹងពីពួករើសតាំងរបស់ព្រះបាន ដ្បិតគឺជាព្រះហើយ ដែលទ្រង់រាប់គេជាសុចរិត” (រ៉ូម ៨:៣៣)។ តើព្រះអង្គរាប់យើងជាសុចរិត ដោយផ្អែកទៅលើអ្វី? គឺតាមរយៈព្រះលោហិតនៃព្រះយេស៊ូវ (រ៉ូម ៥:៩)។

បាបរបស់យើង គឺជាអាវុធសាហាវបំផុត ដែលសាតាំងប្រើដើម្បីទាស់ប្រឆាំងនឹងយើង។ បើការសុគតរបស់ព្រះយេស៊ូវបានដកបាបយើងចេញ នោះព្រះអង្គក៏បានដកអាវុធសំខាន់បំផុត គឺសេចក្តីស្លាប់ ចេញពីដៃសាតាំងផងដែរ។ វាមិនអាចធ្វើការប្តឹង ដើម្បីដាក់ទោសឲ្យយើងស្លាប់ឡើយ ព្រោះព្រះដ៏ជាចៅក្រមបានឲ្យយើងរួចទោស ដោយសារការសុគតរបស់ព្រះរាជបុត្រាព្រះអង្គ។

...ដើម្បីឲ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្ដីស្លាប់ គឺជាអារក្ស...

មូលហេតុដែលទ្រង់យកកំណើតជាមនុស្ស គឺដើម្បីសុគត។ ក្នុងលក្ខណៈជាព្រះដែលបរិសុទ្ធ និងសាមញ្ញ ព្រះអង្គមិនអាចសុគតសម្រាប់មនុស្សមានបាបបានឡើយ។ ប៉ុន្ដែ ក្នុងនាមជាមនុស្ស ព្រះអង្គអាចសុគត។ គោលបំណងរបស់ព្រះអង្គ គឺដើម្បីសុគត។ ដូចនេះ ព្រះអង្គត្រូវតែចាប់កំណើតជាមនុស្ស។ ព្រះអង្គបានប្រសូត ដើម្បីសុគត។ ថ្ងៃសុក្រដ៏ល្អ (ថ្ងៃទ្រង់សុគត) គឺជាគោលបំណងនៃបុណ្យណូអែល។ នេះជាអត្ថន័យនៃបុណ្យណូអែល ដែលមនុស្សភាគច្រើនចាំបាច់ត្រូវរំឭ ក្នុងពេលសព្វថ្ងៃ។

...ហើយឲ្យបានប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវបម្រើ គ្រប់១ជីវិត ដោយខ្លាចស្លាប់ ឲ្យបានរួចចេញវិញ។

ដូចនេះ យើងមានសេរីភាពរួចផុតពីការ*ភ័យខ្លាច*សេចក្ដីស្លាប់។ ព្រះទ្រង់បានរាប់យើងជាសុចរិត។ សាតាំងមិនអាច

កែប្រែព្រះរាជក្រឹត្យរបស់ព្រះអង្គបានឡើយ។ ហើយព្រះទ្រង់សព្វព្រះទ័យឲ្យសុវត្ថិភាព*ដ៏ល្អបំផុត* កើតមាន*ភ្លាមៗ* មកលើជីវិតយើង។ ព្រះអង្គសព្វព្រះទ័យឲ្យយើងមានចុងបញ្ចប់ដ៏មានអំណរ ដោយដកភាពជាទាសករ និងការភ័យខ្លាច ក្នុងពេលបច្ចុប្បន្ន។

បើយើងមិនចាំបាច់ត្រូវភ័យខ្លាចសេចក្ដីស្លាប់ ដែលជាខ្មាំងសត្រូវចុងក្រោយ និងធំបំផុតរបស់យើង នោះយើងមិនចាំបាច់ត្រូវភ័យខ្លាចអ្វីផ្សេងទៀតឡើយ។ យើងអាចមានសេរីភាព។ មានសេរីភាពនៅក្នុងការអរសប្បាយ។ សេរីភាពសម្រាប់អ្នកដទៃ។

នេះជាអំណោយថ្ងៃណូអែលដ៏អស្ចារ្យ ដែលព្រះទ្រង់ប្រទានមកយើង! ហើយយើងចែករំលែកដល់លោកីយ៍!

# ថ្ងៃទី១២

*រីឯដែលបង្រួមសេចក្តីអធិប្បាយទាំងប៉ុន្មានអម្បាញ់មិញ
នេះ នោះគឺថា យើងរាល់គ្នាមានសម្តេចសង្ឃ១អង្គយ៉ាងនោះ
ដែលទ្រង់បានគង់ខាងស្តាំបល្ល័ង្កនៃឫទ្ធានុភាពនៅស្ថានសួគ៌
ជាអ្នកមានការងារក្នុងទីបរិសុទ្ធ ហើយក្នុងរោងឧបោសថដ៏
ពិត ដែលព្រះអម្ចាស់បានដំឡើង មិនមែនជាមនុស្សទេ។*

ហេព្រើរ ៨:១-២

ថ្ងៃទី១២

# ការជំនួសស្រមោល

ខ្លឹមសារនៃកណ្ដាលគម្ពីរហេព្រើរ គឺបានបង្ហាញថា ព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ មិនគ្រាន់តែបានយាងចុះមក ដើម្បីចូលទៅក្នុងប្រព័ន្ធនៃការងាររបស់ពួកសង្ឃ ក្នុងលោកីយ៍ ក្នុងនាមសង្ឃជាមនុស្ស ដែលល្អបំផុត និងចុងក្រោយ តែក៏ដើម្បីបំពេញ និងបញ្ចប់ប្រព័ន្ធនេះ ហើយនាំយើងឲ្យងាកបែរទៅរកព្រះអង្គ ដោយព្រះអង្គបានធ្វើសម្រាប់យើងជាដំបូងនៅកាល់វ៉ារី ក្នុងនាមជាយញ្ញបូជាលោះបាបចុងក្រោយ ហើយបន្ទាប់មក ក្នុងនគរស្ថានសួគ៌ ក្នុងនាមជាសង្ឃចុងក្រោយរបស់យើង។

រោងឧបោសថ ពួកសង្ឃ និងយញ្ញបូជានៅគ្រាសញ្ញាចាស់ គឺជាស្រមោល។ ឥឡូវនេះ ការពិតបានលេចមក ហើយ

ស្រមោលក៏បានកន្លងផុតទៅ។

ខាងក្រោមនេះ ខ្ញុំសូមលើកយកឧទាហរណ៍ពន្យល់ អំពីរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល សម្រាប់កុមារ និងអ្នកដែលបានឆ្លងកាត់វ័យកុមារ ហើយនឹកចាំថា កុមារភាពមានលក្ខណៈដូចម្ដេច។ ឧបមាថា កាលពីក្មេង អ្នកបានវង្វេងចេញពីម្ដាយរបស់អ្នក ក្នុងហាងលក់ទំនិញ ហើយអ្នកក៏បានចាប់ផ្ដើមមានការភ័យខ្លាច និងតក់ស្លុត ហើយមិនដឹងថា ត្រូវទៅតាមផ្លូវណាទេ ហើយអ្នកក៏បានរត់ទៅចុងផ្លូវដើរនៅចន្លោះធ្នើរដាក់អីវ៉ាន់ ក្នុងហាង ហើយមុនពេលអ្នកចាប់ផ្ដើមយំ អ្នកក៏បានឃើញស្រមោលនៅលើកម្រាលឥដ្ឋ នៅចុងផ្លូវដើរចន្លោះធ្នើរដាក់អីវ៉ាន់ ដែលមានរូបរាងដូចម្ដាយរបស់អ្នក។ អ្នកក៏មានសង្ឃឹមឡើង។ ប៉ុន្តែ តើមួយណាល្អជាង? តើការមានសង្ឃឹមដោយសារការបានឃើញស្រមោល ឬការបានឃើញម្ដាយរបស់អ្នកដើរនៅកៀនជ្រុងធ្នើរដាក់អីវ៉ាន់ យ៉ាងពិតប្រាកដ?

ការដែលព្រះយេស៊ូវបានយាងមកធ្វើជាសម្ដេចសង្ឃរបស់យើង ក៏មានលក្ខណៈដូចនេះផងដែរ។ នេះជាអត្ថន័យនៃថ្ងៃណូអែល។ ថ្ងៃណូអែលគឺជាការជំនួសស្រមោល ដោយរបស់ពិត គឺដូចជាក្ដីអំណរ និងភាពធូរស្បើយ ដែលក្មេងតូចនោះ

បានទទួល ពេលដែលបានឃើញម្ដាយបានដើរនៅក្បែរកៀនជ្រុងនៃធ្នើរដាក់អីវ៉ាន់។

(សម្រាប់ការស្វែងយល់បន្ថែម អំពីការយាងមកនៃព្រះគ្រីស្ទ ដែលជំនួសឲ្យសេចក្ដីសញ្ញាចាស់ សូមមើលទំព័រសេចក្ដីបន្ថែម នៅទំព័រចុងក្រោយនៃសៀវភៅនេះ)

# ថ្ងៃទី១៣

*រីឯដែលបង្រួមសេចក្តីអធិប្បាយទាំងប៉ុន្មានអម្បាញ់មិញ*
*នេះ នោះគឺថា យើងរាល់គ្នាមានសម្តេចសង្ឃ១អង្គយ៉ាង*
*នោះ ដែលទ្រង់បានគង់ខាងស្តាំបល្ល័ង្កនៃឫទ្ធានុភាពនៅ*
*ស្ថានសួគ៌ ជាអ្នកមានការងារក្នុងទីបរិសុទ្ធ ហើយក្នុងពាង*
*ឧបោសថដ៏ពិត ដែលព្រះអម្ចាស់បានដំឡើង មិនមែនជា*
*មនុស្សទេ...ដែលគេជាគំរូ ហើយជាស្រមោល ពីរបស់នៅ*
*ស្ថានសួគ៌វិញ ដូចជាព្រះបានបង្គាប់លោក ម៉ូសេ ក្នុងកាល*
*ដែលលោករៀបនឹងធ្វើពាងឧបោសថថា «ចូរប្រយ័ត្ននឹងធ្វើ*
*គ្រប់ទាំងអស់ តាមគំរូដែលអញបានបង្ហាញឯងនៅលើភ្នំ»*

ហេព្រើរ ៨:១-២,៥

ថ្ងៃទី១៣

# ការពិតចុងក្រោយបាន បើកសម្ដែងហើយ

យើងបានយល់នូវអត្ថន័យនៃថ្ងៃណូអែល ក្នុងអត្ថបទមុន។ តែនៅមានអត្ថន័យលើសនោះទៀត។ ថ្ងៃណូអែលជាការជំនួសស្រមោល ដោយអ្វីដែលពិត។

កណ្ឌគម្ពីរ ហេព្រើរ ៨:១-២, ៥ ជាសេចក្ដីថ្លែងសង្ខេបមួយបែប។ ចំណុចសំខាន់នៃកណ្ឌគម្ពីរនេះ គឺថា សង្ឃមួយអង្គដែលធ្វើជាបុគ្គលកណ្ដាល រវាងយើង និងព្រះ ហើយបានផ្សះផ្សាយើងឲ្យជានឹងព្រះ ព្រមទាំងបានអធិស្ឋានឲ្យយើងមិនមែនជាពួកសង្ឃធម្មតា ទន់ខ្សោយ មានបាប និងស្លាប់ក្នុងគ្រាសញ្ញាចាស់នោះទេ។ ទ្រង់ជាព្រះរាជបុត្រានៃព្រះ មានព្រះជន្មដ៏រឹងមាំ គ្មានបាប និងគ្មានអ្វីអាចបំផ្លាញបាន។

មិនតែប៉ុណ្ណោះ ព្រះអង្គមិនបានធ្វើការក្នុងរោងឧបោសថនៅផែនដី ជាទីកន្លែង និងមានទំហំ មានដែនកំណត់ ដែលអាចពុកផុយ និងត្រូវសត្វកណ្ដៀរស៊ី ហើយសើម និងឆេះ ព្រមទាំងអាចរហែក និងត្រូវចោរលួចនោះទេ។ ផ្ទុយទៅវិញ កណ្ឌគម្ពីរ ហេព្រើរ ៨:២ បានចែងថា ព្រះគ្រីស្ទកំពុងតែធ្វើការក្នុងរោងឧបោសថ ដែលព្រះទ្រង់បានតម្កើងឡើង មិនមែនមនុស្សនោះទេ។ នេះមិនមែនជាស្រមោល តែជាអ្វីដែលពិត ក្នុងនគរស្ថានសួគ៌។ នេះជាការពិត ដែលបានបញ្ចេញស្រមោលនៅលើភ្នំស៊ីណាយ សម្រាប់ឲ្យលោក ម៉ូសេ ចម្លងក្រឹត្យវិន័យ។

តាមកណ្ឌគម្ពីរ ហេព្រើរ ៨:១ ភាពអស្ចារ្យមួយទៀត អំពីការពិតដែលធំជាងស្រមោល នោះគឺថា សម្ដេចសង្ឃនៃយើងកំពុងគង់នៅខាងស្ដាំដៃនៃព្រះដ៏មានចេស្ដានៅស្ថានសួគ៌។ គ្មានពួកសង្ឃមួយណា នៅគ្រាសញ្ញាចាស់ ដែលអាចនិយាយដូចនេះបានឡើយ។

ព្រះយេស៊ូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយព្រះ ដ៏ជាព្រះវរបិតា។ ព្រះអង្គមានកន្លែងកិត្តិយស នៅក្បែរព្រះវរបិតា។ ព្រះវរបិតាស្រឡាញ់ និងគោរពទ្រង់ ដោយគ្មានដែនកំណត់។ ព្រះអង្គគង់នៅជាមួយព្រះវរបិតាជានិច្ច។ នេះមិនមែនជាស្រមោល

នៃការពិត ដែលមានដូចជាវាំងនន និងផើង តុ ទៀន អាវវែង រំយោល ចៀម ពពែ និងសត្វព្រាបនោះទេ។ ការពិតចុងក្រោយនោះ គឺបង្ហាញថា ព្រះវរបិតា និងព្រះរាជបុត្រាព្រះអង្គមានទំនាក់ទំនងជាមួយគ្នា ក្នុងសេចក្តីស្រឡាញ់ និងសេចក្តីបរិសុទ្ធ ដើម្បីសេចក្តីសង្គ្រោះដ៏អស់កល្បរបស់យើង។

ការពិតចុងក្រោយនោះក៏បានបង្ហាញផងដែរថា អង្គទាំងបីនៃព្រះត្រៃឯក មានទំនាក់ទំនងជាមួយគ្នា ដោយព្រមព្រៀងគ្នា អំពីរបៀបដែលព្រះចេស្តា ភាពបរិសុទ្ធ សេចក្តីស្រឡាញ់ យុត្តិធម៌ សេចក្តីល្អ និងសេចក្តីពិតរបស់ទ្រង់ បង្ហាញចេញមក ក្នុងរាស្ត្រដែលបានប្រោសលោះ។

# ថ្ងៃទី១៤

*តែឥឡូវនេះវិញ ដែលទ្រង់ជាអ្នកកណ្ដាលរបស់សេចក្ដី
សញ្ញា១ដ៏ប្រសើរជាងប៉ុណ្ណា ដែលសេចក្ដីសញ្ញានោះ
បានតាំងឡើង លើពាក្យសន្យាប្រសើរជាងផង នោះ
ទ្រង់ក៏បានទទួលការងារដ៏ប្រសើរជាងប៉ុណ្ណោះដែរ។*

ហេព្រើរ ៨:៦

ថ្ងៃទី១៤

# បង្ហាញការពិតឲ្យរាស្ត្រទ្រង់បានស្គាល់

តាមកណ្ឌគម្ពីរហេព្រើរ ៨:៦ ព្រះគ្រីស្ទជាអ្នកកណ្ដាល នៃសេចក្ដីសញ្ញាថ្មី។ តើការនេះមានន័យដូចម្ដេច? គឺមានន័យថា ទីបំផុត ព្រះលោហិតទ្រង់ ដែលជាព្រះលោហិត នៃសេចក្ដីសញ្ញា (លូកា ២២:២០; ហេព្រើរ ១៣:២០) បាន ទិញ និងធានា នូវការសម្រេចព្រះបន្ទូលសន្យា ដែលព្រះទ្រង់ មានសម្រាប់យើង។

បានសេចក្ដីថា ព្រះទ្រង់បានប្រទាននូវការផ្លាស់ប្រែក្នុង វិញ្ញាណយើង ដោយព្រះវិញ្ញាណនៃព្រះគ្រីស្ទ យោងតាមព្រះ បន្ទូលសន្យានៃសេចក្ដីសញ្ញាថ្មី។

ហើយបានសេចក្ដីថា ព្រះទ្រង់ធ្វើការផ្លាស់ប្រែនេះ ក្នុងយើង តាមរយៈជំនឿរបស់យើង គឺជំនឿលើការអ្វីទាំងអស់ ដែលព្រះ ទ្រង់ធ្វើ និងមានសម្រាប់យើង ក្នុងព្រះគ្រីស្ទ។

សេចក្តីសញ្ញាថ្មីនេះ ត្រូវបានព្រះទ្រង់ទិញដោយ*ព្រះលោហិត*នៃព្រះគ្រីស្ទ ដោយការបណ្តាលឡើងពី*ព្រះវិញ្ញាណ*នៃព្រះគ្រីស្ទ និងមានភាពត្រឹមត្រូវ ដោយសារ*ជំនឿ*លើព្រះគ្រីស្ទ។

កណ្ឌគម្ពីរដែលបានបកស្រាយបានល្អបំផុត អំពីការដែលព្រះគ្រីស្ទធ្វើការជាអ្នកកណ្តាលនៃសេចក្តីសញ្ញាថ្មី គឺកណ្ឌគម្ពីរហេព្រើរ ១៣:២០-២១ ដែលបានចែងថា៖

សូមឲ្យព្រះនៃសេចក្តីសុខសាន្ត ដែលទ្រង់ប្រោសព្រះយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា ឲ្យត្រឡប់ពីពួកស្លាប់មកវិញ គឺជាអ្នកគង្វាលដ៏ធំនៃហ្វូងចៀម ទ្រង់ប្រោសឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ក្នុងការល្អគ្រប់ជំពូកដោយសារព្រះលោហិត នៃសញ្ញាដ៏នៅអស់កល្បជានិច្ច ប្រយោជន៍ឲ្យអ្នករាល់គ្នា បានធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ ដោយទ្រង់ធ្វើការក្នុងអ្នករាល់គ្នា ដែលគាប់ដល់ព្រះហឫទ័យនៃទ្រង់ *ដោយសារព្រះយេស៊ូវគ្រីស្ទ* សូមឲ្យទ្រង់បានសិរីល្អ នៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន។

ពាក្យ “ធ្វើការក្នុងអ្នករាល់គ្នា ដែលគាប់ដល់ព្រះហឫទ័យនៃទ្រង់” គឺបានពិពណ៌នា អំពីអ្វីដែលបានកើតឡើង ពេលដែលព្រះទ្រង់ចារក្រឹត្យវិន័យរបស់ទ្រង់ ពីលើចិត្តយើង តាមសេចក្តី

សញ្ញាថ្មី។ ហើយពាក្យ «ដោយសារព្រះយេស៊ូវគ្រីស្ទ» គឺបានពិពណ៌នាថា ព្រះយេស៊ូវជាអ្នកកណ្ដាល នៃព្រះរាជកិច្ចដ៏រុងរឿងនៃព្រះគុណរបស់ព្រះ ដែលគ្រប់គ្រងលើអ្វីៗទាំងអស់។

ដូចនេះ អត្ថន័យនៃបុណ្យណូអែល គឺមិនគ្រាន់តែនិយាយអំពីការដែលព្រះទ្រង់យកការពិត មកជំនួសស្រមោលប៉ុណ្ណោះទេ តែថែមទាំងបានយកការពិតនោះ មកបង្ហាញឲ្យរាស្ត្រទ្រង់ស្គាល់ផងដែរ។ ព្រះអង្គបានចារសេចក្ដីនោះពីលើចិត្តពួកគេ។ ព្រះអង្គមិនបានយកអំណោយនៃបុណ្យណូអែល ដែលជាសេចក្ដីសង្គ្រោះ និងការផ្លាស់ប្រែ មកទុកនៅក្រោមដើមណូអែល ដើម្បីឲ្យអ្នកទៅរើសយក ដោយពឹងអាងកម្លាំងខ្លួនឯងនោះទេ។ តែព្រះអង្គបានរើសអំណោយនោះឡើង ហើយដាក់វាក្នុងចិត្ត និងគំនិតរបស់អ្នក ហើយបោះត្រាចំណាំ ដើម្បីធានាថា អ្នកគឺជាកូនរបស់ព្រះ។

# ថ្ងៃទី១៥

*ឯចោរ វាមកប្រយោជន៍តែនឹងលួច សម្លាប់ ហើយ បំផ្លាញប៉ុណ្ណោះ តែឯខ្ញុំវិញ ខ្ញុំបានមក ដើម្បីឲ្យវារាល់គ្នាមានជីវិត ហើយឲ្យមានជីវិតនោះពេញបរិបូរផង។*

យ៉ូហាន ១០:១០

ថ្ងៃទី១៥

# ជីវិត និងការស្លាប់នៅថ្ងៃណូអែល

ពេលដែលខ្ញុំហៀបនឹងចាប់ផ្តើមនិពន្ធសៀវភៅ សម្រាប់ប្រកបជាមួយព្រះប្រចាំថ្ងៃនេះ ខ្ញុំបានទទួលដំណឹងថា អ្នកស្រី ម៉ារាន ញូស្រ្តាំ (Marion Newstrum) ទើបតែទទួលមរណៈភាព។ អ្នកស្រី ម៉ារៀន និងស្វាមីរបស់គាត់ គឺលោក អេលមើរ (Elmer) ជាផ្នែកមួយនៃពួកជំនុំរបស់យើងយូរជាងសមាជិកភាគច្រើនក្នុងព្រះវិហាររបស់យើង ដែលនៅមានជីវិតកាលនោះ។ គាត់មានអាយុ៨៧ឆ្នាំ។ ពួកគាត់បានរៀបការបាន៦៤ឆ្នាំហើយ។

ខ្ញុំបានលើកទឹកចិត្តលោក អេលមើរ ដោយប្រាប់គាត់ថា ខ្ញុំចង់ឲ្យគាត់មានភាពរឹងមាំក្នុងព្រះអម្ចាស់ ហើយកុំអស់សង្ឃឹមក្នុងការរស់នៅ។ ពេលនោះគាត់ក៏បាននិយាយថា “ព្រះអង្គគឺជាមិត្តសំឡាញ់ពិត”។ ខ្ញុំសូមអធិស្ឋាន សូមឲ្យគ្រីស្ទបរិស័ទ

ទាំងអស់អាចនិយាយ នៅចុងបញ្ចប់នៃជីវិតថា “ព្រះគ្រីស្ទជាមិត្តសំឡាញ់ពិត”។

រៀងរាល់ពេលរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែលមកដល់ ខ្ញុំតែងតែនឹកចាំអំពីខួបមរណៈភាពរបស់ម្តាយខ្ញុំ។ គាត់បានទៅនៅជាមួយព្រះអង្គ ក្នុងអាយុ៥៦ឆ្នាំ ក្នុងគ្រោះថ្នាក់ឡានក្រុងមួយ នៅប្រទេសអ៊ីស្រាអែល។ គឺនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៤។ ហេតុការណ៍នោះបានដក់ជាប់ក្នុងចិត្តខ្ញុំ រហូតមកដល់ពេលសព្វថ្ងៃនេះ។ បើខ្ញុំមិនគ្រប់គ្រងអារម្មណ៍ខ្លួនឯងទេ នោះខ្ញុំអាចស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន។ ឧទាហរណ៍ៈ ពេលដែលខ្ញុំគិតអំពីការដែលកូនប្រុសខ្ញុំមិនដែលបានស្គាល់គាត់ ជាដើម។ យើងបានបញ្ចុះសពគាត់ នៅថ្ងៃបន្ទាប់ពីថ្ងៃបុណ្យណូអែល។ បុណ្យណូអែលឆ្នាំនោះពិតជាមានតម្លៃចំពោះយើងណាស់!

មនុស្សជាច្រើនមានអារម្មណ៍ថា មានការបាត់បង់ ក្នុងរដូវកាលនៃបុណ្យណូអែលឆ្នាំនេះ ដែលឈឺចាប់ជាងឆ្នាំមុនៗ។ ចូរកុំរាំងខ្ទប់អារម្មណ៍នេះឡើយ។ ចូរបណ្តោយឲ្យវាចេញមក។ ចូរទទួលយកអារម្មណ៍នេះ។ តើយើងមានក្តីស្រឡាញ់ដើម្បីអ្វី បើមិនមែនដើម្បីធ្វើឲ្យមនោសញ្ចេតនារបស់យើងកាន់តែមាន

ភាពជ្រាលជ្រៅ ក្នុងជីវិតនេះ ក៏ដូចជាក្នុងសេចក្តីស្លាប់? ប៉ុន្តែ សូមកុំមានចិត្តជូរល្វីងនោះឡើយ។ ការមានចិត្តជូរល្វីង គឺជាការបំផ្លាញខ្លួនឯង យ៉ាងសោកសៅ។

ព្រះយេស៊ូវបានយាងចុះមកនៅថ្ងៃណូអែល ដើម្បីឲ្យយើងមានជីវិតអស់កល្ប។ «តែឯខ្ញុំវិញ ខ្ញុំបានមក ដើម្បីឲ្យវារាល់គ្នាមានជីវិត ហើយឲ្យមានជីវិតនោះពេញបរិបូរផង» (យ៉ូហាន ១០:១០)។ លោក អេលមើរ និងអ្នកស្រី ម៉ារាន ធ្លាប់បានពិភាក្សាគ្នា អំពីទីកន្លែងដែលពួកគេនឹងទៅរស់នៅជាមួយគ្នា នៅចុងបញ្ចប់នៃជីវិតពួកគេ។ លោក អេលមើរ ក៏បាននិយាយថា «ខ្ញុំ និងម៉ារាន បានយល់ស្របថា ផ្ទះចុងក្រោយរបស់យើង គឺនៅជាមួយព្រះអម្ចាស់»។

តើអ្នកមានអារម្មណ៍ថា ចង់ទៅផ្ទះឲ្យបានឆាប់ទេ? ខ្ញុំមានក្រុមគ្រួសារដែលត្រូវមកជួបជុំគ្នានៅផ្ទះ សម្រាប់ថ្ងៃឈប់សម្រាក។ ការនេះធ្វើឲ្យខ្ញុំមានអារម្មណ៍ល្អ។ ខ្ញុំយល់ថា មូលហេតុចម្បង ដែលយើងមានអារម្មណ៍ល្អ គឺដោយសារព្រះទ្រង់បានកំណត់ក្នុងជម្រៅចិត្តខ្ញុំ និងពួកគេ ឲ្យប្រាថ្នាចង់បានការវិលត្រឡប់មកផ្ទះចុងក្រោយបំផុត នៅស្ថានសួគ៌។ ការវិលត្រឡប់មកផ្ទះផ្សេងទៀត គឺជាការឆ្លុះបញ្ចាំងអំពីការ

វិលត្រឡប់មកផ្ទះចុងក្រោយបំផុត នៅស្ថានសួគ៌។ ហើយការឆ្លុះបញ្ចាំងទាំងនោះសុទ្ធតែជាការល្អ។

ដរាបណាការវិលត្រឡប់ទាំងនោះ មិនបានជំនួសឲ្យការវិលត្រឡប់មកផ្ទះចុងក្រោយបំផុត។ បានសេចក្តីថា យើងមិនត្រូវឲ្យរឿងដ៏ផ្អែមល្ហែមគ្រប់យ៉ាង ក្នុងរដូវកាលនៃបុណ្យណូអែលឆ្នាំនេះ ជំនួសឲ្យភាពផ្អែមល្ហែមចុងក្រោយ ដ៏អស្ចារ្យ និងស្កប់ស្កល់។ ចូរឲ្យការបាត់បង់ និងរឿងដ៏រីករាយទាំងឡាយ បណ្តាលចិត្តអ្នកឲ្យចង់ទៅនៅផ្ទះ ក្នុងនគរស្ថានសួគ៌។

និយាយឲ្យខ្លីទៅ ណូអែលគឺមានន័យថា *ខ្ញុំបានមក ដើម្បីឲ្យវារាល់គ្នាមានជីវិត*។ គឺដើម្បីឲ្យអ្នកស្រី ម៉ារាន ញូស្រ្តាំ និងម្តាយខ្ញុំ ឈ្មោះ រូធ ផាបភ័រ (Ruth Piper) ព្រមទាំងខ្ញុំ និងអ្នកមានជីវិត ក្នុងពេលបច្ចុប្បន្ន និងជារៀងរហូត។

ចូរឲ្យជីវិតអ្នកកាន់តែមានតម្លៃ និងកាន់តែស៊ីជម្រៅ ក្នុងរដូវកាលណូអែលឆ្នាំនេះ ដោយផឹកពីប្រភពទឹក*ដ៏អស់កល្បជានិច្ច* ដែលនៅជិតបង្កើយស្រាប់។

# ថ្ងៃទី១៦

*ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាង
ខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរ លើស
ជាងអស់ទាំងនាមផង ដើម្បីកាលណាឮព្រះនាមព្រះ
យេស៊ូវ នោះឲ្យគ្រប់ទាំងជង្គង់នៅស្ថានសួគ៌ នៅផែនដី
ហើយនៅក្រោមផែនដីត្រូវលុតចុះ ហើយឲ្យគ្រប់ទាំង
អណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះ
អម្ចាស់ សម្រាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា។*

ភីលីព ២:៩-១១

## ថ្ងៃទី១៦

# ការអន់ថយដ៏ជោគជ័យ
# បំផុតរបស់ព្រះ

បុណ្យណូអែលបានបង្ហាញនូវការចាប់ផ្តើមនៃការអន់ថយដ៏ជោគជ័យបំផុតរបស់ព្រះ។ ព្រះអង្គតែងតែសព្វព្រះទ័យ នឹងបង្ហាញអំណាចចេស្តាទ្រង់ តាមរយៈការអ្វី ដែលគេគិតថា ជាបរាជ័យ។ ព្រះអង្គប្រើយុទ្ធសាស្ត្រដកថយ ដើម្បីទទួលជ័យជម្នះ។

ក្នុងកណ្ឌគម្ពីរសញ្ញាចាស់ លោក យ៉ូសែប ដែលជាកូនប្រុសម្នាក់ ក្នុងចំណោមកូនប្រុសទាំង១២នាក់របស់លោកយ៉ាកុប បានយល់សប្តិឃើញខ្លួនគាត់ទទួលបាននូវភាពរុងរឿង និងអំណាច (លោកុប្បត្តិ ៣៧:៥-១១)។ ប៉ុន្តែ ដើម្បីទទួលភាពជោគជ័យនោះ គាត់ត្រូវតែក្លាយជាទាសករ នៅនគរអេស៊ីព្ទជាមុនសិន។ មិនតែប៉ុណ្ណោះ ពេលដែលស្ថានភាព

របស់គាត់ មានភាពល្អប្រសើរឡើងវិញ ដោយសារភាពត្រឹមត្រូវរបស់គាត់ គាត់ក៏បានក្លាយជាអ្នកទោស គឺកាន់តែវេទនាជាងទាសករទៅទៀត។

តែរឿងនេះសុទ្ធតែបានកើតឡើងតាមផែនការព្រះ ដោយទ្រង់បានរៀបផែនការ ដើម្បីជាប្រយោជន៍គាត់ និងក្រុមគ្រួសារគាត់ ហើយទីបំផុត គឺដើម្បីប្រយោជន៍ពិភពលោកទាំងមូល! ព្រោះកាលគាត់ជាប់គុក គាត់បានជួបអ្នកបម្រើរបស់ស្ដេចផារ៉ោន ដែលក្រោយមក ក៏បាននាំគាត់ទៅជួបស្ដេច ផារ៉ោន ហើយ ទីបំផុត ស្ដេច ផារ៉ោន បាន ឲ្យ គាត់ គ្រប់គ្រង នគរអេស៊ីព្ទ។ ហើយទីបំផុត សុបិនរបស់គាត់ក៏បានក្លាយជាការពិត។ ពួកបងប្អូនរបស់គាត់ក៏បានក្រាបនៅចំពោះគាត់ ហើយគាត់ក៏បានសង្គ្រោះពួកគេ ឲ្យរួចផុតពីគ្រោះអត់ឃ្លាន។ ដូច្នេះនេះជាផ្លូវឆ្ពោះទៅរកភាពរុងរឿង ដែលគេមិននឹកស្មានដល់!

តែនោះជាផ្លូវរបស់ព្រះសម្រាប់គាត់ និងសម្រាប់ព្រះរាជបុត្រាទ្រង់ផងដែរ។ ព្រះអង្គបានលះបង់អ្វីៗគ្រប់យ៉ាង ហើយបានយកភាពជាអ្នកបម្រើ។ ទ្រង់បានក្លាយជាអ្នកទោស ដែលអាក្រក់ជាងទាសករទៅទៀត ហើយក៏ត្រូវគេកាត់ទោសប្រហារជីវិត។ ប៉ុន្តែ ព្រះអង្គបានរក្សាភាពត្រឹមត្រូវ មិនខុសពីលោក

យ៉ូសែប ឡើយ។ «ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាងខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរ លើសជាងអស់ទាំងនាមផង ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវនោះឲ្យគ្រប់ទាំងជង្គង់នៅស្ថានសួគ៌ នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ» (ភីលីព ២:៩-១០)។

ហើយនេះក៏ជាផ្លូវរបស់ព្រះ សម្រាប់យើងផងដែរ។ ព្រះអង្គបានសន្យាថា នឹងប្រទានសិរីល្អមកយើង *បើសិនជា*យើងរងទុក្ខជាមួយទ្រង់ ដូចដែលមានសេចក្តីចែងក្នុងកណ្ឌគម្ពីរ រ៉ូម ៨:១៧។ ផ្លូវនេះជាផ្លូវឡើងទៅលើ ដែលតម្រូវឲ្យយើងត្រូវចុះទៅក្រោម ជាមុនសិន។ ផ្លូវនេះក៏ជាផ្លូវទៅមុខ ដែលតម្រូវឲ្យយើងថយក្រោយ ជាមុនសិន។ ផ្លូវឆ្ពោះទៅរកភាពជោគជ័យនេះ គឺត្រូវឆ្លងកាត់បរាជ័យ ដែលព្រះទ្រង់រៀបចំ។ ជានិច្ចជាកាល ផ្លូវទាំងនោះមើលទៅ និងមានអារម្មណ៍ថាដូចបរាជ័យ។

ប៉ុន្តែ អ្វីដែលយើងរៀនបានពីលោក យ៉ូសែប និងព្រះយេស៊ូវអំពីបុណ្យណូអែលនោះគឺ៖ ការអ្វីដែលសាតាំង និងមនុស្សមានបាប គិតចង់ធ្វើអាក្រក់មកលើយើង «នោះព្រះទ្រង់សម្រេចជាការល្អវិញ...» (លោកុប្បត្តិ ៥០:២០)។

## ថ្ងៃទី១៦

*ឱពួកបរិសុទ្ធដែលមានការភ័យខ្លាច ចូរមានចិត្តក្លាហានឡើង ពពកដែលអ្នកភ័យខ្លាចយ៉ាងនេះ ជាពពកដ៏ធំមានពេញដោយសេចក្តីមេត្តា និងទម្លាក់ព្រះពររបស់ព្រះ មកលើក្បាលអ្នក។*[១]

១ លោក William Cowper, "God Moves in a Mysterious Way," ឆ្នាំ១៧៧៣។

# ថ្ងៃទី១៧

*ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា នឹងមានគ្រា*
*មកដល់ ដែលអញនឹងតាំងសញ្ញាថ្មី នឹងពួក*
*វង្សអ៊ីស្រាអែល ហើយនឹងពួកវង្សយូដា។*

យេរេមា ៣១:៣១

ថ្ងៃទី១៧

# សេចក្ដីសង្គ្រោះដ៏អស្ចារ្យបំផុត ដែលយើងអាចយល់បាន

ព្រះទ្រង់យុត្តិធម៌ និងបរិសុទ្ធ ហើយបែកចេញពីមនុស្សមានបាបដូចយើង។ នេះជាបញ្ហាចម្បងដែលយើងមាន នៅថ្ងៃណូអែល ក៏ដូចជានៅរដូវកាលនីមួយៗ។ តើធ្វើដូចម្ដេច ឲ្យយើងអាចផ្សះផ្សាឲ្យជានឹងព្រះដែលយុត្តិធម៌ និងបរិសុទ្ធ?

ទោះជាយ៉ាងណាក៏ដោយ ព្រះទ្រង់ពេញដោយសេចក្ដីមេត្តា និងបានសន្យាក្នុងកណ្ឌគម្ពីរយេរេមា ជំពូក៣១ (តាំងពី៥០០ឆ្នាំ មុនពេលព្រះគ្រីស្ទប្រសូត) ថា ថ្ងៃមួយ ព្រះអង្គនឹងធ្វើការថ្មីៗ។ ព្រះអង្គនឹងជំនួសស្រមោល ដោយការពិតនៃព្រះមេស្ស៊ី។ ហើយព្រះអង្គយាងចូលក្នុងជីវិតយើង ដោយអំណាចចេស្ដា ហើយកត់ទុកព្រះទ័យទ្រង់ ក្នុងចិត្តយើង ដើម្បី

កុំឲ្យយើងមានការបង្ខំពីខាងក្រៅ តែមានការស្ម័គ្រចិត្តពីខាងក្នុង គឺស្ម័គ្រចិត្តស្រឡាញ់ព្រះអង្គ ទុកចិត្តព្រះអង្គ ហើយដើរតាមព្រះអង្គ។

សេចក្ដីសង្គ្រោះរបស់ទ្រង់មានភាពធំប្រសើរបំផុត ដែលយើងអាចយល់បាន បើសិនជាព្រះទ្រង់ប្រទានយើង នូវការពិតដ៏អស្ចារ្យបំផុត ក្នុងចក្រវាល ឲ្យយើងអរសប្បាយ ហើយបន្ទាប់មក ហើយយាងចូលគង់ក្នុងចិត្តយើង ឲ្យយើងបានស្គាល់ការពិតនោះ តាមរបៀបដែលយើងអាចអរសប្បាយនឹងការពិតនោះ ដោយសេរីភាពដ៏អស្ចារ្យបំផុត និងក្ដីអំណរដ៏ប្រសើរបំផុត ដែលយើងអាចមាន។ នោះជាអំណោយនៃបុណ្យណូអែល ដែលសក្ដិសមនឹងឲ្យយើងយកមករៀបរាប់ក្នុងបទចម្រៀង។

តាមពិតទៅ នោះជាអ្វីដែលទ្រង់បានសន្យា ក្នុងសេចក្ដីសញ្ញាថ្មី។ ប៉ុន្តែ មានឧបសគ្គធំមួយ។ គឺអំពើបាប។ យើងបានដាច់ចេញពីព្រះ ដោយសារអំពើបាបរបស់យើង។

តើធ្វើដូចម្ដេចឲ្យព្រះដ៏បរិសុទ្ធ និងយុត្តិធម៌ ប្រព្រឹត្តចំពោះមនុស្សមានបាបដូចយើង ដោយព្រះទ័យសប្បុរសយ៉ាងនេះ ដោយប្រទានការពិតដ៏អស្ចារ្យបំផុត ក្នុងចក្រវាល (គឺព្រះ

រាជបុត្រាព្រះអង្គ) ឲ្យយើងបានអរសប្បាយ ដោយក្ដីអំណរដ៏អស្ចារ្យបំផុត ដែលយើងអាចមាន?

ចម្លើយនោះគឺ ព្រះទ្រង់បានដាក់អំពើបាបរបស់យើង មកលើព្រះរាជបុត្រាទ្រង់ ហើយក៏បានជំនុំជម្រះអំពើបាបទាំងនោះនៅលើព្រះរាជបុត្រា ដើម្បីឲ្យទ្រង់អាចដកពួកវាចេញពីគំនិតទ្រង់ ហើយប្រព្រឹត្តចំពោះយើង ដោយសេចក្ដីមេត្តាករុណា ហើយបន្តមានភាពយុត្តិធម៌ និងបរិសុទ្ធ។ កណ្ឌគម្ពីរ ហេព្រើរ ៩:២៨ បានចែងថា ព្រះគ្រីស្ទ «បានថ្វាយព្រះអង្គទ្រង់១ដង ហើយដោយព្រោះបាបរបស់មនុស្សជាច្រើន»។

ព្រះគ្រីស្ទក៏បានផ្ទុកអំពើបាបយើង នៅលើអង្គទ្រង់ ពេលទ្រង់សុគត (១ពេត្រុស ២:២៤)។ ព្រះអង្គទទួលយកការជំនុំជម្រះ ដែលយើងត្រូវទទួល (រ៉ូម ៨:៣)។ ព្រះអង្គបានលុបទោសរបស់យើងចោល (រ៉ូម ៨:១)។ បានសេចក្ដីថា យើងបានរួចពីបាបហើយ (កិច្ចការ ១០:៤៣)។ អំពើបាបយើងមិននៅជាប់ក្នុងគំនិតរបស់ព្រះ ដោយធ្វើជាមូលដ្ឋាននៃការថ្កោលទោសយើងទៀតទេ។ តាមន័យនេះ ព្រះអង្គ «មិននឹកចាំ» អំពើបាបយើងទៀតឡើយ (មើលយេរេមា ៣១:៣៤)។ ព្រះទ្រង់បានលុបអំពើបាបរបស់យើងចោល ក្នុងការសុគត

របស់ព្រះគ្រីស្ទ។

បានសេចក្ដីថា ចាប់តាំងពីពេលនោះមក ព្រះទ្រង់ប្រទាន មកយើង ដោយសេរី តាមយុត្តិធម៌របស់ទ្រង់ នូវសេចក្តីសន្យា ដ៏អស្ចារ្យនៃសេចក្តីសញ្ញាថ្មី ដែលមិនអាចពិពណ៌នាបាន។ គឺព្រះអង្គប្រទានយើងនូវព្រះគ្រីស្ទ ដែលជាការពិតដ៏អស្ចារ្យ ក្នុងចក្រវាល សម្រាប់ឲ្យយើងអរសប្បាយ។ ហើយព្រះអង្គ បានកត់បំណងព្រះទ័យទ្រង់ ឬព្រះទ័យទ្រង់ ពីលើចិត្តរបស់ យើង ដើម្បីឲ្យយើងអាចស្រឡាញ់ព្រះគ្រីស្ទ ហើយទុកចិត្ត ព្រះគ្រីស្ទ ហើយដើរតាមព្រះគ្រីស្ទ ចេញពីក្នុងចិត្ត ដោយសេរី ភាព និងក្តីអំណរ។

# ថ្ងៃទី១៨

*ទូលបង្គំបានចាត់គេឲ្យទៅក្នុងលោកីយ៍ ដូចជា*
*ទ្រង់ចាត់ទូលបង្គំ ឲ្យមកក្នុងលោកីយ៍ដែរ។*

យ៉ូហាន ១៧:១៨

ថ្ងៃទី១៨

# បុណ្យណូអែលគឺជាគំរូ សម្រាប់បេសកកម្ម

បុណ្យណូអែលគឺជាគំរូសម្រាប់បេសកកម្ម។ បេសកកម្ម ជាកញ្ចក់ឆ្លុះឲ្យឃើញបុណ្យណូអែល។

ឧទាហរណ៍៖ ខ្ញុំសូមនិយាយអំពីគ្រោះថ្នាក់។ ព្រះគ្រីស្ទបាន យាងមករករាស្ត្រទ្រង់ ហើយរាស្ត្រទ្រង់មិនបានទទួលទ្រង់ទេ។ គេក៏នឹងមិនទទួលអ្នកដែរ។ គេបានរៀបគម្រោងទាស់នឹង ទ្រង់។ អ្នកក៏អាចជួបបញ្ហានេះដែរ។ ពួកគេបានចោទបង្ខូចព្រះ អង្គ។ ដូចនេះ អ្នកក៏អាចទទួលរងការចោទប្រកាន់ផងដែរ។ គេវាយដំ និងចំអកឲ្យទ្រង់។ អ្នកក៏អាចទទួលរងដូចគ្នា។ ព្រះ អង្គសុគត បន្ទាប់ពីព្រះអង្គបានបំពេញព្រះរាជកិច្ចទ្រង់បានបី ឆ្នាំ។ អ្នកក៏អាចបាត់បង់ជីវិត ក្នុងការបម្រើទ្រង់ផងដែរ។

តែមានគ្រោះថ្នាក់ដែលអាក្រក់ជាងនេះទៀត ដែល

ព្រះយេស៊ូវ*បានជៀសផុត*។ អ្នកក៏អាចជៀសវាងផងដែរ!

នៅពាក់កណ្តាលសតវត្សរ៍ទី១៦ បេសកជន ឈ្មោះ ហ្វ្រង់ស៊ីស ហ្សាវីយ៉េរ (Francis Xavier ឆ្នាំ១៥០៦-១៥៥២) បានសរសេរសំបុត្រផ្ញើទៅលោកឪពុក ប៉េរ៉េស នៃទីក្រុងម៉ាឡាកា (Father Perez of Malacca សព្វថ្ងៃនេះ ជាផ្នែកមួយនៃប្រទេសម៉ាឡេស៊ី) ដើម្បីរៀបរាប់អំពីគ្រោះថ្នាក់ នៃបេសកកម្មរបស់គាត់ នៅប្រទេសចិន។ ក្នុងសំបុត្រនោះ គាត់បាននិយាយថា «គ្មានអ្វីគ្រោះថ្នាក់ជាងការបាត់បង់ជំនឿ ឬទំនុកចិត្តលើសេចក្តីមេត្តាករុណារបស់ព្រះនោះទេ…ការមិនទុកចិត្តព្រះអង្គ គឺជាការអាក្រក់លើសការអាក្រក់ខាងសាច់ឈាមណាទាំងអស់ ដែលសត្រូវទាំងអស់របស់ព្រះអាចប្រមូលផ្តុំរួចទម្លាក់មកលើយើង។ ដ្បិត បើសិនជាគ្មានការអនុញ្ញាតពីព្រះទេ នោះពួកអារក្ស ឬមនុស្សដែលបម្រើពួកវា មិនអាចរារាំងយើងសូម្បីតែបន្តិច»។[១]

គ្រោះថ្នាក់ធំបំផុតដែលបេសកជនជួបប្រទះ គឺមិនមែនជាសេចក្តីស្លាប់ តែជាការមិនទុកចិត្តសេចក្តីមេត្តារបស់ព្រះ។

១ ដកស្រង់ចេញពី “A Letter to Father Perez,” ក្នុងសៀវភៅ *Classics of Christian Missions*, កែសម្រួលដោយ៖ លោក Francis M.DuBose (Nashville, TN: Broadman Press, ឆ្នាំ១៩៧៩), ២២១f.។

បើគេអាចជៀសវាងគ្រោះថ្នាក់មួយនេះ នោះគ្រោះថ្នាក់ផ្សេងទៀតក៏បាត់បង់ទ្រនិចរបស់ខ្លួនផងដែរ។

នៅចុងបញ្ចប់ព្រះទ្រង់ធ្វើឲ្យកាំបិតស្នៀតនីមួយៗ ក្លាយជាដំបងរាជ្យ នៅក្នុងដៃរបស់យើង។ គឺដូចដែលលោក ចេ. ដាប់ប៊ិលយូ. អ័ឡិកហ្សែនឌ័រ (J. W. Alexander ) បានមានប្រសាសន៍ថា «កិច្ចការនីមួយៗដែលយើងធ្វើថ្វាយព្រះ ក្នុងពេលបច្ចុប្បន្ន នឹងបានទទួលការតបស្នង នូវសិរីល្អ១លានជំនាន់ តាមព្រះគុណព្រះ»។[២]

ព្រះគ្រីស្ទបានជៀសផុសពីគ្រោះថ្នាក់នេះ គឺគ្រោះថ្នាក់នៃការមិនទុកចិត្តព្រះ។ ហេតុនេះហើយ ព្រះទ្រង់បានលើកតម្កើងទ្រង់ខ្ពស់ឡើង។ ដូចនេះ ព្រះអង្គក៏នឹងលើកអ្នកខ្ពស់ឡើងផងដែរ។

ឆ្នាំនេះ ក្នុងរដូវកាលនៃការរង់ចាំមុនថ្ងៃណូអែល ចូរចាំថា បុណ្យណូអែលគឺជាគំរូ សម្រាប់បេសកកម្ម។ *គឺសម្រាប់ខ្ញុំនិងអ្នក*។ ហើយបេសកកម្មនោះ អាចជួបគ្រោះថ្នាក់។ ហើយគ្រោះថ្នាក់ធំបំផុតគឺការមិនទុកចិត្តសេចក្តីមេត្តារបស់ព្រះ។ បើយើងមិនជម្នះបញ្ហានេះទេ នោះយើងនឹងធ្លាក់ចូលក្នុងភាព

២ លោក J. W. Alexander, *Thoughts on Preaching: Classic Contributions to Homiletics* (Edinburgh: Banner of Truth, ឆ្នាំ១៩៧៥), ទំព័រ១០៨។

អស់សង្ឃឹមមិនខាន។ ចូរជម្នះវា នោះគ្មានអ្វីអាចធ្វើទុក្ខអ្នកមួយលានជំនាន់។

# ថ្ងៃទី១៩

*ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រម
គ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះ
ដែរ ដើម្បីឲ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាច
លើសេចក្ដីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ហើយ
ឲ្យបានប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវបម្រើ
គ្រប់១ជីវិត ដោយខ្លាចស្លាប់ ឲ្យបានរួចចេញវិញ។*

ហេព្រើរ ២:១៤-១៥

ថ្ងៃទី១៩

# បុណ្យណូអែល គឺដើម្បីឲ្យយើងមានសេរីភាព

ព្រះយេស៊ូវបានយកកំណើតជាមនុស្ស ព្រោះព្រះទ្រង់បានតម្រូវឲ្យមានការស្លាប់របស់អង្គបុគ្គលមួយអង្គ ដែលមានលក្ខណៈលើសមនុស្ស។ ការយាងមកចាប់កំណើតរបស់ព្រះអង្គ គឺជាការដែលព្រះអង្គចាក់សោព្រះអង្គទ្រង់ ឲ្យជាប់នឹងទោសប្រហារជីវិត។

ព្រះគ្រីស្ទមិនបានប្រថុយនឹងសេចក្តីស្លាប់ តែព្រះអង្គបានជ្រើសរើសយកការសុគត។ ពោលគឺព្រះអង្គបានឱបក្រសោបយកសេចក្តីស្លាប់។ ហេតុនេះហើយ ព្រះអង្គបានមក «មិនមែនឲ្យគេបម្រើ ដែរ គឺដើម្បីនឹងបម្រើ គេវិញ ហើយនិងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង» (ម៉ាកុស ១០:៤៥)។

យើងអាចដឹងច្បាស់ថា សាតាំងពិតជាបានព្យាយាមបង្វែរ

ព្រះទ័យព្រះយេស៊ូវ ឲ្យងាកចេញពីឈើឆ្កាង កាលព្រះអង្គគង់នៅវាលរហោស្ថាន (ម៉ាថាយ ៤:១-១១) និងបានព្យាយាមរារាំងព្រះអង្គ តាមរយៈមាត់របស់លោក ពេត្រុស (ម៉ាថាយ ១៦:២១-២៣)! ឈើឆ្កាងគឺជាសេចក្តីហិនវិនាសរបស់សាតាំង។ តើព្រះយេស៊ូវបានបំផ្លាញវា ដោយរបៀបណា?

កណ្ឌគម្ពីរ ហេព្រើរ ២:១៤ បានចែងថា សាតាំងមាន "អំណាចនៃសេចក្តីស្លាប់"។ បានសេចក្តីថា សាតាំងមានសមត្ថភាពធ្វើឲ្យមនុស្សមានការភ័យខ្លាចសេចក្តីស្លាប់។ "អំណាចនៃសេចក្តីស្លាប់" ជាអំណាចដែលធ្វើឲ្យមនុស្សជាប់ចំណង តាមរយៈការខ្លាចសេចក្តីស្លាប់។ វាជាអំណាចដែលធ្វើឲ្យមនុស្សបន្តរស់នៅក្នុងអំពើបាប ដើម្បីឲ្យសេចក្តីស្លាប់ចូលមក ក្នុងលក្ខណៈដែលគួរឲ្យភ័យខ្លាច។

ប៉ុន្តែ ព្រះយេស៊ូវបានដកហូតអំណាចនេះចេញពីសាតាំង។ ព្រះអង្គបានដកហូតអាវុធមួយនេះចេញពីវា។ ព្រះអង្គបានបង្កើតអាវក្រោះនៃសេចក្តីសុចរិត សម្រាប់យើង ដើម្បីឲ្យយើងមានភាពស៊ាំនឹងការចោទប្រកាន់ទោសរបស់អារក្ស។ តើព្រះអង្គបានប្រទានអាវក្រោះនៃសេចក្តីសុចរិតមកយើង ដោយរបៀបណា?

គឺដោយសារការសុគតរបស់ព្រះយេស៊ូវ នោះព្រះអង្គបាន

លប់អំពើបាបទាំងអស់របស់យើងចោល។ ហើយមនុស្សដែលបានរួចពីបាប មិនអាចទទួលរងការថ្កោលទោសពីសាតាំងទៀតទេ។ ដោយសារយើងបានទទួលការអត់ទោសបាបពីព្រះអង្គហើយ នោះទីបំផុត សាតាំងមិនអាចបំផ្លាញយើងបានឡើយ។ សាតាំងមានផែនការបំផ្លាញច្បាប់របស់ព្រះចោល ដោយថ្កោលទោសអ្នកដើរតាមព្រះអង្គ នៅទីជំនុំជម្រះរបស់ព្រះអង្គ។ ប៉ុន្តែ ឥឡូវនេះ ក្នុងព្រះគ្រីស្ទ យើងមិនមានទោសទៀតទេ។ អំពើក្បត់របស់សាតាំងក៏បានបរាជ័យ។ ល្បិចកលរបស់វានៅនាអាកាសក៏បានខកខាន។ «យើងអាចស៊ូទ្រាំនឹងកំហឹងដែលវាបានបញ្ចេញមក ដ្បិតវាពិតជានឹងទទួលសេចក្ដីហិនវិនាស»។[១] ឈើឆ្កាងបានវាយបំបាក់វាហើយ។ ហើយមិនយូរប៉ុន្មាន វានឹងដកដង្ហើមជាលើកចុងក្រោយជាមិនខាន។

ព្រះទ្រង់ប្រទានបុណ្យណូអែល ដើម្បីឲ្យយើងមានសេរីភាព គឺសេរីភាពរួចផុតពីសេចក្ដីស្លាប់។

ព្រះយេស៊ូវបានយាងមកយកកំណើតជាមនុស្សដូចយើង នៅភូមិបេថ្លេហិម ដើម្បីសុគតជំនួសយើង នៅទីក្រុងយេរូសាឡឹម ទាំងអស់នេះ គឺដើម្បីឲ្យយើងអាចរស់នៅដោយ

១ លោក Martin Luther, "A Mighty Fortress Is Our God," ឆ្នាំ១៥២៧-១៥២៩។

គ្មានការភ័យខ្លាច ក្នុងទីក្រុងរបស់យើង ក្នុងពេលបច្ចុប្បន្ន។ ជាការពិតណាស់ គឺគ្មានការភ័យខ្លាចទៀតទេ ពីព្រោះថា បើការគំរាមកំហែងធំបំផុត មកលើក្ដីអំណររបស់យើង បានរលាយបាត់ហើយ តើហេតុអ្វីយើងគួរតែមានការភ័យខ្លាចចំពោះការគំរាមកំហែងដែលតូចជាងនោះ? តើធ្វើដូចម្ដេចឲ្យយើងអាចនិយាយថា យើងពិតជាគ្មានការភ័យខ្លាច! យើងប្រហែលជាចង់និយាយថា “ខ្ញុំមិនខ្លាចស្លាប់ទេ តែខ្ញុំខ្លាចបាត់បង់ការងារ?” ទេ! ទេ! ការនិយាយដូចនេះ គឺមិនសមហេតុផលឡើយ។ សូមគិតឡើងវិញ!

បើសេចក្ដីស្លាប់ (ខ្ញុំចង់និយាយថា សេចក្ដីស្លាប់! គឺការគ្មានជីពចរ ខ្លួនត្រជាក់ លែងមានជីវិត!) មិនមែនជាអ្វីដែលយើងភ័យខ្លាចទៀត នោះយើងមានសេរីភាព គឺសេរីភាពពិតប្រាកដ។ យើងមានសេរីភាព នៅក្នុងការប្រឈមមុខដាក់គ្រោះថ្នាក់ទាំងឡាយ នៅក្រោមកម្ដៅថ្ងៃ ថ្វាយព្រះគ្រីស្ទ និងដើម្បីសេចក្ដីស្រឡាញ់។ យើងមិនមែនជាទាសករនៃការថប់បារម្ភទៀតទេ។

បើព្រះរាជបុត្រានៃព្រះបានរំដោះអ្នក ឲ្យមានសេរីភាពហើយ នោះអ្នកនឹងមានសេរីភាពពិតប្រាកដ!

# ថ្ងៃទី២០

*ដោយហេតុនោះបានជាព្រះរាជបុត្រានៃព្រះបានលេច
មក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ។*

១យ៉ូហាន ៣:៨

ថ្ងៃទី២០

# ការរួមចិត្តគ្នានៃថ្ងៃណូអែល

សង្វាក់ផលិតកម្មនៃរោងចក្ររបស់សាតាំង បានផលិតអំពើបាបរាប់លាន ជារៀងរាល់ថ្ងៃ។ វាបានវេចខ្ចប់អំពើបាបទាំងនោះ ដឹកតាមយន្តហោះដឹកទំនិញ ចូលទៅស្ថានសួគ៌ ហើយបើកបង្ហាញពួកវា នៅពីមុខព្រះ រួចវាក៏បានសើចហើយសើចទៀត។

មនុស្សមួយចំនួនបានធ្វើការពេញពេល នៅក្នុងសង្វាក់ផលិតកម្មនៃអំពើបាបនោះ។ អ្នកខ្លះបានបោះបង់ចោលការងារនៅទីនោះហើយ តែបានមួយរយៈពេល ពួកគេក៏វិលត្រឡប់ទៅធ្វើការងារនោះវិញ។

គ្រប់នាទីដែលមនុស្សធ្វើការ ក្នុងសង្វាក់ផលិតកម្មនោះ គឺបានធ្វើឲ្យសាតាំងសើចចំអកឲ្យព្រះ។ អំពើបាប គឺជាមុខរបររបស់សាតាំង ព្រោះវាស្អប់ពន្លឺ ភាពស្រស់ស្អាត សេចក្ដី

បរិសុទ្ធ និងសិរីល្អរបស់ព្រះ។ គ្មានអ្វីដែលធ្វើឲ្យវាសប្បាយចិត្ត ជាងពេលដែលស្នាព្រះហស្តរបស់ព្រះ មិនទុកចិត្ត និងមិនស្តាប់បង្គាប់ព្រះអាទិកររបស់ខ្លួននោះទេ។

ដូចនេះ ណូអែលជាដំណឹងល្អ សម្រាប់មនុស្ស ហើយក៏ជាដំណឹងល្អសម្រាប់ព្រះ។

«ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប» (១ធីម៉ូថេ ១:១៥)។ នេះជាដំណឹងល្អសម្រាប់យើង។

«ដោយហេតុនោះបានជាព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ» (១យ៉ូហាន ៣:៨)។ នេះក៏ជាដំណឹងល្អសម្រាប់ព្រះអង្គផងដែរ។

ណូអែលគឺជាដំណឹងល្អសម្រាប់ព្រះ ព្រោះព្រះយេស៊ូវបានយាងចុះមក ដើម្បីដឹកនាំកូដកម្ម នៅសង្វាក់ផលិតកម្មរបស់សាតាំង។ ព្រះអង្គបានយាងចូលទៅក្នុងរោងចក្រនោះតែម្តង និងត្រាស់ហៅពួកស្មោះត្រង់ ឲ្យគាំទ្រព្រះអង្គ ហើយក៏បានចាប់ផ្តើមនាំពួកគេដើរចេញទាំងហ្វូង។

ណូអែលជាការត្រាស់ហៅឲ្យធ្វើកូដកម្ម នៅរោងចក្រដំឡើង

អំពើបាប។ គឺដោយគ្មានការចរចាជាមួយផ្នែកគ្រប់គ្រង។ គ្មានការតថ្លៃអ្វីទ្បើយ។ តែជាការរួមចិត្តគ្នា ប្រឆាំងនឹងផលិតផលនោះ ដោយគ្មានការរាថយ។យើងនឹងមិនរួមចំណែកនៅក្នុងការផលិតវាទៀតទ្បើយ។

ការរួមចិត្តគ្នានៃបុណ្យណូអែល មានគោលបំណងរាំងខ្ទប់យន្តហោះដឹកផលិតផល មិនឲ្យហោះឡើង។ ការរួមចិត្តគ្នានេះមិនប្រើអំណាច ឬហិង្សាទ្បើយ តែដោយភាពស្មុគ្រស្មោះជារៀងរហូត ចំពោះសេចក្តីពិត ការរួមចិត្តគ្នានេះនឹងបង្ហាញឲ្យគេឃើញស្ថានភាពពិតនៃរោងចក្ររបស់អារក្ស ដែលបំផ្លាញជីវិតមនុស្ស។

ការរួមចិត្តគ្នានៃបុណ្យណូអែល នឹងមិនចុះចាញ់ទ្បើយ រហូតដល់ពេលដែលរោងចក្ររបស់អារក្សបានបិទទ្វារជាស្ថាពរ។

ពេលណាអំពើបាបត្រូវបានបំផ្លាញចោលហើយ នឹងគ្មាននរណាចោទប្រកាន់មកលើព្រះនាមរបស់ព្រះទៀតទេ។ ពោលគឺគ្មាននរណាសើចចំអកទៀត។

បើអ្នកចង់ថ្វាយអំណោយមួយដល់ព្រះ ក្នុងរដូវកាលនៃបុណ្យណូអែលឆ្នាំនេះ ចូរដើរចេញពីសង្វាក់ផលិតកម្មនៃអំពើបាប ដោយមិនវិលត្រឡប់។ ចូររើសយកកន្លែងរបស់

អ្នក នៅក្នុងជួរកូដកម្មនៃសេចក្តីស្រឡាញ់ ដើម្បីតវ៉ាប្រឆាំង នឹងសង្វាក់ផលិតកម្មនៃអំពើបាប។ ចូរយើងចូលរួម នៅក្នុង ការរួមចិត្តគ្នានៃបុណ្យណូអែល ទាល់តែអារក្សលែងមានការ ចោទប្រកាន់ មកលើព្រះនាមដ៏មានចេស្តារបស់ព្រះ ហើយ ព្រះអង្គពេញដោយសិរីល្អ ក្នុងការសរសើរតម្កើង អំពីភាព សុចរិតរបស់ព្រះអង្គ។

# ថ្ងៃទី២១

*លោក ពីឡាត ក៏សួរទ្រង់ថា ដូច្នេះ អ្នកជាស្តេចមែនឬ ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា លោកមានប្រសាសន៍ថា ខ្ញុំជាស្តេច នោះត្រូវហើយ ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកីយ៍នេះសម្រាប់តែការនោះឯង ដើម្បីឲ្យខ្ញុំបានធ្វើបន្ទាល់ពីសេចក្តីពិត អស់អ្នកណាដែលកើតពីសេចក្តីពិត នោះក៏ឮសំឡេងខ្ញុំ។*

យ៉ូហាន ១៨:៣៧

ថ្ងៃទី២១

# កំណើតនៃព្រះដែលមានព្រះវត្តមានតាំងពីអស់កល្បជានិច្ច

កណ្ឌគម្ពីរ យ៉ូហាន ១៨:៣៧ ជាកណ្ឌគម្ពីរដ៏អស្ចារ្យ ដែលនិយាយអំពីបុណ្យណូអែល ទោះនិយាយក្នុងបរិបទនៃចុងបញ្ចប់ តែមិនមែនដើមដំបូងនៃព្រះជន្មរបស់ព្រះយេស៊ូវនៅលើផែនដីក៏ដោយ។

ចូរកត់សម្គាល់ថា ព្រះយេស៊ូវមិនគ្រាន់តែបានមានបន្ទូលថា ព្រះអង្គបានប្រសូតប៉ុណ្ណោះទេ តែថែមទាំងមានបន្ទូលថា ព្រះអង្គ «បានយាងចុះមកក្នុងលោកីយ៍»។ លក្ខណៈពិសេសខុសគេនៃការប្រសូតរបស់ព្រះអង្គ គឺនៅត្រង់ថា ព្រះអង្គមិនបានចាប់ផ្តើមមានព្រះជន្ម នៅពេលព្រះអង្គប្រសូតនោះទេ។ ព្រះអង្គមានព្រះជន្ម តាំងពីមុនពេលព្រះអង្គប្រសូតនៅក្នុងក្រោលសត្វទៅទៀត។ អង្គបុគ្គល ចារិកលក្ខណៈ និងបុគ្គលិក

លក្ខណៈរបស់ព្រះយេស៊ូវ មកពីស្រុកណាសារ៉ែត គឺសុទ្ធតែមានស្រាប់ តាំងពីមុនពេលព្រះអង្គប្រសូតជាមនុស្ស។

ពាក្យក្នុងទេវវិទ្យា ដែលបកស្រាយអំពីសេចក្តីអាថ៌កំបាំងនេះបានពេញលេញ មិនមែនជាពាក្យ *“ការកើត”* តែពាក្យ *“យាងចុះមកយកកំណើតជាមនុស្ស”*។ អង្គបុគ្គលរបស់ទ្រង់មិនមែនជាព្រះកាយ តែជាភាពជាបុគ្គលមួយអង្គនៃព្រះយេស៊ូវ គឺមានវត្តមាន តាំងពីមុនព្រះអង្គប្រសូតជាមនុស្ស។ ការប្រសូតរបស់ព្រះអង្គ មិនមែនជាការយាងមកយកកំណើតជាមនុស្សថ្មីម្នាក់ តែជាការយាងចុះមកក្នុងលោកីយ៍ ក្នុងលក្ខណៈជាអង្គបុគ្គលចាស់មួយអង្គ។ តាំងពី៧០០ឆ្នាំ មុនពេលព្រះយេស៊ូវប្រសូត កណ្ឌគម្ពីរ មីកា ៥:១ បានចែងថា៖

*តែឯង ឱបេថ្លេហិម-អេប្រាតាអើយ ឯងដែលតូចនៅក្នុងពួកយូដាទាំងពាន់ៗ នឹងមានម្នាក់កើតចេញពីឯងមកឲ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក។*

សេចក្តីអាថ៌កំបាំងនៃការប្រសូតរបស់ព្រះយេស៊ូវ គឺមិនគ្រាន់តែជាការប្រសូតរបស់ព្រះអង្គ ពីស្ត្រីព្រហ្មចារីប៉ុណ្ណោះទេ។ ព្រះទ្រង់បានបណ្តាលឲ្យការអស្ចារ្យនេះកើតឡើង ដើម្បីធ្វើបន្ទាល់ពីការអស្ចារ្យជាងនេះទៀត គឺបុត្រដែលបានប្រសូត

នៅថ្ងៃណូអែលដំបូងបំផុតនោះ ជាអង្គបុគ្គលដែលមានវត្តមាន «តាំងពីបុរាណ គឺពីអស់កល្បរៀងមក»។

ដូចនេះព្រះអង្គបានប្រសូត ដោយមានការគ្រោងទុកជាមុន។ មុនពេលព្រះអង្គប្រសូត ព្រះអង្គបានគិតអំពីការប្រសូតនោះ។ ព្រះអង្គបានរៀបផែនការនៃការប្រសូតនេះ ជាមួយព្រះវរបិតា។ ក្នុងរយៈពេលប៉ុន្មានម៉ោងចុងក្រោយ មុនពេលព្រះអង្គសុគត ព្រះអង្គបានមានបន្ទូលអំពីផ្នែកមួយនៃផែនការនេះថា «ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកីយ៍នេះ សម្រាប់តែការនោះឯង ដើម្បីឲ្យខ្ញុំបានធ្វើបន្ទាល់ពីសេចក្តីពិត អស់អ្នកណាដែលកើតពីសេចក្តីពិត នោះក៏ឮសំឡេងខ្ញុំ» (យ៉ូហាន ១៨:៣៧)។

ព្រះអង្គជាសេចក្តីពិតដ៏អស់កល្ប។ ព្រះអង្គមានបន្ទូលតែអំពីសេចក្តីពិតប៉ុណ្ណោះ។ ព្រះអង្គបង្ហាញចេញនូវសេចក្តីពិតដ៏អស្ចារ្យបំផុតនៃសេចក្តីស្រឡាញ់ តាមរយៈការសុគតរបស់ព្រះអង្គ។ ហើយព្រះអង្គកំពុងតែប្រមូលអស់អ្នកដែលបានកើតពីសេចក្តីពិតនោះ ចូលទៅក្នុងមហាគ្រួសារដ៏អស់កល្បរបស់ព្រះអង្គ។ នេះជាផែនការ ដែលបានរៀបចំមកតាំងពីអស់កល្បរៀងមក។

# ថ្ងៃទី២២

*ព្រះយេស៊ូវក៏ធ្វើទីសម្គាល់ជាច្រើនទៀត នៅមុខពួកសិស្ស
ទ្រង់ ដែលមិនបានចែងទុកក្នុងសៀវភៅនេះទេ បានចែង
ទុកតែប៉ុណ្ណេះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវ
ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់
គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយមានជំនឿ។*

យ៉ូហាន ២០:៣០-៣១

## ថ្ងៃទី២២

# ដើម្បីឲ្យលោកអ្នកជឿព្រះអង្គ

ខ្ញុំ មានការជឿជាក់យ៉ាងមុតមាំថា ក្នុងចំណោមអ្នកដែលបានចម្រើនវ័យធំឡើង ក្នុងពួកជំនុំ និងអ្នកដែលអាចសូត្រគោលលទ្ធិធំៗនៃជំនឿរបស់យើង ពេលគេងមមើ និងអ្នកដែលអាចស្វាបចេញគោលជំនឿរបស់ពួកសាវ័ក (ត្រង់ចំណុចនេះ គឺសំដៅទៅលើការចេះស្ទាត់) ពោលគឺក្នុងចំណោមយើង យើងត្រូវធ្វើអ្វីម៉្យាង ដើម្បីឲ្យយើងមានការស្ញែងខ្លាច ការកោតខ្លាច ការស្ញប់ស្ញែង ចំពោះព្រះរាជបុត្រានៃព្រះ ដែលគង់នៅជាមួយព្រះវរបិតាតាំងពីអស់កល្ប ដោយជញ្ជឹងគិតអំពីសិរីល្អគ្រប់យ៉ាងរបស់ព្រះ ដោយធ្វើជារូបភាពនៃអង្គទ្រង់ ដែលបង្កើតអ្វីៗតាមរយៈព្រះអង្គទ្រង់ ទ្រទ្រង់ចក្រវាលទាំងមូល ដោយព្រះបន្ទូល

នៃព្រះចេស្តាព្រះអង្គ។

លោកអ្នកអាចអានរឿងនិទាននីមួយៗដែលគេបាននិពន្ធរឿងអាថ៌កំបាំងនីមួយៗដែលធ្វើឲ្យរំភើបចិត្ត រឿងខ្មោចទាំងអស់ តែលោកអ្នកនឹងមិនដែលបានឃើញរឿងណា ដែលគួរឲ្យភ្ញាក់ផ្អើល ចម្លែក និងប៉ះពាល់ចិត្ត ដូចរឿងនៃការយាងចុះមកនៃព្រះរាជបុត្រានៃព្រះ មកយកកំណើតជាមនុស្សឡើយ។

ឱព្រះអង្គអើយ! យើងខ្ញុំដូចជាមនុស្សស្លាប់! តើយើងខ្ញុំមានការព្រងើយកន្តើយ និងមិនយកចិត្តទុកដាក់ប៉ុណ្ណា ចំពោះសិរីល្អ និងរឿងរបស់ព្រះអង្គ! តើមានពេលប៉ុន្មានដងហើយដែលយើងខ្ញុំត្រូវប្រែចិត្ត ហើយនិយាយថា “ព្រះអង្គអើយ! សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ដែលមានចិត្តស្ងប់ស្ងែងភ្ញាក់ផ្អើល កោតសរសើរ និងមានអំណរ ចំពោះរឿងប្រឌិតរបស់មនុស្ស ខ្លាំងជាងរឿងពិតរបស់ព្រះអង្គ”។

រឿងវិទ្យាសាស្ត្រដែលធ្វើឲ្យញាប់ញ័រក្នុងចិត្ត ក្នុងសម័យយើង យ៉ាងហោចណាស់ ប្រហែលជាអាចមានប្រយោជន៍ចំពោះយើង ត្រង់ចំណុចដែលថា ពួកវាអាចធ្វើឲ្យយើងបន្ទាបខ្លួន ហើយនាំយើងប្រែចិត្ត ដោយបង្ហាញឲ្យយើងឃើញថាយើងពិតជាអាចមានចិត្តភ្ញាក់ផ្អើល និងស្ងប់ស្ងែង ដែលយើង

កម្រនឹងមាន ពេលណាយើងជញ្ជឹងគិត អំពីព្រះដ៏អស់កល្ប និងអំពីសិរីល្អនៃព្រះគ្រីស្ទនៅស្ថានដ៏ខ្ពស់ និងទំនាក់ទំនងដ៏រស់ពិតប្រាកដ រវាងព្រះអង្គ និងយើង ក្នុងព្រះយេស៊ូវ មកពីស្រុកណាសារ៉ែត។

ពេលដែលព្រះយេស៊ូវមានបន្ទូលថា “ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកីយ៍នេះសម្រាប់តែការនោះឯង” (យ៉ូហាន ១៨:៣៧) គឺព្រះអង្គកំពុងមានបន្ទូល នូវអ្វីដែលមនុស្សគិតថា ឆ្កួត និងខុសរបៀប ហើយចម្លែក ព្រមទាំងអាថ៌កំបាំង ដូចសម្រង់សម្ដីណាមួយ ក្នុងរឿងប្រឌិតបែបវិទ្យាសាស្ត្រ ដែលលោកអ្នកបានស្ដាប់ឮ។

ឱខ្ញុំសូមឲ្យការបើកបង្ហាញនៃព្រះវិញ្ញាណរបស់ព្រះបានកើតមានចំពោះខ្ញុំ លោកអ្នក និងសូមព្រះវិញ្ញាណបរិសុទ្ធ ជ្រួតជ្រាបក្នុងបទពិសោធន៍របស់ខ្ញុំ តាមរបៀបដែលគួរឲ្យភ័យខ្លាច ដើម្បីធ្វើឲ្យខ្ញុំភ្ញាក់ដឹងខ្លួនឡើង ដើម្បីឲ្យបានស្គាល់ការពិតរបស់ព្រះដែលហួសការយល់ដឹងរបស់យើង។

ថ្ងៃមួយ ផ្ទៃមេឃនឹងមានពេញដោយផ្លេកបន្ទោរ ចាប់តាំងពីពេលថ្ងៃរះ ដល់ថ្ងៃលិច ហើយកូនមនុស្សនឹងលេចឡើងនៅលើពពក ជាមួយនឹងទេវតានៃព្រះចេស្ដាទ្រង់ ដោយមាន

អណ្ដាតភ្លើង។ ហើយយើងនឹងបានឃើញព្រះអង្គកាន់តែច្បាស់។ ហើយទោះយើងតក់ស្លុត ឬមានចិត្តរំភើបឥតឧបមាក្ដី យើងនឹងញាប់ញ័រ ហើយនឹងឆ្ងល់ថា តើយើងបានរស់នៅបានយូរយ៉ាងនេះ ជាមួយព្រះយេស៊ូវដ៏សុភាព ដោយរបៀបណា?

នេះជាសេចក្ដីដែលបានចែង—ពោលគឺបានចែងក្នុងព្រះគម្ពីរទាំងមូល—ដើម្បីឲ្យយើងជឿ យើងមានចិត្តស្ញប់ស្ញែង និងភ្ញាក់ដឹងខ្លួន ដោយសារសេចក្ដីដ៏អស្ចារ្យដែលចែងថា ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដែលបានយាងចុះមកក្នុងលោកីយ៍នេះ។

# ថ្ងៃទី២៣

ដ្បិតកាលយើងជាខ្មាំងសត្រូវ បើយើងបានជាមេត្រីនឹងព្រះវិញ
ទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ដូច្នេះ ដែលយើង
បាន ជាមេត្រីហើយ នោះប្រាកដជាយើងនឹងបានសង្គ្រោះជា
មិនខានលើសទៅទៀត ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ
ហើយមិនតែប៉ុណ្ណោះសោត យើងក៏មានសេចក្ដីរីករាយចំពោះ
ព្រះផង ដោយនូវព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់
គ្នាដែលឥឡូវនេះ យើងបានជាមេត្រីដោយសារទ្រង់ហើយ។

រ៉ូម ៥:១០-១១

ថ្ងៃទី២៣

# អំណោយរបស់ព្រះដែលមិនអាចពិពណ៌នាបាន

តើយើងបានទទួលការផ្សះផ្សា និងក្ដីអំណរដ៏ពោរពេញក្នុងព្រះដោយរបៀបណា? ជាការពិតណាស់ យើងទទួលតាមរយៈព្រះយេស៊ូវគ្រីស្ទ។ បានសេចក្ដីថា យ៉ាងហោចណាស់ យើងបានធ្វើឲ្យរូបភាពនៃព្រះយេស៊ូវ ក្នុងព្រះគម្ពីរដែលជាព្រះរាជកិច្ច និងព្រះបន្ទូលព្រះយេស៊ូវក្នុងព្រះគម្ពីរសញ្ញាថ្មីក្លាយជាមូលហេតុដ៏សំខាន់ ដែលយើងមានអំណរចំពោះព្រះ។ ការមានអំណរក្នុងព្រះ ដោយមិនបានគិតដល់ព្រះគ្រីស្ទ គឺមិនបានថ្វាយព្រះកិត្តិនាមដល់ព្រះគ្រីស្ទឡើយ។ ការមិនថ្វាយព្រះកិត្តិនាមដល់ព្រះគ្រីស្ទ គឺជាការមិនបានថ្វាយព្រះកិត្តិនាមដល់ព្រះ។

ក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៤:៤-៦ សាវ័ក ប៉ុល បាន

ពិពណ៌នា អំពីការផ្លាស់ប្រែ តាមរបៀបពីរយ៉ាង។ ក្នុងខ៤ គាត់មានប្រសាសន៍ថា ការផ្លាស់ប្រែ គឺជាការមើលឃើញ «សិរីល្អនៃព្រះគ្រីស្ទ ដែលជារូបអង្គព្រះ»។ ហើយក្នុងខ៦ គាត់ថា ការផ្លាស់ប្រែ ជាការស្គាល់ «សិរីល្អរបស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ»។ ក្នុងករណីទាំងពីរនេះ យើងអាចយល់បានថា យើងមានព្រះគ្រីស្ទ ជារូបអង្គនៃព្រះ ហើយយើងមានព្រះ នៅលើព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ។

ដើម្បីមានអំណរក្នុងព្រះ យើងត្រូវមានអំណរ ក្នុងការអ្វីដែលយើងមើលឃើញ និងដឹងអំពីព្រះ ក្នុងរូបអង្គនៃព្រះយេស៊ូវគ្រីស្ទ។ ហើយយើងបានពិសោធន៍យ៉ាងពេញលេញបំផុតនឹងការនេះ ពេលដែលក្តីស្រឡាញ់របស់ព្រះបានបង្ហូរចូលក្នុងចិត្តយើង ដោយព្រះវិញ្ញាណបរិសុទ្ធ គឺដូចដែលកណ្ឌគម្ពីររ៉ូម ៥:៥ បានចែង។ ការពិសោធន៍នឹងសេចក្តីស្រឡាញ់របស់ព្រះ គឺការពិសោធន៍ដ៏ផ្អែមល្ហែម ដែលព្រះវិញ្ញាណបានប្រទានកើតមានចំពោះយើង ពេលដែលយើងជញ្ជឹងគិត អំពីការពិតជាប្រវត្តិសាស្រ្ត នៃខ៦ ដែលបានចែងថា «ដ្បិតកាលយើងនៅខ្សោយនៅឡើយ លុះដល់កំណត់ហើយ នោះព្រះគ្រីស្ទទ្រង់បានសុគតជំនួសមនុស្សទមិលល្មើស»។

ដូចនេះ ចំណុចសំខាន់នៃបុណ្យណូអែលនោះគឺ ព្រះទ្រង់មិនគ្រាន់តែបានទិញការផ្សះផ្សា តាមរយៈការសុគតនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទប៉ុណ្ណោះទេ (រ៉ូម ៥:១០) ហើយព្រះទ្រង់មិនគ្រាន់តែបានជួយឲ្យយើងអាចទទួលការផ្សះផ្សានោះ តាមរយៈព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះទេ តែសូម្បីតែពេលសព្វថ្ងៃនេះ យើងថែមទាំងបានអរសប្បាយក្នុងព្រះ ដោយព្រះវិញ្ញាណបរិសុទ្ធ តាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង (រ៉ូម ៥:១១)។

*ព្រះយេស៊ូវបានបង់ថ្លៃទិញការផ្សះផ្សា។* ព្រះយេស៊ូវធ្វើឲ្យយើងអាចទទួលការផ្សះផ្សា និងបើកយកអំណោយនោះ។ ព្រះយេស៊ូវផ្ទាល់បញ្ចេញពន្លឺ ក្នុងនាមជាអំណោយដែលមិនអាចពិពណ៌នាបាន គឺព្រះដែលគង់ក្នុងសាច់ឈាម និងបណ្តាលចិត្តយើងឲ្យមានអំណរគ្រប់យ៉ាងក្នុងព្រះ។

ចូរយើងមើលទៅព្រះគ្រីស្ទ ក្នុងរដូវកាលនៃបុណ្យណូអែលឆ្នាំនេះ។ ចូរយើងទទួលការផ្សះផ្សាដែលព្រះអង្គបានបង់ថ្លៃទិញ។ ចូរកុំទុកអំណោយនេះនៅលើធ្នើរ ដោយមិនបានបើកប្រើនោះឡើយ។ ហើយពេលណាលោកអ្នកបើកអំណោយនេះ ចូរចាំថា ព្រះទ្រង់ផ្ទាល់ជាអំណោយ នៃការផ្សះផ្សាជា

មួយព្រះ។

ចូរមានអំណរក្នុងព្រះអង្គ។ ចូរពិសោធន៍នឹងព្រះអង្គ ដោយទទួលព្រះអង្គជាក្តីអំណររបស់អ្នក។ ចូរទទួលស្គាល់ថា ព្រះអង្គជាកំណប់ទ្រព្យរបស់អ្នក។

# ថ្ងៃទី២៤

*កូនតូចៗ រាល់គ្នាអើយ ចូរកុំឲ្យអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេង
ឡើយ អ្នកណាដែលប្រព្រឹត្តសេចក្តីសុចរិត នោះឈ្មោះថា
សុចរិតហើយ ដូចជាទ្រង់ក៏សុចរិតដែរ តែអ្នកណាដែលប្រព្រឹត្ត
អំពើបាបវិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាប
ចាប់តាំងពីដើមរៀងមក ដោយហេតុនោះបានជាព្រះរាជបុត្រា
នៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ។*

១យ៉ូហាន ៣:៧-៨

ថ្ងៃទី២៨

# គោលបំណងទាំងពីរនៃបុណ្យណូអែល

កណ្ឌគម្ពីរ ១យ៉ូហាន ៣:៨ បានចែងថា «ព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ» ដូចនេះ ក្នុងកណ្ឌគម្ពីរនេះ តើ «ការរបស់អារក្ស» មានអ្វីខ្លះ? យើងអាចរកឃើញចម្លើយដ៏ច្បាស់លាស់ ពីបរិបទនៃខគម្ពីរនេះ។

ទី១ កណ្ឌគម្ពីរ ១យ៉ូហាន ៣:៥ គឺពិតជាបានចែងស្របនឹងខគម្ពីរនេះផងដែរថា «ទ្រង់បានលេចមក ដើម្បីនឹងដោះបាបយើងចេញ ហើយក៏នៅក្នុងទ្រង់ នោះគ្មានបាបសោះ»។ ឃ្លា *«ទ្រង់បានលេចមក»* គឺមានក្នុងខ៥ និងខ៨ ដូចគ្នា។ ដូចនេះ ដែលទំនងបំផុតនោះ គឺ «ការរបស់អារក្ស» ដែលព្រះយេស៊ូវបានយាងមកបំផ្លាញ គឺជាអំពើបាប។ ផ្នែកដំបូងនៃខ៨ បាន

បញ្ជាក់ច្បាស់ថា «អ្នកណាដែលប្រព្រឹត្ត*អំពើបាប*វិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាប ចាប់តាំងពីដើមរៀងមក»។

បញ្ហាក្នុងបរិបទនេះ គឺ*ការធ្វើអំពើបាប* មិនមែនជម្ងឺ ឬឡានខូច ឬក៏កាលបរិច្ឆេទដ៏រញ៉េរញ៉ៃនោះទេ។ ព្រះយេស៊ូវបានយាងចុះមកក្នុងលោកីយ៍នេះ ដើម្បីជួយយើង ឲ្យឈប់ប្រព្រឹត្តអំពើបាប។

យើងយល់កាន់តែច្បាស់ បើសិនជាយើងដាក់សេចក្តីពិតនេះ ទន្ទឹមនឹងសេចក្តីពិត ក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ២:១ ដែលបានចែងថា «កូនតូចៗ រាល់គ្នាអើយ ដែលខ្ញុំសរសេរសេចក្តីទាំងនេះផ្ញើមក *នោះដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត*» (១យ៉ូហាន ៣:៨)។ គោលបំណងនេះ ស្ថិតក្នុងចំណោមគោលបំណងសំខាន់ៗនៃពិធីបុណ្យណូអែល និយាយរួម គឺស្ថិតក្នុងចំណោមមូលហេតុដ៏សំខាន់ ដែលព្រះយេស៊ូវបានយាងមកចាប់កំណើតជាមនុស្ស (១យ៉ូហាន ៣:៨)។

ប៉ុន្តែ មានគោលបំណងមួយទៀត ដែលលោក យ៉ូហាន បានលើកឡើង ក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ២:១-២ ដែលបានចែងថា «បើសិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះ

ដ៏ជាជំនួយ១អង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត ដែលទ្រង់ជាដង្វាយធួននឹងបាបយើងរាល់គ្នា មិនត្រឹមតែបាបរបស់យើងរាល់គ្នាតែប៉ុណ្ណោះ គឺនឹងបាបរបស់លោកីយ៍ទាំងមូលដែរ»។

បានសេចក្តីថា ព្រះយេស៊ូវបានលេចឡើង ក្នុងពិភពលោកនេះ ដោយសារមូលហេតុពីរយ៉ាង។ ព្រះអង្គបានយាងមកដើម្បីកុំឲ្យយើងបន្តធ្វើបាបទៀត ពោលគឺ ព្រះអង្គបានមកដើម្បីបំផ្លាញកិច្ចការរបស់អារក្ស (១យ៉ូហាន ៣:៨) ហើយព្រះអង្គបានយាងមក ដើម្បីឲ្យមានដង្វាយធួននឹងបាបយើងរាល់គ្នា។ និយាយរួម ព្រះអង្គបានយាងមកធ្វើជាដង្វាយជំនួស ដើម្បីដកសេចក្តីក្រោធ ដែលព្រះទ្រង់មានមកលើអំពើបាបរបស់យើង។

លទ្ធផលនៃគោលបំណងទី២ គឺមិនបានធ្វើឲ្យគោលបំណងទី១គ្មានន័យនោះទេ។ ការអត់ទោសបាប មិនមែនដើម្បីអនុញ្ញាតឲ្យមនុស្សបន្តធ្វើអំពើបាបនោះទេ។ គោលបំណងនៃការសុគតរបស់ព្រះគ្រីស្ទ ដើម្បីលោះបាបយើង គឺមិនមែនដើម្បីឲ្យយើងបន្ធូរដៃ ក្នុងការប្រយុទ្ធនឹងអំពើបាបនោះឡើយ។ ផ្ទុយទៅវិញ លទ្ធផលនៃគោលបំណងទាំងពីរនៃបុណ្យណូអែល គឺដើម្បីឲ្យការបង់ថ្លៃម្តងជាសម្រេច ដើម្បីលោះ

អំពើបាបទាំងអស់របស់យើង នាំមកនូវសេរីភាព និងអំណាច ដែលជួយឲ្យយើងអាចតយុទ្ធនឹងអំពើបាប មិនមែនតាមបែប មនុស្សក្រឹត្យវិន័យនិយម ដែលខំប្រព្រឹត្តល្អឲ្យបានសង្គ្រោះ និង មិនមែនដោយការខ្លាចបាត់សេចក្ដីសង្គ្រោះនោះទេ តែក្នុងនាម ជាអ្នកមានជ័យជម្នះ ដែលបានតយុទ្ធនឹងអំពើបាប ដោយការ ទុកចិត្ត និងក្ដីអំណរ ទោះយើងត្រូវបាត់បង់ជីវិតក៏ដោយ។

# ថ្ងៃទី២៥

*កូនតូចៗ រាល់គ្នាអើយ ដែលខ្ញុំសរសេរសេចក្តីទាំងនេះផ្ញើមក នោះដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត តែបើសិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយ១អង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត ដែលទ្រង់ជាដង្វាយធួននឹងបាបយើងរាល់គ្នា មិនត្រឹមតែបាបរបស់យើងរាល់គ្នាតែប៉ុណ្ណោះ គឺនឹងបាបរបស់លោកីយ៍ទាំងមូលដែរ...កូនតូចៗ រាល់គ្នាអើយ ចូរកុំឲ្យអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេងឡើយ អ្នកណាដែលប្រព្រឹត្តសេចក្តីសុចរិត នោះឈ្មោះថាសុចរិតហើយ ដូចជាទ្រង់ក៏សុចរិតដែរ តែអ្នកណាដែលប្រព្រឹត្តអំពើបាបវិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាប ចាប់តាំងពីដើមរៀងមក ដោយហេតុនោះបានជាព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ។*

១យ៉ូហាន ២:១-២; ៣:៧-៨

ថ្ងៃទី២៥

# អំណោយទាំងបីនៃថ្ងៃណូអែល

សូមពិចារណាអំពីលក្ខខណ្ឌដ៏គួរឲ្យកត់សម្គាល់នេះជាមួយខ្ញុំ។ ព្រះរាជបុត្រានៃព្រះបានយាងមក ដើម្បីជួយឲ្យអ្នកឈប់ប្រព្រឹត្តអំពើបាបគឺដើម្បីបំផ្លាញកិច្ចការរបស់អារក្ស—ហើយព្រះអង្គក៏បានសុគត ដើម្បីកាលណាអ្នកមានបាប នោះមានដង្វាយធួននឹងបាប ដែលជាការដោះសេចក្តីក្រោធរបស់ព្រះ ដូចនេះ តើសេចក្តីពិតនេះមានន័យយ៉ាងណាសម្រាប់ការរស់នៅរបស់អ្នក?

គឺមានសេចក្តី៣យ៉ាង ដ៏អស្ចារ្យដែលយើងត្រូវមាន។ សេចក្តី៣យ៉ាងនោះ ជាអំណោយបុណ្យណូអែល ដែលខ្ញុំសូមបកស្រាយដោយសង្ខេបដូចតទៅ៖

## *អំណោយទី១៖ គោលបំណងច្បាស់លាស់ សម្រាប់ការរស់នៅ៖*

អត្ថប្រយោជន៍ទី១ គឺយើងមានគោលបំណងច្បាស់លាស់ សម្រាប់ការរស់នៅ។ យើងអាចនិយាយឲ្យសាមញ្ញ ជាលក្ខណបំរាមថា៖ ចូរកុំធ្វើអំពើបាប ចូរកុំធ្វើការអ្វីដែលមិនថ្វាយព្រះកិត្តិនាមដល់ព្រះ។ ដូចមានសេចក្ដីចែងថា “ខ្ញុំសរសេរសេចក្ដីទាំងនេះផ្ញើមក នោះដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត” (១យ៉ូហាន ២:១)។ ហើយ “ព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ” (១យ៉ូហាន ៣:៨)។

បើអ្នកសួរថា “តើយើងអាចទទួលអំណោយនេះ ជាលក្ខណៈវិជ្ជមាន ជាជាងជាលក្ខណៈបំរាមបានដែរឬទេ?” ចម្លើយនោះគឺ “បាទ យើងអាចទទួលអំណោយនេះ ជាលក្ខណៈវិជ្ជមានបាន ផ្អែកទៅលើ ការសង្ខេបនៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ៣:២៣”។ នេះជាការសង្ខេបដ៏អស្ចារ្យ នូវខ្លឹមសារនៃសំបុត្ររបស់លោក យ៉ូហាន ទាំងមូល ដែលបង្រួមមកត្រឹម *“ព្រះរាជបញ្ញា”* តែមួយ ដូចមានសេចក្ដីចែងថា “ឯ*បញ្ញត្ត*ទ្រង់នោះ គឺថា ត្រូវឲ្យយើងជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ហើយត្រូវស្រឡាញ់គ្នាទៅវិញ

ទៅមក ដូចជាទ្រង់បានបង្គាប់មកហើយ»។ ព្រះរាជបញ្ញត្តិទាំងពីរនេះមានការជាប់ទាក់ទងគ្នាយ៉ាងខ្លាំង បានជាលោកយ៉ូហាន បានហៅចំណុចទាំងពីរថា ព្រះរាជបញ្ញត្តិតែមួយ ដែលបង្គាប់ឲ្យជឿព្រះយេស៊ូវ និងស្រឡាញ់អ្នកដទៃ។ នេះជាគោលបំណងដែលអ្នកត្រូវមាន។ ជីវិតជាគ្រីស្ទបរិស័ទត្រូវបានសង្ខេបមកត្រឹមនេះ។ គឺជឿព្រះយេស៊ូវ និងស្រឡាញ់អ្នកដទៃ ដូចដែលព្រះយេស៊ូវ និងពួកសាវ័កទ្រង់បានបង្រៀនយើងឲ្យស្រឡាញ់។ ត្រូវជឿព្រះយេស៊ូវ ស្រឡាញ់អ្នកដទៃ។ នេះជាអំណោយទីមួយ ជាគោលបំណងនៃការរស់នៅរបស់យើង។

## អំណោយទី២៖ ជាការមានសង្ឃឹមថា កំហុសរបស់យើង នឹងត្រូវបានអត់ទោសឲ្យ

អត្ថប្រយោជន៍ទី២ ដែលយើងទទួលបានពីសេចក្តីពិតដែលមានពីរផ្នែក (គឺការដែលព្រះគ្រីស្ទបានយាងមក ដើម្បីបំផ្លាញការប្រព្រឹត្តអំពើបាបរបស់យើង និងដើម្បីអត់ទោសឲ្យអំពើបាបរបស់យើង) នោះយើងមានការរីកចម្រើន ក្នុងការជម្នះអំពើបាបរបស់យើង ពេលដែលយើងសង្ឃឹមថា ព្រះអង្គនឹងអត់ទោសបាបឲ្យយើង។ បើអ្នកមិនមានសង្ឃឹមថា ព្រះទ្រង់នឹង

អត់ទោសបាបឲ្យអ្នកទេ នោះពេលណាអ្នកចាប់ផ្ដើមតយុទ្ធនឹងអំពើបាប អ្នកក៏បោះបង់ចោលការតស៊ូទាំងនោះ។

មនុស្សជាច្រើនកំពុងតែជញ្ជឹងគិត អំពីការផ្លាស់ប្ដូរមួយចំនួន ក្នុងឆ្នាំថ្មី ព្រោះពួកគេបានធ្លាក់ចូលក្នុងគំរូនៃការប្រព្រឹត្តអំពើបាបដដែលៗ ហើយចង់ចាកចេញពីអំពើបាបនោះ។ អ្នកចង់បានគំរូថ្មីៗ សម្រាប់ការញាំអាហារ។ គំរូថ្មីៗសម្រាប់ការកម្សាន្តសប្បាយ។ គំរូថ្មីៗសម្រាប់ការចែករំលែក។ គំរូថ្មីៗសម្រាប់ទំនាក់ទំនងប្ដីប្រពន្ធ។ គំរូថ្មីៗសម្រាប់ការថ្វាយបង្គំព្រះជាលក្ខណៈគ្រួសារ។ គំរូថ្មីៗសម្រាប់ការគេង និងហាត់ប្រាណ។ គំរូថ្មីៗនៃចិត្តក្លាហាន ក្នុងការធ្វើបន្ទាល់។ ប៉ុន្តែអ្នកមានការពិបាក ដោយឆ្ងល់ថា តើគំរូថ្មីៗទាំងនោះមានប្រយោជន៍ឬអត់ទេ។ ទោះជាយ៉ាងណាក៏ដោយ អំណោយទី២នៃបុណ្យណូអែលនោះគឺ ព្រះគ្រីស្ទមិនគ្រាន់តែបានយាងមក ដើម្បីបំផ្លាញកិច្ចការរបស់អារក្ស ដែលជាការប្រព្រឹត្តអំពើបាបរបស់យើងប៉ុណ្ណោះទេ តែព្រះអង្គក៏បានមក ដើម្បីធ្វើជាជំនួយ សម្រាប់យើង ដោយសារយើងជួបការភ្លាត់ដួល ក្នុងការតយុទ្ធនឹងអំពើបាប។

ការភ្លាត់ដួល ក្នុងការតយុទ្ធនឹងអំពើបាប គឺមិនមានន័យថា

យើងត្រូវឈប់តយុទ្ធនោះទេ ហេតុនេះហើយ ខ្ញុំសូមលើកទឹកចិត្តអ្នកថា ចូរមានសង្ឃឹមក្នុងការតយុទ្ធនឹងអំពើបាប ដោយផ្តោតទៅលើការពិតនេះ។ ប៉ុន្តែ ត្រូវមានការប្រុងប្រយ័ត្ន! បើអ្នកចាត់ទុកព្រះគុណរបស់ព្រះ ជាប័ណ្ណអនុញ្ញាត ហើយនិយាយថា «បើខ្ញុំអាចភ្លាត់ដួល ហើយវាមិនជាបញ្ហាអ្វីទេ នោះតើខ្ញុំចាំបាច់ត្រូវតយុទ្ធនឹងអំពើបាបធ្វើអ្វី?» បើអ្នកនិយាយដូចនេះ ចេញពីចិត្តមែន ហើយបន្តធ្វើអ្វីដែលបាននិយាយទៀត នោះមានន័យថា អ្នកមិនបានកើតជាថ្មីទេ ហើយគួរតែភ័យញ័រ នៅចំពោះព្រះ។

ប៉ុន្តែ មនុស្សភាគច្រើនមិនមានចិត្តដូចនេះទេ។ មនុស្សភាគច្រើនចង់តយុទ្ធនឹងគំរូនៃការប្រព្រឹត្តអំពើបាបដដែលៗក្នុងជីវិតរបស់ខ្លួន។ ហើយព្រះទ្រង់កំពុងមានបន្ទូលមកកាន់អ្នកថា ចូរមានសង្ឃឹម ក្នុងការតយុទ្ធនេះ ដោយដឹងថា ព្រះគ្រីស្ទបានគ្របបាំងការភ្លាត់ដួលរបស់អ្នកហើយ។ គឺដូចមានសេចក្តីចែងថា «ខ្ញុំសរសេរសេចក្តីទាំងនេះផ្ញើមក នោះដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត តែបើសិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយ១អង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត»។

*អំណោយទី៣៖ ព្រះគ្រីស្ទនឹងជួយយើង*

ជាចុងក្រោយ អត្ថប្រយោជន៍ទី៣ ដែលយើងទទួលបានពីសេចក្ដីពិតដែលមានពីរផ្នែក (គឺការដែលព្រះគ្រីស្ទបានយាងមក ដើម្បីបំផ្លាញការប្រព្រឹត្តអំពើបាបរបស់យើង និងដើម្បីអត់ទោសបាបឲ្យយើង) នោះគឺថា ព្រះគ្រីស្ទនឹង*ជួយ*យើងនៅក្នុងការតយុទ្ធរបស់យើង។ ព្រះអង្គពិតជានឹងជួយយើងមែន។ ព្រះអង្គកាន់ខាងយើង។ ព្រះអង្គបានមកដើម្បីបំផ្លាញអំពើបាប មិនមែនដោយសារការតយុទ្ធនឹងអំពើបាបគឺជារឿងដែលសប្បាយនោះទេ។ ព្រះអង្គយាងមកបំផ្លាញអំពើបាប គឺដោយសារអំពើបាបនាំឲ្យស្លាប់។ វាជាកិច្ចការដ៏ពិសពុលរបស់អារក្ស ហើយវានឹងបំផ្លាញយើង បើយើងមិនតយុទ្ធនឹងវាទេនោះ។ តែព្រះអង្គបានមកដើម្បីជួយយើង មិនមែនដើម្បីធ្វើឲ្យយើងឈឺចាប់នោះឡើយ។

ដូចនេះ អំណោយទី៣សម្រាប់អ្នក នៅថ្ងៃបុណ្យណូអែលនោះគឺ ព្រះគ្រីស្ទនឹងជួយឲ្យអ្នកឈ្នះអំពើបាប ក្នុងជីវិតអ្នក។ កណ្ឌគម្ពីរ ១យ៉ូហាន ៤:៤ បានចែងថា “ព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះ ដែលនៅក្នុងលោកីយ៍ផង”។

ព្រះយេស៊ូវមានព្រះជន្មរស់ ព្រះយេស៊ូវមានគ្រប់ចេស្ដា ព្រះយេស៊ូវគង់នៅក្នុងយើង ដោយសារយើងជឿព្រះអង្គ។ ហើយព្រះយេស៊ូវកាន់ខាងយើង គឺមិនទាស់នឹងយើងទេ។ ព្រះអង្គនឹងជួយអ្នកតយុទ្ធនឹងអំពើបាប ក្នុងឆ្នាំថ្មីនេះ។

# ការសន្និដ្ឋាន

## ការសន្និដ្ឋាន

# កណ្ឌាគម្ពីរស្ដីអំពីបុណ្យណូអែល ដែលខ្ញុំចូលចិត្តជាងគេ

កណ្ឌាគម្ពីរស្ដីអំពីបុណ្យណូអែល ដែលខ្ញុំចិត្តជាងគេ បានចាត់ទុកការបន្ទាបខ្លួន ជាចំណុចស្នូលនៃបុណ្យណូអែល។ ហេតុនេះហើយ ក្នុងរដូវកាលនៃបុណ្យអែលឆ្នាំនេះ ខ្ញុំមានការស្ញប់ស្ញែង ចំពោះការបន្ទាបព្រះកាយរបស់ព្រះយេស៊ូវ ហើយខ្ញុំចង់ឲ្យខ្លួនខ្ញុំមានការបន្ទាបខ្លួនកាន់តែខ្លាំងថែមទៀត។ បន្តិចទៀត ខ្ញុំនឹងដកស្រង់អត្ថបទ ដែលនិយាយអំពីប្រធានបទនេះ។

ប៉ុន្តែ ជាបឋម ខ្ញុំសូមលើកយកបញ្ហាពីរយ៉ាងមកនិយាយ។ លោក ធីម ឃែល័រ (Tim Keller ) បានជួយពន្យល់ អំពីបញ្ហាមួយ ក្នុងចំណោមបញ្ហាទាំងពីរនេះ យ៉ាងដូចនេះថា “ការបន្ទាបខ្លួន មានភាពខ្មាសអៀនខ្លាំងណាស់។ បើអ្នកចាប់ផ្ដើម

និយាយអំពីវា វាក៏ចាកចេញពីអ្នក»។ ដូចនេះ ការជញ្ជឹងគិតអំពីការបន្ទាបខ្លួន (ដែលមានលក្ខណៈដូចនេះ) គឺហាក់ដូចជាពិបាកណាស់។ ប៉ុន្តែ ជួនកាល សូម្បីតែមនុស្សដែលអៀនខ្លាំង ក៏អើតក្បាលចេញមកដែរ បើសិនជា ពេលខ្លះ អ្នកដទៃបានធ្វើល្អ ចំពោះពួកគេ។

បញ្ហាមួយទៀត គឺស្ថិតនៅត្រង់ថា ព្រះយេស៊ូវមិនបានបន្ទាបព្រះកាយ ដោយសារព្រះអង្គមានហេតុផលដូចយើង (ឬដូចហេតុផល ដែលយើងគួរបន្ទាបខ្លួន) នោះទេ។ ដូចនេះ តើការមើលទៅការបន្ទាបព្រះកាយរបស់ព្រះយេស៊ូវ ក្នុងបុណ្យណូអែល អាចមានប្រយោជន៍ចំពោះ*យើង* យ៉ាងណាខ្លះ? ការបន្ទាបខ្លួនរបស់យើង បើសិនជាមានមែន គឺផ្អែកទៅលើលក្ខណៈសម្បត្តិរបស់យើង ដែលមានដែនកំណត់ ងាយជំពប់ដួល និងជាមនុស្សមានបាប។ តែព្រះអង្គមិនជំពប់ដួលឡើយ ហើយព្រះអង្គក៏មិនមានបាប។ ដូចនេះ ការបន្ទាបព្រះកាយរបស់ព្រះយេស៊ូវកើតមាន តាមរបៀបខុសពីការបន្ទាបខ្លួនរបស់យើង។

ខាងក្រោមនេះ ជាកណ្ឌគម្ពីរសម្រាប់បុណ្យណូអែលដែលខ្ញុំចូលចិត្ត។ ចូរមើលទៅការបន្ទាបព្រះកាយរបស់ព្រះយេស៊ូវ

ក្នុងកណ្ឌគម្ពីរខាងក្រោមនេះ៖

*ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបម្រើ វិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់ឈើឆ្កាងផង (ភីលីព ២:៦-៨)។*

យើងអាចយល់អត្ថន័យនៃការបន្ទាបព្រះកាយរបស់ព្រះយេស៊ូវ ផ្អែកទៅលើការពិតដែលថា ការបន្ទាបព្រះកាយព្រះអង្គ គឺជាការស្ម័គ្រព្រះទ័យដាក់ព្រះកាយព្រះអង្គ នៅក្នុងតួនាទីជាអ្នកបម្រើ ដ៏តូចទាប ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ។ គេអាចបកស្រាយអត្ថន័យនៃការបន្ទាបព្រះកាយព្រះអង្គ ដោយប្រើឃ្លាដូចតទៅ៖

*«ព្រះអង្គលះបង់សិទ្ធិរបស់ព្រះអង្គដែលជាព្រះ [គឺសិទ្ធិរួចផុតពីការធ្វើទុក្ខបុកម្នេញ និងការរងទុក្ខវេទនា]»។*

*«ព្រះអង្គទទួលយកភាពជាអ្នកបម្រើ»។*

*«ព្រះអង្គស្ដាប់បង្គាប់ព្រះវរបិតា រហូតដល់សុគត គឺសូម្បីតែការសុគតនៅលើឈើឆ្កាង»។*

ដូចនេះ ព្រះយេស៊ូវបន្ទាបព្រះកាយ មិនមែនដោយសារព្រះទ័យព្រះអង្គបានយល់ឃើញថា ព្រះអង្គមានដែនកំណត់ ឬងាយជំពប់ដួល ឬក៏មានបាបនោះទេ។ ផ្ទុយទៅវិញ ព្រះទ័យព្រះអង្គមានភាពល្អឥតខ្ចោះគ្មានដែនកំណត់ និងមានភាពពិតត្រង់ដែលមិនចេះជំពប់ដួល ហើយរួចផុតពីបាបទាំងអស់ ហេតុនេះហើយ ព្រះអង្គមិនត្រូវការឲ្យគេបម្រើព្រះអង្គឡើយ។ ព្រះអង្គមានសេរីភាពពេញលេញ នៅក្នុងការបម្រើយ៉ាងហូរហៀរ។

កណ្ឌគម្ពីរសម្រាប់បុណ្យណូអែលមួយទៀត ដែលនិយាយអំពីសេចក្តីនេះដែរ គឺកណ្ឌគម្ពីរ ម៉ាកុស ១០:៤៥៖ “ដ្បិតកូនមនុស្សបានមក *មិនមែនឲ្យគេបម្រើ* ដែរ គឺ*ដើម្បីនឹងបម្រើគេវិញ* ហើយនិងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង”។ ការបន្ទាបព្រះកាយរបស់ព្រះយេស៊ូវ មិនមែនជាការយល់ឃើញថា អង្គទ្រង់មានភាពខ្វះចន្លោះនោះទេ តែដោយសារព្រះអង្គជ្រាបថា ព្រះអង្គមានភាពពេញលេញ ដែលត្រូវលះបង់ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ។ នេះជាការបន្ទាបព្រះកាយ ដោយ

ស្ម័គ្រព្រះទ័យ ដើម្បីឲ្យមនុស្សមានបាបបានអរសប្បាយនឹងសិរីល្អរបស់ព្រះអង្គ។

ព្រះយេស៊ូវបានតភ្ជាប់ទំនាក់ទំនង រវាងភាពតូចទាបរបស់ព្រះអង្គនៅថ្ងៃណូអែល និងដំណឹងល្អសម្រាប់យើងរាល់គ្នាដោយមានបន្ទូលថា «អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សម្រាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយ*មានចិត្តសុភាព* នោះអ្នករាល់គ្នានឹងបានសេចក្ដីសម្រាកដល់ព្រលឹង ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល» (ម៉ាថាយ ១១:២៨-៣០)។

ភាពតូចទាបរបស់ព្រះអង្គធ្វើឲ្យបន្ទុកយើងអាចមានភាពធូរស្រាល។ បើព្រះអង្គមិនតូចទាបទេ នោះព្រះអង្គក៏មិនបាន «ចុះចូលស្ដាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់ឈើឆ្កាង» នោះឡើយ។ ហើយបើព្រះអង្គមិនស្ដាប់បង្គាប់ព្រះវរបិតា ដើម្បីសុគតជំនួសយើងទេ នោះយើងនឹងត្រូវវិនាសនៅក្រោមទម្ងន់នៃបាបរបស់យើង។ ព្រះអង្គបន្ទាបព្រះកាយដើម្បីទទួលទោសរបស់យើង (រ៉ូម ៨:៣)។

ដូចនេះ យើងមានហេតុផលកាន់តែច្រើន ដែលត្រូវបន្ទាប

ខ្លួន។ យើងមានដែនកំណត់ ងាយជំពប់ដួល និងមានបាប ដូចនេះ គ្មានហេតុផលដែលត្រូវអួតខ្លួនទេ។ តែឥឡូវនេះ យើងឃើញរឿងផ្សេងដែលធ្វើឲ្យយើងបន្ទាបខ្លួន នោះគឺថា៖ សេចក្តីសង្រ្គោះរបស់យើង មិនអាស្រ័យទៅលើការប្រព្រឹត្តរបស់យើងទេ តែអាស្រ័យទៅលើព្រះគុណទ្រង់។ ដូចនេះ យើងមិនអាចអួតអំពីការប្រព្រឹត្តរបស់យើងបានទេ (អេភេសូរ ២:៨-៩)។ ហើយព្រះអង្គបានសម្រេចនូវសេចក្តីសង្រ្គោះប្រកបដោយព្រះគុណនោះ តាមរយៈការបន្ទាបព្រះកាយ ដោយស្ម័គ្រព្រះទ័យ ដោយការស្តាប់បង្គាប់ដូចអ្នកបម្រើ រហូតដល់ទីមរណៈ។

ដូចនេះ ក្រៅពីភាពមានដែនកំណត់ ភាពងាយជំពប់ដួល និងភាពមានបាប ឥឡូវនេះ យើងមានកត្តាជំរុញចិត្តធំៗពីរផ្សេងទៀត ដែលនាំឲ្យយើងបន្ទាបខ្លួននោះគឺ៖ ទី១ ព្រះគុណដែលយើងមិនសមទទួល ហើយព្រះបានប្រទានដោយឥតគិតថ្លៃ នៅក្រោមព្រះពរទាំងអស់ដែលយើងបានទទួល និងទី២ គំរូនៃភាពជាអ្នកបម្រើ ដែលបដិសេធខ្លួនឯង និងមានការលះបង់ ដែលស្ម័គ្រចិត្តយកភាពជាអ្នកបម្រើ។

ដូចនេះ ព្រះយេស៊ូវត្រាស់ហៅយើង ឲ្យចូលរួមជាមួយព្រះអង្គ ក្នុងភាពជាអ្នកបម្រើ ដែលដឹងខ្លួន និងបន្ទាបខ្លួន។ ដូច

មានសេចក្ដីចែងថា “អ្នកណាដែលតម្កើងខ្លួន នោះនឹងត្រូវបន្ទាបចុះវិញ ហើយអ្នកណាដែលបន្ទាបខ្លួន នោះនឹងបានតម្កើងឡើង” (ម៉ាថាយ ២៣:១២)។ “ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ...” (ភីលីព ២:៥)។

ចូរយើងអធិស្ឋានសូមឲ្យ “គុណធម៌ដែលអៀនខ្លួន”នេះ ដែលជាមូលដ្ឋានដ៏ធំធេង នៃសេចក្ដីសង្គ្រោះ និងភាពជាអ្នកបម្រើរបស់យើង បានអើតចេញមកពីកន្លែងដ៏ស្ងាត់ស្ងៀមរបស់ខ្លួន ហើយដណ្ដប់ខ្លួនយើង ដោយភាពតូចទាប ក្នុងរដូវកាលរង់ចាំ នៃបុណ្យណូអែលឆ្នាំនេះ។ “ត្រូវឲ្យគ្រប់គ្នាមានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្ដល់ព្រះគុណដល់ពួករាបសាវិញ” (១ពេត្រុស ៥:៥)។

# សេចក្ដីបន្ថែម

## សេចក្ដីបន្ថែម

# ស្រមោលនៃសេចក្ដីសញ្ញាចាស់ និងការយាងមកនៃព្រះគ្រីស្ទ

ចំណុចសំខាន់មួយ ក្នុងចំណោមចំណុចសំខាន់ទាំងឡាយនៃកណ្ឌគម្ពីរហេព្រើរនោះគឺថា ប្រព័ន្ធនៃការថ្វាយបង្គំ តាមសេចក្ដីសញ្ញាចាស់ គឺជាស្រមោល ដែលត្រូវបានជំនួសដោយព្រះគ្រីស្ទ។ ដូចនេះ បុណ្យណូអែល គឺបានជំនួសស្រមោល ដោយការពិត។ (អ្នកអាចឃើញសេចក្ដីនេះក្នុងកណ្ឌគម្ពីរ ហេព្រើរ ៨:៥ ត្រង់ចំណុចដែលចែងថា ពួកសង្ឃ “*ជាគំរូ ហើយជាស្រមោល* ពីរបស់នៅស្ថានសួគ៌វិញ”)។ សូមពិចារណា អំពីស្រមោលទាំង៦ ដែលការយាងមកនៃព្រះគ្រីស្ទបានជំនួស ដោយការពិត។

១. *ស្រមោលនៃភាពជាសង្ឃ នៃសេចក្តីសញ្ញាចាស់។*
មួយទៀត ពួកសង្ឃទាំងនោះមានគ្នាជាច្រើន ពីព្រោះគេតែងតែស្លាប់ មិននៅជាប់ស្ថិតស្ថេរទេ តែទ្រង់មានការងារជាសង្ឃឥតផ្ទេរឡើយ ពីព្រោះទ្រង់នៅជាប់អស់កល្បជានិច្ចវិញ (ហេព្រើរ ៧:២៣-២៤)។

២. *ស្រមោលរបស់ដង្វាយនៃបុណ្យរំលង។*
ចូរសម្អាតដំបែរចាស់ចេញ ដើម្បីឲ្យអ្នករាល់គ្នាបានត្រឡប់ជាដុំម្សៅថ្មីវិញ ដ្បិតអ្នករាល់គ្នាបានឥតដំបែហើយ ព្រោះព្រះគ្រីស្ទដ៏ជាយញ្ញបូជានៃបុណ្យរំលង នោះបានត្រូវថ្វាយជំនួសយើងរាល់គ្នាហើយ (១កូរិនថូស ៥:៧)។

៣. *ស្រមោលរបស់រោងឧបោសថ និងព្រះវិហារ។*
រីឯ ដែល បង្រួម សេចក្តី អធិប្បាយ ទាំង ប៉ុន្មាន អម្បាញ់មិញនេះ នោះគឺថា យើងរាល់គ្នាមានសម្តេចសង្ឃ១អង្គយ៉ាងនោះ ដែលទ្រង់បានគង់ខាងស្តាំបល្ល័ង្កនៃឫទ្ធានុភាពនៅស្ថានសួគ៌ ជាអ្នកមានការងារក្នុងទីបរិសុទ្ធ ហើយក្នុងរោងឧបោសថដ៏ពិត ដែលព្រះ

អម្ចាស់បានដំឡើង មិនមែនជាមនុស្សទេ (ហេព្រើរ ៨:១-២)។

ព្រះយេស៊ូវទ្រង់ឆ្លើយទៅគេថា ចូរបំផ្លាញព្រះវិហារនេះចុះ រួចក្នុងរវាង៣ថ្ងៃ ខ្ញុំនឹងសង់ឡើងវិញ ដូច្នេះ ពួកសាសន៍យូដាទូលថា គេសង់ព្រះវិហារនេះ ពេញ៤៦ឆ្នាំគត់ តែលោកនឹងសង់ឡើងវិញ ក្នុងរវាង៣ថ្ងៃឬ ប៉ុន្តែគឺទ្រង់មានព្រះបន្ទូល*ពីព្រះវិហារ ដែលជារូបអង្គទ្រង់ទេ* (យ៉ូហាន ២:១៩-២១)។

៤. *ស្រមោលនៃការកាត់ស្បែក។*

*ព្រោះការកាត់ស្បែកមិនជាអ្វីទេ* ឬដែលមិនកាត់ស្បែកនោះក៏មិនជាអ្វីដែរ តែដែលមានប្រយោជន៍ នោះគឺស្រេចនឹងកាន់តាមបញ្ញត្តិរបស់ព្រះវិញ (១កូរិនថូស ៧:១៩)។

៥. *ស្រមោលនៃក្រឹត្យវិន័យអំពីចំណីអាហារ។*

ទ្រង់មានព្រះបន្ទូលថា តើអ្នករាល់គ្នានៅតែមិនយល់

ដែរឬអី តើអ្នករាល់គ្នានឹកមិនឃើញទេឬអីថា របស់អ្វីពីខាងក្រៅដែលចូលក្នុងមនុស្ស នោះពុំអាចនឹងធ្វើឲ្យស្មោកគ្រោកបានទេ ដ្បិតរបស់នោះមិនបានចូលទៅក្នុងចិត្ត គឺចូលទៅតែក្នុងពោះប៉ុណ្ណោះ រួចចេញទៅក្នុងបង្គន់ ដូច្នេះ *អស់ទាំងអាហារឈ្មោះថា ជារបស់ស្អាតវិញ* (ម៉ាកុស ៧:១៨-១៩)។

## ៦. *ស្រមោលនៃថ្ងៃបុណ្យ*

ដូច្នេះ កុំទុកឲ្យអ្នកណានិន្ទាអ្នករាល់គ្នា ពីរឿងចំណីអាហារ ឬគ្រឿងផឹក ឬពីរឿងថ្ងៃបុណ្យ ថ្ងៃចូលខែ ឬថ្ងៃឈប់សម្រាកឡើយ សេចក្តីទាំងនេះជាស្រមោលនៃការដែលត្រូវមក តែតួរូបអង្គនោះ គឺជាព្រះគ្រីស្ទ (កូឡុស ២:១៦-១៧)។

អត្ថន័យនៃបុណ្យណូអែលនោះគឺថា ខ្លឹមសារនៃបុណ្យណូអែលជាកម្មសិទ្ធិរបស់ព្រះគ្រីស្ទ។ នេះបានសេចក្តីថា ការប្រារព្ធពិធីតាមជំនឿសាសនា គឺប្រៀបដូចជាស្រមោលរបស់បុគ្គលដ៏អស្ចារ្យ និងរុងរឿងម្នាក់។ ចូរយើងងាកចេញ

ពីស្រមោលនោះ ហើយមើលទៅព្រះភក្ត្ររបស់ព្រះអង្គវិញ (២កូរិនថូស ៤:៦)។ កូនតូចៗ រាល់គ្នាអើយ ចូរឲ្យអ្នករាល់គ្នារក្សាខ្លួនឲ្យផុតពីរូបព្រះចេញ (១យ៉ូហាន ៥:២១)។

# លេខខគម្ពីរយោង


*លោកុប្បត្តិ*
៣៧:៥–១១ .......... ១២៥
៥០:២០ .............. ១២៧

*ចោទិយកថា*
១០:១៧.............. ៨៧

*ទំនុកតម្កើង*
១៣៩:២៣–២៤ .... ៣៣

*សុភាសិត*
២១:១................. ៥១

*អេសាយ*
៨:១៨.................. ៩៤
៥៣:១០.............. ៩៤
៦០:៣ ................ ៦៨

*យេរេមា*
២៣:២៩ ............. ៣៣
៣១..................... ១៣១
៣១:៣១ ............. ១៣០
៣១:៣៤ ............. ១៣៣

*មីកា*
៥:១ ................... ៤៩, ១៥៦

*ម៉ាថាយ*
*កណ្ឌគម្ពីរទាំងមូល*.៦៧
២:១–២............... ៦៦
២:២................... ៧២, ៧៣
២:៣................... ៨០, ៨២
២:៤ ................... ៨២
២:៩ ................... ៧៣
២:១០................. ៨៨
២:១០–១១.......... ៨៦
៤:១–១១............ ១៤៤
១១:២៨–៣០....... ១៩៣
១៦:២១–២៣ ....... ១៤៤
២៣:១២ ............. ១៩៥
២៤:១៤.............. ៧៧
២៨:១៨–១៩ ....... ៦៨

*ម៉ាកុស*
៧:១៨–១៩.......... ២០២
១០:៤៥.............. ១៤៣, ១៩២

*លូកា*
១:១៦–១៧.......... ៣០
១:៤៣ ................ ៣៨
១:៤៦–៥៥.......... ៣៦
១:៤៨................. ៣៨
១:៦៨................. ៤៤

១:៦៨–៧១ .......... ៤៣, ៤២
២:១–៥ .......... ៤៨
២:៦–៧ .......... ៥៤
២:១១ .......... ៣២
២:១២–១៤ .......... ៦០
២:២៥ .......... ៤៤
២:៣៤–៣៥ .......... ៦២
២:៣៨ .......... ៤៤
៩:២៣ .......... ៥៦
៩:៥៧–៥៨ .......... ៥៧
២២:២០ .......... ១១៣

*យ៉ូហាន*
១:១ .......... ៩៥
១:៣ .......... ២៣
១:១១–១២ .......... ៦២
១:១២ .......... ២២,៩៤,៩៥
២:១៩–២១ .......... ២០១
៣:១៦ .......... ៩៤
៣:១៧ .......... ២២
៣:១៩ .......... ៦២
៤:២៣ .......... ៧៧
៦:៣៥ .......... ២២
៦:៤៤ .......... ២១
៦:៦៥ .......... ២១
១០:១០ .......... ១១៨, ១២១
១០:១១ .......... ២២
១០:១៧–១៨ .......... ២២
១១:៥២ .......... ៩៥
១៤:២៧ .......... ៦២
១៥:២០ .......... ៥៧
១៧ .......... ២១
១៧:១៨ .......... ១៣៦
១៧:២៤ .......... ២០, ២១
១៨:៣៧ .......... ១៥៤, ១៥៥, ១៥៧
២០:២៨ .......... ២២
២០:៣០–៣១ .......... ១៦០

*កិច្ចការ*
១០:៤៣ .......... ១៣៣
១៧:២៥ .......... ៨៧

*រ៉ូម*
៥:៥ .......... ១៦៨
៥:៩ .......... ៩៦
៥:១០ .......... ១៦៩
៥:១០–១១ .......... ១៦៦
៥:១១ .......... ១៦៩
៨:១ .......... ១៣៣
៨:៣ .......... ១៣៣, ១៩៣
៨:១៧ .......... ១២៧
៨:៣៣ .......... ៩៦
១៥:១៣ .......... ៦៣

*១ កូរិនថូស*
៥:៧ .......... ២០០
៧:១៩ .......... ២០១

*២ កូរិនថូស*
៤:៤ .......... ១៦៨
៤:៤–៦ .......... ១៦៧
៤:៦ .......... ១៦៨, ២០៣
៨:៩ .......... ៥៦

*អេភេសូរ*
២:៨–៩ .......... ១៩៤

*ភីលីព*
២:៥ .................... ១៩៥
២:៦–៨ ................ ១៩១
២:៩–១០ ............... ១២៧
២:៩–១១ ............... ១២៤
៤:៦–៧ ................ ៦៣

*កូឡុស*
២:៩ .................... ៩៥
២:១៦–១៧ .......... ២០២

*១ ធីម៉ូថេ*
១:១៥ .................. ១៥០
៤:១០ .................. ៩៥

*ហេព្រើរ*
*កណ្ឌគម្ពីរទាំងមូល*. ១០១, ១៩៩
២:១៣ .................. ៩៤
២:១៤ .................. ១៤៤
២:១៤–១៥ .......... ៩២, ៩៣
៧:២៣–២៤ .......... ២០០
៨:១ .................... ១០៨
៨:១–២ ................ ១០៧, ១០៦, ១០០, ២០១
៨:២ .................... ១០៨
៨:៥ .................... ១៩៩, ១០៧, ១០៦
៨:៦ .................... ១១២, ១១៣
៩:២៨ .................. ១៣៣
១១:៦ .................. ៦១
១៣:២០ ............... ១១៣
១៣:២០–២១ ....... ១១៤

*១ពេត្រុស*
២:២៤ .................. ១៣៣
៥:៥ .................... ១៩៥

*១ យ៉ូហាន*
*កណ្ឌគម្ពីរទាំងមូល*. ១៨០
២:១ .................... ១៧៤, ១៨០
២:១–២ ................ ១៧៤, ១៧៨
៣:៥ .................... ១៧៣
៣:៧–៨ ................ ១៧២, ១៧៨
៣:៨ .................... ១៧៣, ១៧៤, ១៤៨, ១៥០, ១៧៤
៣:២៣ .................. ១៨០
៤:៤ .................... ១៨៤
៥:២១ .................. ២០៣

## មានធនធានជាច្រើនទៀតនៅ៖

ផ្លូវពិត plovpit.com

**For ordering information please visit:**

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖

http://goodnewsofgreatjoykhmer.com

## ហើយទាញយកសៀវភៅជាច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com